# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី៣៤ លេខ ៥ ខែ ឧសភា

ព.ស. ២៥០៥ គ.ស. ១៩៦២

- ភ្នំពេញ -

ក 225-

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

---

*ផ្នែកសាសនា* | *បញ្ជីរឿង* | *ទំព័រ*


– សទ្ធម្មកថា ព្រះញាណវីរិយៈ ភ៌ន់-សាន់ រៀបរៀង . . . . . . . . . ៤៨៣

– លោកុត្តរចិត្ត (តចប់) អ្នកឧកញ៉ា ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . . . . ៤៩៤

– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកប៉ូ-ប៉ុំ ប្រែរៀបរៀង . . . . . . ៥០៨

– មធុរសវាហិណី(ត)សម្តេចព្រះធម្មលិខិតល្វី-ឯម ប្រែ ព្រះញាណកោសលញ-ឈឹនពិនិត្យ ៥១៧

– មហោសថជាតក(ត) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ ៥២៣

– ការលាយនៃភពផែនដីនឹងកើតជាថ្មីសាឡើងវិញ(តចប់)ពាក្យ លោកញ៉ុង-សឿង និពន្ធ ៥៣៣


*ផ្នែកអក្សរសាស្ត្រ*


– ភាសាសាស្ត្រនិងអក្សរសាស្ត្រខ្មែរ លោក ឌឹក-ជាម រៀបរៀង . . . . . . . ៥៥៥

– ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ “ក” . . ៥៦៦

– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . . . ៥៦៧

– រឿងសាមកុក (ត) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . . ៥៦៨

– រឿងព្រេងចិន (ត) លោក ភិយ ប៊ុក ប្រែរៀបរៀង . . . . . . . . ៥៧៨

– ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ . . . . . . . . . . . ៥៨៣


*ផ្នែកកំណត់ទីនប្រវត្តិការណ៍*


– ពិធីបុណ្យវិសាខបូជា នៅមុខព្រះសក្យមុនីចេតិយ លោក ជឹង-វង រៀបរៀង . . . . ៥៩២


---

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារៀល ២៣០,០០

34è Année — N° 5 — Mai 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Saddhammakatha par Vén. VAN-SADUM . . . . . . . 483
—Lokuttaracitta (suite et fin) par l'Oknha TEA-SAN. . . . 494
—Prah Abhidhamma pitaka « Kampi prah Yamaka » (suite)
traduit par M. BOU-PO . . . . . . . . . . . . 508
—Madhurasavahini (suite) traduit par Samdech Prah
Dhammalikhita LOUIS-EM, revu et corrigé
par le Vén. NHEAN-CHHŒUN. . . . . . . . . . 517
—Mahosatha Jataka (suite) relevé du manuscrit sur feuilles
de latanier par M. IM-PHON, revu et corrigé
par le Vén. KEM-TO . . . . . . . . . . . . . .523
—La fin du monde et sa formation (suite et fin)
par M. NHOUNG-SŒUNG. . . . . . . . . . . 533

### Partie littéraire

—Le Langage et la littérature Khmèrs par M. DIK-KEAM...555
—Activités de la Commission Culturelle (suite) chapitre «Ka» 566
—Dictionnaire Sanscrit-Khmèr (suite) par Vén. PANG KHAT 567
—Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN 568
—Contes et Légendes de la Chine (suite) traduits
par M. RAY-BUC . . . . . . . . . . . . . . . .578
—Annonce de Concours institués par la Commission des
Mœurs et Coutumes du Cambodge . . . . . . . 583

### Notes et Chroniques

—Fête du Visakha bochea devant le Prah Sakyamoni
Cheddey par M. THANG-VONG. . . . . . . . . 592

Prix d'Abonnement annuel (comprenant 12 numéros) : 230$ 00

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលោមក ឲ្យធ្វើល្អទៅ ។
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ត.

## សទ្ធម្មកថា

*ព្រះញាណវីរិយៈ ប៉ាង-សាឌុំ រៀបរៀង*

---

នមត្ថុ រតនត្តយស្ស

*សូមនមស្សការចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ។*

សទ្ធម្មោ គរុកាតព្វោ
សុខា សទ្ធម្មទេសនា ។

*វេលានេះ សូមពណ៌នាតាមបទបាទព្រះគាថា ដែលបានតាំងទុកខាងដើមនេះ ដើម្បីផ្សាយនូវឧត្តមគតិ នៃព្រះពុទ្ធសាសនា ដែលមានមកក្នុងព្រះត្រៃបិដក ដូចតទៅនេះ ៖*

*បាទទី ១ សទ្ធម្មោ គរុកាតព្វោ សាធុជនគួរគោរពព្រះសទ្ធម្ម*

*បាទទី ២ សុខា សទ្ធម្មទេសនា ការសំដែងព្រះសទ្ធម្ម នាំមកនូវសេចក្ដីសុខ ។*

ការគោរពព្រះសទ្ធម្ម ឬការសំដែងព្រះសទ្ធម្ម ជាករណីយកិច្ច របស់អ្នកប្រាជ្ញដែលមានសន្តានស្ងប់ ព្រោះព្រះសទ្ធម្ម ប្រែថា ធម៌ស្ងប់ ឬធម៌របស់លោកអ្នកស្ងប់ ៗ លោកអ្នកមានកុសល ឈ្លាសវៃក្នុង ការលះនឹងក្នុងការចំរើន នូវធម៌ដែលគួរលះនឹងធម៌ដែលគួរចំរើន អាច រក្សាខ្លួនមិនឲ្យកិលេសធម៌ដឹកនាំធ្វើអំពើអាក្រក់ មានបញ្ចវេរជាដើម នេះ ហៅថាលោកអ្នកស្ងប់ ដោយមាន សីល សមាធិ បញ្ញា ជាធម៌ស្ងប់ ក្នុងសន្តាន ៗ សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម មាននាមថា ជាអ្នកស្ងប់ ដែលហៅជាបាលីថាសន្តៈ ៗ ពួកសន្តៈអ្នកស្ងប់ រមែងមាន ធម៌ស្ងប់ជាទីគោរពជ្រះថ្លា គឺមានហឫទ័យធ្ងន់ក្នុងព្រះសទ្ធម្ម សមដោយ បាលីថា សតេ សទ្ធម្មគរុនោ ព្រះសម្ពុទ្ធគ្រប់អង្គ សុទ្ធតែទ្រង់គោ-រពក្នុងព្រះសទ្ធម្ម គឺមានការគោរពតាំងពីក្នុងការស្តាប់ព្រះសទ្ធម្មជាដើម ទៅ ៗ ដូច្នេះ អំពើកាយ វាចា ចិត្ត របស់លោកអ្នកស្ងប់ រមែងមាន ធម៌ស្ងប់ជាទីតាំង ហើយប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ ដែលជាមូលនៃ សេចក្តីសុខពិត ៗ សមដោយព្រះបាលីថា សន្តោ សោ ភគវា សមថាយ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះ ទ្រង់ជា សន្តៈអ្នកស្ងប់ ទ្រង់សំដែងធម៌ដើម្បីសេចក្តីស្ងប់ ៗ ការសំដែងធម៌ ដើម្បីសេចក្តីស្ងប់នេះហើយ ដែលចាត់ទុកជាព្រះសទ្ធម្មទេសនា មកក្នុង

ព្រះបាលីថា សុខា សទ្ធម្មទេសនា ការសំដែងព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ ។

សេចក្តីសុខក្នុងទីនេះ សំដៅយកនិរាមិសសុខ យ៉ាងបរិសុទ្ធឥតប្រែក្លាយ កើតឡើងអំពីព្រះសទ្ធម្ម មានព្រះសទ្ធម្មគឺសីលជាដើម ។ ពុំមែនទូទៅដល់សាមិសសុខ ដែលមិនបរិសុទ្ធកើតអំពីអសទ្ធម្មមាន រូប សំឡេង ជារបស់មនុស្ស ឬរបស់ទេវតាជាដើម ហើយប្រែក្លាយទៅជាទុក្ខវិញឡើយ ។ ដ្បិតសេចក្តីសុខ សោមនស្ស ព្រោះរូប សំឡេង ជាដើមនោះ ព្រះពុទ្ធជាអម្ចាស់ទ្រង់ត្រាស់ថា ជាវិបរិណាមទុក្ខទៅហើយ ដោយសេចក្តីសុខសោមនស្សនោះ តែងតែប្រែក្លាយទៅជាទុក្ខវិញនៅវេលាដែលអារម្មណ៍មានរូបជាដើមនោះវិបត្តិ ព្រោះហេតុមានការចាស់-ស្លាប់ជាដើម ។ ហេតុនេះ ទើបអ្នកប្រាជ្ញទាំងឡាយ ពុំអាចលះព្រះសទ្ធម្ម ព្រោះអសទ្ធម្មឡើយ ប្រែសេចក្តីថា លោកពុំអាចប្រព្រឹត្តទុច្ចរិត ព្រោះតែចង់បានលាភ យស សរសើរ សុខ ឬ រូប សំឡេង ក្លិន រស ផ្សព្វនោះៗ ឡើយ ។

ព្រះសទ្ធម្ម បើពោលដោយខ្លីមាន ៣ ប្រការ គឺៈ បរិយត្តិសទ្ធម្ម ១ បដិបត្តិសទ្ធម្ម ១ បដិវេធសទ្ធម្ម ១ ។ ធម្មវិន័យ គឺព្រះត្រៃបិដក ជាសត្ថុសាសនៈ (ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាអម្ចាស់) ដែលអ្នកប្រាជ្ញលោកបានសង្គាយនារៀបចំទុកមក ប្រកបដោយអត្ថទាំង

៩ ប្រការ មានសុត្តៈ គេយ្យៈ ជាដើម ដែលជាគ្រឿងរៀនសូត្រជាន់ដំបូងសម្រាប់សាងសីល សមាធិ បញ្ញា ហៅថា បរិយត្តិសទ្ធម្ម ៗ សីល សមាធិ បញ្ញា ដែលកើតឡើងដោយការប្រតិបត្តិតាមធម្មវិន័យ ហៅថា បដិបត្តិសទ្ធម្ម ៗ មគ្គ ផល និព្វាន ដែលកើតមានព្រោះសីល សមាធិ និងបញ្ញា ហៅថា បដិវេធសទ្ធម្ម ៗ

ព្រះពុទ្ធជាអម្ចាស់ បានត្រាស់ដឹងហើយ ទ្រង់បំពេញពុទ្ធកិច្ចស្ទើរតែគ្មានពេលសម្រាក ៗ ក្នុងរវាង ៤៥ ព្រះវស្សា តាំងពីបានត្រាស់ទល់បរិនិព្វាន ទ្រង់មានពុទ្ធកិច្ច គឺប្រកាសព្រះសទ្ធម្មតាំង ៣ ប្រការ និងទ្រង់ប្រតិស្ឋាននូវពុទ្ធសាសនមណ្ឌល ដែលប្រដាប់ដោយបរិស័ទ ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ៗ ក្នុងការប្រកាសព្រះសទ្ធម្ម ទ្រង់ប្រកាសដោយព្រះអង្គឯងផង ទ្រង់ត្រាស់ឲ្យពុទ្ធសាវ័កតាំងឡាយជួយប្រកាសផង ៗ ឧទាហរណ៍ ដូចក្នុងបឋមពោធិកាល ទ្រង់បានប្រកាសព្រះធម្មចក្ក និងព្រះសទ្ធម្មដទៃ ៗ ទៀត មានអនត្តលក្ខណសូត្រជាដើម ៗ កាលមានព្រះអរហន្តជាពុទ្ធសាវ័កបានចំនួន ៦០ រូបហើយ ទ្រង់ក៏បញ្ជូនព្រះអរហន្តតាំងនោះ ឲ្យទៅប្រកាសព្រះសទ្ធម្មក្នុងទិសទីនានា ហើយទ្រង់ហាមមិនឲ្យទៅតាមផ្លូវតែមួយដល់ ២ រូបផង ដើម្បីឲ្យព្រះសទ្ធម្មឆាប់ផ្សព្វផ្សាយទៅបានច្រើនកន្លែង ៗ តាំងព្រះអង្គឯង ក៏ធ្វើពុទ្ធដំណើរតែមួយព្រះអង្គ សំដៅទៅប្រោសជដិលមួយពាន់នាក់ ឯឧរុវេលប្រទេស

ដែរ ៗ ក្នុងរយៈផ្លូវពុទ្ធដំណើរនេះ ទ្រង់បានបំបួសព្រះភទ្ទវគ្គិយកុមារ ៣០ អង្គ ដែលបានស្តាប់ព្រះសទ្ធម្មទេសនាបានសម្រេចមគ្គផល ហើយទ្រង់បញ្ជូនទៅដូចមុន ទើបស្តេចធ្វើពុទ្ធដំណើរតទៅតែមួយព្រះអង្គទៀត ៗ ហេតុការណ៍ប៉ុណ្ណេះជាដើម ធ្វើឲ្យយើងឃើញថា ព្រះអង្គមានពុទ្ធបំណងធ្ងន់ណាស់ ក្នុងការផ្សាយព្រះសទ្ធម្មដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដើម្បីគុណដល់សព្វសត្វ ដោយព្រះមហាករុណា ៗ

ព្រះបរិយត្តិសទ្ធម្ម គឺធម្មវិន័យ ដែលមានមកក្នុងព្រះត្រៃបិដកជាសត្ថុសាសនៈ អាចជាតំណាងព្រះអង្គ តាំងពីទ្រង់គង់ព្រះធរមាននៅឡើយ ហេតុនេះហើយ បានជាព្រះអង្គទ្រង់ត្រាស់ថា "នរណាឃើញធម៌ នរនោះឈ្មោះថាឃើញព្រះអង្គ" ទោះបីពុំបានជួបព្រះភក្ត្រព្រះអង្គក៏ដោយ ៗ នរណាគ្រាន់តែជួបព្រះភក្ត្រព្រះអង្គ តែពុំបានឃើញធម៌ នរនោះពុំអាចឈ្មោះថាបានឃើញព្រះអង្គឡើយ ៗ លុះទៀបចូលបរិនិព្វានទ្រង់ត្រាស់ ១ បែបទៀតថា អំណើះពីព្រះអង្គទៅ ធម្មវិន័យដែលទ្រង់បានសំដែងបានបញ្ញត្តហើយនឹងបានជាសាស្តាតំណាងព្រះអង្គ ដូច្នេះពុទ្ធបរិស័ទដែលបានប្រតិបត្តិតាមធម្មវិន័យ ឈ្មោះថាបានបូជាព្រះអង្គដោយសក្ការបូជាយ៉ាងប្រសើរបំផុត ៗ ពួកពុទ្ធបរិស័ទដែលបានឃើញព្រះអង្គដោយវិចារណញ្ញាណ តាំងមាន

សេចក្ដីស្នេហា កតញ្ញូ កតវេទី ចំពោះព្រះអង្គ ចង់ឲ្យព្រះអង្គទ្រង់គង់ព្រះធរមាននៅ ដោយព្រះមហាករុណាធិគុណ រមែងនាំគ្នាយកចិត្តទុកដាក់ក្នុងព្រះសទ្ធម្ម គោរពក្នុងព្រះសទ្ធម្ម លើកតំកើងនូវព្រះសទ្ធម្មដែលមានមកក្នុងព្រះត្រៃបិដក ដោយការសិក្សា និងការប្រតិបត្តិតាមសីល សមាធិ បញ្ញា, ពោះបើលោកអ្នកទាំងនោះអស់ករណីយកិច្ចផ្ទាល់ខ្លួនហើយក៏ដោយ ការសង្គាយនារៀនរៀបផ្ទៀងផ្ទាត់ធម្មវិន័យក្ដី រៀនទន្ទេញធម្មវិន័យក្ដី ផ្សាយធម្មវិន័យក្ដី ជាករណីយកិច្ចនៃពុទ្ធសាវកទាំងឡាយ តាំងពីព្រះពុទ្ធជាអម្ចាស់ទ្រង់គង់ព្រះធរមាននៅឡើយ ។ ព្រះសារីបុត្តដែលជាគូអគ្គអគ្គសាវក បានក្រាបបង្គំទូលសុំព្រះពុទ្ធានុញ្ញាតប្រជុំសង្ឃធ្វើសង្គាយនាមួយគ្រា ។ ក្នុងការសង្គាយនានោះ អង្គលោកជាអ្នកសំដែងរៀបរៀងធម្មវិន័យក្នុងសង្ឃសន្និបាត នៅទីចំពោះព្រះភក្ត្រនៃព្រះបរមសាស្ដា លោកបានបញ្ជាក់គ្រប់ក្នុងធម៌ថា នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសនៈ លោកដ៏មានអាយុទាំងឡាយ គប្បីចាំទុកដូច្នេះចុះ ។ គ្រាព្រះដ៏មានបុណ្យបរិនិព្វានហើយ ពុទ្ធសាវកទាំងឡាយ មានព្រះមហាកស្សបៈជាប្រធាន បានប្រជុំធ្វើសង្គាយនាដែលហៅថាបឋមសង្គាយនា ។ ក្នុងការសង្គាយនានេះ បានលើកព្រះវិន័យមកសង្គាយនាជាមុន ទើបសង្គាយនាព្រះធម៌ គឺព្រះសូត្រនិងព្រះ

អភិធម្ម ។ ព្រោះហេតុនោះ សត្ថុសាសនៈដែលធ្លាប់មានឈ្មោះតែពីរ គឺធម៌ ១ វិន័យ ១ ក៏ប្រាកដទៅជាបិដកទាំង ៣ គឺ ព្រះវិន័យបិ-ដក ១ ព្រះសុត្តន្តបិដក ១ ព្រះអភិធម្មបិដក ១ ។ កាលសង្គាយនាបិដកទីមួយ ។ ចប់ ដោយយល់ឃើញព្រមគ្នាថាជាធម៌ ជាវិន័យ ជាសត្ថុសាសនៈហើយ ក៏នាំគ្នាស្វាធ្យាយឲ្យបានចាំស្ទាត់ទាំងអស់ រួចប្រកាសផ្សាយធម្មវិន័យ ដរាបអស់ព្រះជន្មរៀងខ្លួន ។

តពីនោះមកចេះតែមានការសង្គាយនាជាលំដាប់ គឺទុតិយសង្គាយនា តតិយសង្គាយនា ចតុត្ថសង្គាយនាជាដើម តាំងពីអរហន្តសម័យ ដរាបដល់សម័យនេះ ។ ក៏សុទ្ធតែប្រាកដក្នុងប្រវត្តិពុទ្ធសាសនា សង្គាយ-នានៅជម្ពូទ្វីបមជ្ឈិមប្រទេស (ឥណ្ឌា) ៣គ្រា ។ នៅលង្កាទ្វីប ២ គ្រា និងនៅឧបទ្វីបសុវណ្ណភូមិយើងនេះច្រើនគ្រា ដូចជានៅប្រទេសភូមា និងប្រទេសកម្ពុជាយើងនេះជាដើម ។ ការសង្គាយនាទាំងនេះ សុទ្ធតែជារបស់រដ្ឋ មានអគ្គព្រះមហាក្សត្រិយ៍ ឬប្រធានាធិបតី ជាពុទ្ធសាសនូ-បត្ថម្ភក ។

ការសង្គាយនាទាំងឡាយ ដែលមានមកហើយ តាំងពីពុទ្ធសត-វត្សរ៍ទី ១ ដរាបដល់ពុទ្ធសតវត្សរ៍ទី ២៥ ដែលទើបកន្លងទៅនេះ សុទ្ធតែមានការផ្ទៀងផ្ទាត់បាលីព្រះត្រៃបិដក ឲ្យត្រឹមត្រូវតាមបែបបឋម-សង្គាយនាដូចគ្នាទាំងអស់ ។

ការសង្គាយនាព្រះត្រៃបិដក របស់រដ្ឋកម្ពុជាយើង ចាប់ផ្ដើមធ្វើមកតាំងពីក្នុងរជ្ជកាល នៃព្រះករុណាព្រះបរមខត្តិយកោដ្ឋ ដោយព្រះសង្ឃជាសង្គីតិកាចារ្យច្រើនរូប ដែលហៅថាក្រុមជំនុំព្រះត្រៃបិដក នៅក្រុមពុទ្ធសាសនបណ្ឌិត្យ បានប្រជុំរៀនផ្ទាត់ព្រះត្រៃបិដកភាសាបាលី រួចប្រែជាសម្រាយភាសាខ្មែរទាល់តែចប់ ។

យើងជាពុទ្ធបរិស័ទ គួរញុំាងចិត្តឲ្យជ្រះថ្លាក្នុងព្រះត្រៃបិដកនេះ គួរមើល គួរអាន គួរពិនិត្យ គួរជាវទុកជាសម្បត្តិប្រចាំជីវិត ព្រោះជាក្បួនច្បាប់មានសារប្រយោជន៍ខ្ពង់ខ្ពស់បំផុត អាចញុំាងដំណើងខាងពុទ្ធសាសនា ឲ្យច្បាស់ប្រាកដឡើង ដល់មនុស្សនិងទេវតា ទាំងអាចញុំាងសារធម៌ គឺសីល សមាធិ បញ្ញា ឲ្យផ្សាយជ្រួតជ្រាបទៅក្នុងសន្ដាននៃសត្វលោកផង ។

យើងរាល់គ្នា ដែលបានសៀវភៅព្រះត្រៃបិដកបោះពុម្ព ជាបាលីម្ខាង សម្រាយម្ខាងរាល់ទំព័របែបនេះប្រសើរណាស់ ប្រៀបដូចបានប្រទីបឬគោមធំ ៗ ពីរដួរ តាំងនៅអមផ្លូវទាំងសងខាង ដែលជាផ្លូវដើរទៅកាន់ទីក្សេមក្សាន្ត និរទុក្ខ និរភ័យ ។

មួយទៀត ការសង្គាយនាព្រះសទ្ធម្ម ការជួយឧបត្ថម្ភក្នុងការសង្គាយនាដោយវិធីផ្សេង ៗ ក្ដី ដែលនឹងកើតឡើងបាន ក៏ដោយសារមានយោបល់សំខាន់ ៗ មានដើមដូចតទៅនេះ ៖

១- ព្រះពុទ្ធជាម្ចាស់ មិនងាយកើតមានក្នុងលោក ព្រោះត្រូវកសាងអភិនីហារអស់កាលយូរអង្វែងណាស់ ទើបបានត្រាស់ជាព្រះពុទ្ធ ។ កាលបើព្រះពុទ្ធមិនងាយកើតមានហើយ ព្រះសទ្ធម្ម គឺធម្មវិន័យ ជាសត្ថុសាសនៈក៏មិនងាយកើតមានដែរ ។ ព្រះសទ្ធម្មទាំងឡាយ មានព្រះបរិយត្តិសទ្ធម្មជាដើម សុទ្ធតែមានព្រះត្រៃបិដកនេះជាប្រភព ប្រែសេចក្តីថា យើងគួរតែស្វះស្វែងរកព្រះសទ្ធម្មក្នុងព្រះត្រៃបិដកនេះឯង ។

២- ការសំដែងព្រះសទ្ធម្ម ស្តាប់ព្រះសទ្ធម្ម, រៀនសូត្រព្រះសទ្ធម្ម, ប្រតិបត្តិញុំាងព្រះសទ្ធម្ម ឲ្យកើតមានក្នុងសន្តាន នេះរមែងប្រព្រឹត្តទៅដើម្បីសុខសន្តិភាព ។ ហេតុនេះ ទើបអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ពេញព្រះទ័យណាស់ក្នុងការផ្សាយព្រះសទ្ធម្ម ដើម្បីប្រយោជន៍ដល់សព្វសត្វ ។

៣- ការសាងបារមី ដើម្បីត្រាស់ជាព្រះពុទ្ធ និងការបំពេញពុទ្ធកិច្ច មានប្រកាសព្រះសទ្ធម្មទេសនាជាដើម ដោយព្រះមហាករុណានៃព្រះពុទ្ធជាអម្ចាស់យើង ធ្វើឲ្យព្រះអង្គលំបាកព្រះកាយហួសប្រមាណ មុខគួរសំវេគ អាណោចអាណិតព្រះទ័យព្រះអង្គណាស់ ។ ហេតុនេះ យើងជាពុទ្ធបរិស័ទ គួរតែប្រតិបត្តិឲ្យសមតាមព្រះពុទ្ធបំណង ។

៤- ព្រះពុទ្ធជាបរមសាស្តាយើង ទ្រង់លត់ខន្ធចូលកាន់ព្រះបរមនិព្វានកន្លងមកជាងពីរពាន់ប្រាំរយឆ្នាំហើយ មានតែព្រះសទ្ធម្ម គឺព្រះ

ត្រៃបិដកជាពុទ្ធវចនៈនេះហើយ ដែលឋិតនៅជាតំណាងព្រះអង្គ ។ បើយើងជាពុទ្ធបរិស័ទមិនយកចិត្តទុកដាក់ ធ្វើសក្ការៈគោរពកោតខ្លាចជាព្រះសទ្ធម្មគឺព្រះត្រៃបិដកជាតំណាងព្រះអង្គ ដោយអាមិសបូជា និងដោយបដិបត្តិបូជាទេ តើឲ្យនរណាយកចិត្តទុកដាក់ជំនួសវិញ ។

៤- ព្រះពុទ្ធសាសនាដែលនឹងរុងរឿងឋិតថេរចិរកាលទៅបាន ក៏ដោយសារសម្មាបដិបត្តិនៃពុទ្ធបរិស័ទទាំងអស់គ្នា ដែលមានការរៀនទន្ទេញអានមើល នូវព្រះត្រៃបិដកនេះជាមូលហេតុ ។ ចុះបើយើងជាពុទ្ធបរិស័ទ មិនយកចិត្តទុកដាក់ក្នុងការរៀននេះហើយ តើពុទ្ធសាសនានឹងសន្ធឹមលើនរណា ។ យើងតែងបានដឹងថា ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា សាសនាព្រះអង្គនឹងរុងរឿង ដោយសារបរិស័ទដែលជាកូនទៅព្រះអង្គ ខំរៀន ខំប្រតិបត្តិតាម ។ ព្រោះការរៀន ការប្រតិបត្តិនេះហើយជាគ្រឿងប្រកាសគុណព្រះរតនត្រ័យឲ្យប្រាកដ ។

៦- មនុស្សទាំងក្នុងលោកសព្វថ្ងៃនេះ កំពុងអំពាវនាវស្រែករកសន្តិភាព ។ បើអត្ថរសព្រះសទ្ធម្មក្នុងព្រះបិដកទាំង ៣ បានផ្សាយជ្រួតជ្រាបទៅក្នុងពួកមនុស្សនាសកលលោក យ៉ាងហោចឲ្យបានត្រឹមសីល ៥ ដែលហៅថានិច្ចសីល ការអំពាវនាវរកសន្តិភាពនោះមុខជាបាននូវសម្រេចផលតាមបំណង ។

ដោយអាស្រ័យយើងជាពុទ្ធបរិស័ទទាំងអស់គ្នា មានយោបល់ស្រប គ្នាបែបនេះ ទើបដូចយើងអាចធ្វើសង្គាយនាព្រះសទ្ធម្ម គឺព្រះត្រៃបិដក ជាពុទ្ធវចនៈ ឲ្យបានសម្រេចផលដកបមក ទាំងតទៅមុខទៀត ។

កាលបើយើងបានសង្គាយនា នឹងជួយទំបតម្កល់ការនេះ ដោយ ឃើញថា អំពើប្រសើរនេះ ជាករណីយកិច្ចរបស់ខ្លួន ដែលជាពុទ្ធបរិ-ស័ទ កូនចៅព្រះសម្មាសម្ពុទ្ធ គួរតែធ្វើដើម្បីសំដែងសេចក្ដីកតញ្ញូកតវេទី ចំពោះព្រះអង្គផង ។ នោះយើងនឹងបានសម្រេចផលានិសង្សយ៉ាង ខ្ពង់ខ្ពស់ កាលនឹកដល់អំពើដែលខ្លួនបានធ្វើហើយនេះគ្រាណា គ្រានោះ សេចក្ដីសោមនស្សជ្រះថ្លា នឹងកើតមានដល់យើងមិនតិចឡើយ ។ ម្យ៉ាងទៀត បុញ្ញាភិសន្ទៈ ស្ទឹងបុណ្យគឺសេចក្ដីស្ងប់ នឹងសេចក្ដីសុខសួ-ស្ដី រមែងហូរមកកាន់ខន្ធសន្តាន ទាំងយប់ទាំងថ្ងៃ តាមដែលយើងនឹក យកអំពើនេះមកជាការម្មណ៍ ។

សំដែងមកក្នុងព្រះសទ្ធម្ម ធម៌ស្ងប់នាំឲ្យកើតសទ្ធិកាព នឹងសទ្ធិសុខ ដែលសាធុជនគួរគោរព គួរបូជា ដោយអាមិស នឹងដោយសេចក្ដីប្រតិបត្តិ ចប់ដោយសង្ខេបតែប៉ុណ្ណេះ ។

---

# លោកុត្តរចិត្ត

អ្នកចងក្រង ជា-សាន អតីតវជ្ជមន្ត្រីរៀបរៀង

( តមក )

---

៣ - អប្បណិហិតវិមោក្ខ គឺការរួចផុតស្រឡះចាកកិលេស ដោយគ្មានទីតាំងកិលេស ១ ។

រីឯវិមោក្ខ ៣ វិញ គឺបញ្ជាក់ថា ចិត្តដែលរួចផុតស្រឡះចាកកិលេសគឺ រួចចាកដោយសូន្យកិលេស ១ ដោយគ្មានគ្រឿងសំគាល់កិលេស ១ នឹង ដោយគ្មានទីតាំងកិលេស ១ ពោលគឺដោយកិលេសរលត់អស់គ្មានសេស សល់នោះឯង ។ ដោយហេតុនេះ ទើបវិមោក្ខ៣ប្រការ ត្រូវចាត់ទុក ជានិមិត្តរូបនៃកិរិយារលត់អស់ទៅនៃកិលេស ហើយវិមោក្ខ៣នោះ មាន តែព្រះអរហន្តដែលបានសម្រេចមគ្គចិត្ត ៤ នឹងផលចិត្ត ៤ នោះទេ ដែល អាចធ្វើឲ្យជាក់ច្បាស់ឡើងបានដោយចំរើនអនុបស្សនា៣ គឺ សុញ្ញតា-នុបស្សនា ១ អនិមិត្តានុបស្សនា ១ នឹង អប្បណិហិតា-នុបស្សនា ១ កិរិយាធ្វើឲ្យជាក់ច្បាស់នូវវិមោក្ខ ៣ ប្រការនេះហើយ ដែលហៅថា និញ្ញាណសច្ឆិកិរិយា គឺកិរិយាធ្វើឲ្យជាក់ច្បាស់នូវព្រះ និព្វាននោះឯង ។

---

លំដាប់តទៅនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយអំពីផលចិត្ត ៤ ដួង ដែលកើត

មានឡើងដោយមគ្គចិត្ត ៤ ដួងជាមូលហេតុ ដូចមានសេចក្ដីបញ្ជាក់ខាងក្រោមនេះ ៗ

## ៩- ផលចិត្ត ៤ ដួង

រីឯផលចិត្ត ៤ ដួង ដែលត្រូវជាគូនឹងមគ្គចិត្ត ៤ ដួងនោះគឺៈ

ផលចិត្តទី ១- ឯផលចិត្តទី ១ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី ១ ជាមូលហេតុនោះឯង ៗ ដោយហេតុនេះទើបផលចិត្តទី១ នេះ ត្រូវចាត់ទុកជាផលចិត្តបានរួចផុតស្រឡះចាកទិដ្ឋាសវៈ នឹងសំយោជនៈ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆា នឹងសីលព្វតបរាមាស ១ ប្រកបដោយវិសុទ្ធិ ៥ មានទិដ្ឋិវិសុទ្ធិជាដើម ហើយត្រូវបាននាមបញ្ញត្តិហៅថា សោតាបត្តិផល នោះ ៗ

ផលចិត្តទី ២- ឯផលចិត្តទី ២ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី ២ ជាមូលហេតុនោះឯង ៗ ដោយហេតុនេះទើបផលចិត្តទី ២ នេះត្រូវចាត់ទុកជាផលចិត្តបានញុំាងកាមាសវៈ នឹង សំយោជនៈ ២ គឺ កាមរាគៈ នឹង បដិឃៈ ឲ្យសាបរលាបស្រាលស្តើង ហើយត្រូវបាននាមបញ្ញត្តិហៅថា សកទាគាមិផល នោះ ៗ

ផលចិត្តទី៣ -ឯផលចិត្តទី ៣ នោះ គឺសំដៅចំពោះផលចិត្តដែលកើតមានឡើងដោយមគ្គចិត្តទី៣ ជាមូលហេតុនោះឯង ៗ ដោយហេតុ

នេះទើបផលចិត្តទី ៣ ត្រូវចាត់ទុកជាផលចិត្តបានរួចផុតស្រឡះចាក

កាមាសវៈ និង សំយោជនៈ ២ គឺកាមរាគ និងបដិឃៈព្រម

ទាំងកាមតណ្ហាប្រកបដោយចិត្តវិសុទ្ធិ ហើយត្រូវបាននាមបញ្ញត្តិហៅថា

អនាគាមិផលនោះ ៗ

ផលចិត្តទី ៤– ឯផលចិត្តទី ៤ នោះ គឺសំដៅចំពោះផលចិត្តដែល

កើតមានឡើងដោយ មគ្គចិត្តទី ៤ ជាមូលហេតុនោះឯង ៗ ដោយហេតុ

នេះ ទើបផលចិត្តទី ៤ នេះ ត្រូវចាត់ទុកជាផលចិត្តបានរួចផុតស្រឡះចាក

ភវាសវៈ និង អវិជ្ជាសវៈ ហើយនិង សំយោជនៈ ៥ មានរូបរាគ

និងអរូបរាគជាដើម ព្រមទាំងតណ្ហា ២ គឺភវតណ្ហា និង វិភវតណ្ហា ប្រកប

ដោយវិសុទ្ធិ ២ គឺ បញ្ញាវិសុទ្ធិ និង វិមុត្តិវិសុទ្ធិ ហើយត្រូវបាន

នាមបញ្ញត្តិហៅថា អរហត្តផល នោះឯង ៗ រួមសេចក្តីទៅឃើញថា

ផលចិត្ត ៤ ដួងនេះបានរួចផុតស្រឡះចាកអាសវៈ ៤ និងសំយោជនៈ ១០

ហើយនិងតណ្ហា ៣ ប្រកបដោយវិសុទ្ធិ ៩ ប្រការ គ្រប់តាមកំរិតដែល

កំណត់ទុកពេញបរិបូណ៌អស់ហើយ ៗ បើដូច្នេះ គប្បីចោទសួរថា តើ

ផលចិត្ត ៤ ដួងនេះអាចផ្តល់ឲ្យអរិយបុគ្គលនូវឧត្តមប្រយោជន៍អ្វីខ្លះទៅ ? ៗ

ចំពោះសំនួរនេះ ខ្ញុំសូមឆ្លើយថា ផលចិត្ត ៤ ដួងនេះ កាលបើបាន

សម្រេចកើតមានឡើងហើយ រមែងនាំមកនូវចេតសិកសុខ ៤ ប្រការជា

ដើម ដូចមានសេចក្តីបញ្ជាក់ខាងក្រោមនេះ ៗ

## ១០- សុខ ៤ ប្រការ

ឯសុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដួងនោះ ត្រូវចែកជា ២ ប្រភេទដូចតទៅនេះ ៖

### សុខ ៤ ប្រការប្រភេទទី ១

បើពោលអំពីសុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដួង បានរួចចាកអាសវៈ ៤ នោះ ទើបសុខ ៤ ប្រការនោះត្រូវចាត់ទុកជាអាសវសុខ ៣ និងអនាសវសុខ ១ គឺ ៖

អាសវសុខទី ១- ឯសុខទី ១ ដែលកើតមានឡើងដោយផលចិត្តទី ១ បានរួចចាកទិដ្ឋាសវៈនោះ ត្រូវចាត់ទុកជាអាសវសុខទី ១ គឺសុខប្រកបដោយអាសវៈ ៣ គឺ កាមាសវៈ ១ ភវាសវៈ ១ និង អវិជ្ជាសវៈ ១ ។

អាសវសុខទី ២- ឯសុខទី ២ ដែលកើតមានឡើងដោយផលចិត្តទី២ បានញុំាងកាមាសវៈឲ្យសាបរលាបស្រាលស្តើងនោះ ត្រូវចាត់ទុកជាអាសវសុខទី ២ គឺសុខប្រកបដោយអាសវៈ ៣ ដែរ តែកាមាសវៈបានសាបរលាបស្រាលស្តើងហើយនោះ ។

អាសវសុខទី៣- ឯសុខទី ៣ ដែលកើតមានឡើងដោយផលចិត្តទី ៣ បានរួចចាកកាមាសវៈនោះ ត្រូវចាត់ទុកជាអាសវសុខទី ៣ គឺសុខប្រកបដោយអាសវៈ ២ គឺ ភវាសវៈ ១ និង អវិជ្ជាសវៈ ១ នោះ ។

អនាសវសុខ. ឯសុខទី ៤ ដែលកើតមានឡើង ដោយផលចិត្តទី ៤ បានរួចចាកភវាសវៈ និង អវិជ្ជាសវៈនោះ ត្រូវចាត់ទុកជាអនាសវសុខគឺ សុខមិនប្រកបដោយអាសវៈ ៤ ដោយប្រការដូច្នេះឯង ។

## សុខ ៤ ប្រការប្រភេទទី ២

បើពោលអំពីសុខ ៤ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដួងនោះបានរួចចាកសំយោជនៈ ១០ វិញនោះ ទើបសុខ ៤ ប្រការនោះ ត្រូវចាត់ទុកជាអាមិសសុខ ៣ និង និរាមិសសុខ ១ ដូចមានសេចក្តីបញ្ជាក់ខាងក្រោមនេះ ៖

អាមិសសុខទី ១ – ឯសុខទី ១ ដែលកើតមានឡើងដោយផលចិត្តទី ១ បានរួចចាកសំយោជនៈ ៣ មានសក្កាយទិដ្ឋិជាដើមនោះ ត្រូវចាត់ទុកជាអាមិសសុខទី ១ គឺសុខប្រកបដោយសំយោជនៈ ៧ មានកាមរាគជាដើម និងតណ្ហា ៣ មានកាមតណ្ហាជាដើមនោះ ។

អាមិសសុខទី២ – ឯសុខទី ២ ដែលកើតមានឡើងដោយផលចិត្តទី២ បានញាំងកាមរាគ និងបដិឃៈ ឲ្យសាបរលាបស្រាលស្តើងនោះ ត្រូវចាត់ទុកជាអាមិសសុខទី ២ គឺសុខប្រកបដោយ សំយោជនៈ ៧ និង តណ្ហា ៣ ដែរ តែសំយោជនៈ ២ គឺកាមរាគ និងបដិឃៈ ហើយនិងកាមតណ្ហាបានស្រាលស្តើងហើយ ។

អាមិសសុខទី ៣ – ឯសុខទី៣ ដែលកើតមានឡើងដោយផល

ចិត្តទី ៣ បានរួបតាកកាមរាគ នឹងបដិឃៈនោះ ត្រូវតាត់ទុកជាអាមិសសុខ ទី ៣ គឺសុខប្រកបដោយសំយោជនៈ ៥ មានរូបរាគជាដើម នឹងតណ្ហា ២ គឺភវតណ្ហា នឹងវិភវតណ្ហានោះ ។

និរាមិសសុខ– ឯសុខទី ៤ ដែលកើតមានឡើងដោយផលចិត្តទី៤ បានរួបតាកសំយោជនៈ ៥ មានរូបរាគជាដើមនោះត្រូវតាត់ទុកជានិរាមិសសុខ គឺសុខមិនប្រកបដោយ អាមិស ពោលគឺដោយសំយោជនៈ នឹងតណ្ហានោះឯង ។

## ១១– អរិយបុគ្គល ៤ ពួក

ឯអរិយបុគ្គល ៤ ពួកនោះគឺ៖

១– អរិយបុគ្គល ដែលបានសម្រេចមគ្គចិត្តទី១ នឹងផលចិត្តទី ១ ហើយនឹងតាសវសុខទី ១ នោះត្រូវមាននាមបញ្ញត្តិហៅថា ព្រះសោតាបន្ន គឺអរិយបុគ្គលដែលបានទៅដល់ដំណាក់ទី ១ នៃដំណើរឆ្ពោះទៅកាន់បរមសុខនោះ ។

២–អរិយបុគ្គល ដែលបានសម្រេចមគ្គចិត្តទី២ នឹងផលចិត្តទី២ ហើយនឹងតាសវសុខទី២ នោះត្រូវបាននាមបញ្ញត្តិហៅថា ព្រះសកទាគាមី គឺអរិយបុគ្គល ដែលបានទៅដល់ដំណាក់ទី ២ នៃដំណើរឆ្ពោះទៅកាន់បរមសុខនោះ ។

៣– អរិយបុគ្គល ដែលបានសម្រេចមគ្គចិត្តទី ៣ នឹងផលចិត្ត

ទី ៣ ហើយនឹងអាសវសុខទី ៣ នោះត្រូវបាននាមបញ្ញត្តិហៅថាព្រះអនាគាមី គឺអរិយបុគ្គលដែលបានទៅដល់ដំណាក់ទី ៣ នៃដំណើរឆ្ពោះទៅកាន់បរមសុខនោះ ។

៤-អរិយបុគ្គល ដែលបានសម្រេចមគ្គចិត្តទី ៤ នឹងផលចិត្តទី៤ ហើយនឹងអនាសវសុខនោះ ត្រូវបាននាមបញ្ញត្តិហៅថា ព្រះអរហន្ត គឺអរិយបុគ្គល ដែលបានទៅដល់ដំណាក់ទី ៤ ទុកជាដំណាក់ចុងក្រោយបំផុតនៃដំណើរឆ្ពោះទៅកាន់បរមសុខហើយ ។

ត្រង់នេះខ្ញុំសូមថ្លែងបញ្ជាក់តាមយោបល់ខ្ញុំថា អរិយបុគ្គល ៤ ពួកនេះ លុះណាតែបានសម្រេចមគ្គចិត្ត ៤ ផលចិត្ត ៤ នឹងសុខ ៤ ប្រការ ដូចមានពណ៌នាខាងលើនេះ ទើបឈ្មោះថាបានត្រាស់ដឹងមគ្គ ៤ មានសោតាបត្តិមគ្គជាដើម នឹងផល ៤ មានសោតាបត្តិផល ជាដើមនោះឯង ។

## ១២-បរមសុខ:

ចំពោះបរមសុខនេះមានបញ្ហាមួយចោទឡើងថា៖ បើសុខដែលកើតមានឡើងដោយផលចិត្ត ៤ ដួង មានតែ ៤ ប្រការ គឺអាសវសុខ ៣ នឹងអនាសវសុខ ១ ប៉ុណ្ណោះទេ, តើបរមសុខជាសុខកើតមានឡើងដោយចិត្តប្រភេទណាជាពិសេសទៀត ?

រីឯបញ្ហាដែលចោទឡើងនេះ, បើតាមការត្រិះរិះពិចារណាដែលខ្ញុំបានធ្លើនោះខ្ញុំយល់ឃើញថា បរមសុខនោះ គឺគ្រាន់តែជានាមបញ្ញត្តិសម្រាប់

ទុកហៅសុខទី ៤ ដែលកើតមានឡើងដោយផលចិត្តទី ៤ បានតាំងនៅស៊ប់ក្នុងវិមោក្ខ ៣ ប្រការ គោលគឺក្នុងការរួចផុតស្រឡះចាកកិលេសដោយសូន្យកិលេស ១ ដោយគ្មានគ្រឿងសំគាល់កិលេស ១ និងដោយគ្មានទីតាំងកិលេស ១ ទុកជាឯការម្មណ៍នោះឯង ពីព្រោះផលចិត្តទី ៤ កាលបើបានតោងយកវិមោក្ខ ៣ ធ្វើជាឯការម្មណ៍ហើយ រមែងជាហេតុធ្វើឲ្យអាសវក្កិលេសរលត់អស់ពីខន្ធសន្តាន ព្រមទាំងជាហេតុធ្វើឲ្យអនាសវសុខដែលជាសុខទី ៤ ប្រែសភាពៈកើតទៅជាអាសវក្ខយសុខ គឺសុខប្រកបដោយអាសវក្ខ័យវិញជាលំដាប់ ។

គឺអាសវក្ខយសុខ នេះហើយដែលត្រូវចាត់ទុកជាសុខទី ៤ ដែលកើតមានឡើងបន្ទាប់ពីអនាសវសុខ ហើយត្រូវបាននាមបញ្ញត្តិហៅថាបរមសុខ គឺសុខដ៏ឧត្តមគ្មានសុខណាអាចមកប្រៀបធៀបឲ្យស្មើបានសោះនោះឯង ។

ម្យ៉ាងទៀត មានតែព្រះអរហន្ត ដែលបានសម្រេចនូវអាសវក្ខយញាណហើយបានឡើងឋានៈជាព្រះខីណាស្រពនោះទេ ដែលត្រូវបានទទួលសោយនូវបរមសុខ គោលគឺអាសវក្ខយសុខនោះឯង ។

ត្រង់នេះសសេចក្តីឲ្យឃើញច្បាស់ថា បរមសុខក្តី ឯកន្តបរមសុខក្តី និព្វានក្តី គឺគ្រាន់តែជានាមបញ្ញត្តិសម្រាប់ទុកហៅ អាសវក្ខយសុខតែប៉ុណ្ណោះ ពីព្រោះអាសវក្ខយសុខ គឺសុខប្រកបដោយអាសវក្ខ័យនោះជាកំពូលលើសុខទាំងឡាយមានអាសវសុខ ៣ ប្រការជាដើម ។ ដោយ

ហេតុនេះហើយបានជាបណ្ឌិតលោកលើកយកតែបរមសុខ ឬឯកន្តសុខ ឬនិព្វាន ដែលជានាមនៃអាសវក្ខយសុខនោះមកថ្លែងប្រាប់បត្វ ដើម្បីទុកការៈឲ្យសត្វត្រិះរិះពិចារណាការកឲ្យឃើញនូវរូប នៃបរមសុខ ឬនិព្វាន ដោយខ្លួនឯងចុះ ។ ចំណែកឯមគ្គចិត្ត ៤ នឹងផលចិត្ត ៤ ក៏មានដំណើរដូច្នេះដែរ គឺបណ្ឌិតលោកលើកយកតែមគ្គ ៤ នឹងផល ៤ មកថ្លែងប្រាប់សត្វទុកឲ្យសត្វត្រិះរិះពិចារណាការកឲ្យឃើញច្បាស់ដោយខ្លួនឯងនូវរូបនៃមគ្គ ៤ នឹងផល ៤ នោះចុះ ។ ម្យ៉ាងវិញទៀត ដោយបរមសុខ ជាសុខប្រកបដោយអាសវក្ខ័យនោះ ទើបខ្ញុំយល់ឃើញថា គប្បីវែកញែកបរមសុខនោះជា ២ វិភាគឲ្យស្របទៅតាមហេតុនឹងផលគឺ ៖

– បរមសុខដែលសម្រេចកើតឡើងដោយភ្លើងកិលេសរលត់ ត្រូវបាននាមបញ្ញត្តិ ហៅថា ឧបាទិសេសនិព្វាន ១ ,

– នឹងបរមសុខដែលសម្រេចកើតឡើងដោយភ្លើងទុក្ខរលត់ ត្រូវបាននាមបញ្ញត្តិហៅថា អនុបាទិសេសនិព្វាន ១ ។

រីឯបរមសុខដែលសម្រេចកើតឡើង ដោយភ្លើងកិលេសរលត់នោះ ទុកជាបរមសុខក្នុងបច្ចុប្បន្ន ដែលព្រះខីណាស្រពគប្បីបានទទួលសោយ នៅខណៈដែលព្រះខីណាស្រពអង្គនោះ បានធ្វើនិព្វានសច្ឆិកិរិយាឲ្យប្រាកដច្បាស់ដោយវិមោក្ខ ៣ ប្រការនោះឯង ។ ចំណែកឯបរមសុខដែលសម្រេចកើតឡើងដោយភ្លើងទុក្ខរលត់នោះ ទុកជាបរមសុខទៅអនាគត

ដែលព្រះវិញ្ញាណស្រេពគប្បីបានទទួលសោយ នៅពេលដែលព្រះវិញ្ញាណស្រេពអង្គនោះបានរំលត់អាយុសង្ខារចូលកាន់ព្រះនិព្វាន ធ្វើដំណើរឆ្ពោះទៅកាន់អនាសានជាតិ គឺជាតិចុងក្រោយបំផុត លែងមានដំណើរវិលកើតវិលស្លាប់ទៀត ដោយប្រការដូច្នេះឯង ។

## ១៣- សេចក្តីប្រៀបផ្ទឹមរវាងសុខ ៧ ប្រការ :

សរុបសេចក្តីទៅឃើញថា លោកុត្តរចិត្ត ៨ ដួង គឺមគ្គចិត្ត ៤ ដួង និងផលចិត្ត ៤ ដួងនោះ កាលបើបានសម្រេចកើតមានក្នុងខន្ធសន្តានហើយ រមែងតែនាំមកនូវអាសវសុខ ៣ និងអនាសវសុខ ១ ហើយនិងបរមសុខ ១ ពុំខានឡើយ ។ ដើម្បីឲ្យយល់បានដោយងាយនូវសុខមាលភាពនៃសុខ ៥ ប្រការនោះរៀងជាលំដាប់, ខ្ញុំនឹងលើកយកចេតសិកសុខ គឺសុខខាងផ្លូវចិត្ត ៧ ប្រការមកធ្វើសេចក្តីប្រៀបផ្ទឹមតាំងពីកាមសុខរៀងទៅទល់នឹងបរមសុខដែលជាកំពូលនៃសុខទាំងឡាយ ដូចមានសេចក្តីអធិប្បាយតទៅនេះ ៖

១- កាមសុខ គឺសុខដោយការបរិភោគកាមនោះ ត្រូវចាត់ទុកជាសុខប្រកបដោយសំយោជនៈ ១០ ដែរ ។ ឯកាមសុខជាសុខប្រសើររបស់ពួកគ្រហស្ថមែនហើយ តែកាមសុខនេះមិនប្រសើរដល់នេក្ខម្មសុខទៀត ។

២- នេក្ខម្មសុខ គឺសុខដោយការចេញចាកកាមនោះ ត្រូវចាត់ទុកជាសុខប្រកបដោយសំយោជនៈ ១០ ដែរ តែសំយោជនៈ ៣ ខាន

ដើម គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ បានសាប រលាបស្រោលស្ងើងហើយ ។ ឯនេក្ខម្មសុខទុកជាសុខប្រសើររបស់ពួកបព្វ-ជិតមែនហើយ តែនេក្ខម្មសុខនេះមិនប្រសើរដល់អាមិសសុខទី ១ទៀត ។

៣- អាមិសសុខទី ១ គឺសុខប្រកបដោយសំយោជនៈ ៧ មាន កាមរាគជាដើម ទុកជាសុខប្រសើររបស់ព្រះសោតាបន្នមែនហើយ តែ អាមិសសុខទី ១ នេះ មិនប្រសើរដល់អាមិសសុខទី ២ ទៀត ។

៤- អាមិសសុខទី ២ គឺសុខប្រកបដោយសំយោជនៈ ៧ ដែរ តែកាមរាគ និងបដិឃៈបានសាបរលាបស្រោលស្ងើងហើយ ទុកជាសុខ ប្រសើររបស់ព្រះសកទាគាមីមែនហើយ តែអាមិសសុខទី ២ មិនប្រសើរ ដល់អាមិសសុខទី ៣ ទៀត ។

៥- អាមិសសុខទី ៣ គឺសុខប្រកបដោយសំយោជនៈ ៥ មាន រូបរាគជាដើម ទុកជាសុខប្រសើររបស់ព្រះអនាគាមីមែនហើយ តែអាមិ-សសុខទី ៣ នេះ មិនប្រសើរដល់និរាមិសសុខ គឺសុខមិនប្រកបទៅដោយ សំយោជនៈ ១០ទៀត ។

៦- និរាមិសសុខ គឺសុខមិនប្រកបដោយសំយោជនៈ ១០ ទុក ជាសុខប្រសើររបស់ព្រះអរហន្តមែនហើយ តែនិរាមិសសុខនោះមិនប្រសើរ ដល់បរមសុខទៀត ។

៧– បរមសុខ គឺសុខប្រកបដោយអាសវក្ខ័យ ទុកជាសុខប្រសើរបំផុតរបស់ព្រះខីណាស្រព, គ្មានសុខណាអាចមកប្រៀបផ្ទឹមបានឡើយ ។

សេចក្តីប្រៀបធៀបរវាងសុខ ៧ ប្រការនេះ នាំឲ្យសង្កេតឃើញថា នេក្ខម្មសុខ គឺជាសុខបានសសៀរវិតទៅអែបជិតនឹងអាមិសសុខទី ១ ឬអាសវសុខទី ១ ដែលជាសុខនៃព្រះសោតាបន្នបុគ្គលណាស់ទៅហើយ ។ ត្រង់នេះសេចក្តីឲ្យឃើញច្បាស់ថា ពួកបព្វជិត លោកនៅតែញុំាងទិដ្ឋា-សវៈនឹងសំយោជនៈ ៣ ខាងដើមឲ្យដាច់អស់ពីខន្ធសន្តានដោយវិបស្សនា-ការនោះទៅ ក៏លោកមុខតែនឹងបានសម្រេចនូវអាមិសសុខទី ១ ឬអាសវសុខទី ១ ពុំខានឡើយ ។

## ១៤– បញ្ហាដែលចោទមានឡើងដោយសុខ ៥ ប្រការ

សេចក្តីអធិប្បាយអំពីសុខ ៥ ប្រការ ដែលកើតមានឡើងដោយផលចិត្ត ៤ ដូច្នេះនោះជាហេតុនាំឲ្យមានបញ្ហាមួយចោទឡើងថា ៖

បើសុខ ៥ ប្រការនោះពិតជាចេតសិកសុខគឺសុខខាងផ្លូវចិត្តប្រសើរមែន តើហេតុដូចម្តេចបានជាពុទ្ធបរិស័ទភាគច្រើន ហាក់ដូចជាពុំសូវអើពើយកចិត្តទុកដាក់ចាប់អារម្មណ៍ទៅរកសុខ ៥ ប្រការនោះសោះ ? ។

ឯបញ្ហាដែលចោទឡើងនេះ ឃើញថាស្មុគ្រស្មាញពិបាកនឹងឆ្លើយដោះស្រាយឲ្យសមហេតុ-ផលណាស់ ពីព្រោះម្យ៉ាងខ្ញុំពុំដែលបានដឹងនូវ

អត្ថាស្រ័យនៃអស់លោកអ្នកជាពុទ្ធបរិស័ទផងឡើយ ពីព្រោះម្យ៉ាងទៀត ហេតុដែលជាប់ទាក់ទងនឹងបញ្ហានោះក៏មានច្រើនប្រការផងទៀត ។ បើដូច្នេះ ខ្ញុំសូមដោះស្រាយនូវបញ្ហាខាងលើនេះចំពោះតែហេតុដែលនាំខ្ញុំមិនឲ្យយកចិត្តទុកដាក់អើពើតាមអារម្មណ៍ទៅរកសុខ ៥ ប្រការនោះវិញ ទើបខ្ញុំអាចដឹងច្បាស់នូវហេតុនោះបាន ។ រីឯហេតុនោះ គឺមកតែពីខ្ញុំពុំដែលបានដឹងនូវសុខ ៥ ប្រការនោះសោះគឺខ្ញុំទើបតែត្រិះរិះពិចារណាការរកឃើញនូវសុខ ៥ ប្រការនោះនៅពេលថ្មី ៗ នេះ គឺនៅពេលដែលខ្ញុំរៀបរៀងសៀវភៅលោកុត្តរចិត្តនេះឯង ។

តើសេចក្តីអធិប្បាយបញ្ជាក់អំពីសុខ ៥ ប្រការ ដូចមានខាងលើនេះទុកជាត្រឹមត្រូវបានឬទេ. ត្រង់ចំណុចនេះគឺស្រេចតែអស់លោកអ្នកដែលបានអានសៀវភៅលោកុត្តរចិត្តនេះ មេត្តាជួយពិនិត្យនឹងសម្រេចសេចក្តីដោយសុភនិច្ឆ័យចុះ, ក៏ប៉ុន្តែចំណែកខ្លួនខ្ញុំ ៗជឿជាក់ក្នុងចិត្តថា សុខកើតមកតែអំពីចិត្ត, កាលបើចិត្តត្រូវបានដុសខាត់ជំរះបានស្អាតបរិសុទ្ធផូរផង់រួចពាកគ្រឿងសៅហ្មងនឹងគ្រឿងគ្រាំអស់ហើយ ចិត្តនោះត្រូវតែផ្តល់ឲ្យនូវសុខ ៥ ប្រការនោះពុំខានឡើយ ។

ដោយហេតុនេះ ខ្ញុំមានជំនឿថា បើពុទ្ធបរិស័ទបានដឹងច្បាស់នូវសុខ ៥ ប្រការ មានបរមសុខជាកំពូលនោះហើយ មុខតែមានពុទ្ធបរិស័ទខ្លះដែលនឿយណាយធុញទ្រាន់នឹងកងទុក្ខមានជាតិទុក្ខជាដើម យកចិត្តទុក

ជាក់ចាប់អារម្មណ៍ឆ្ពោះទៅរកសុខ ៤ ប្រការនោះមិនខានឡើយ ពីព្រោះមានតែសុខ ៤ ប្រការនេះទេដែលអាចកំចាត់បង់នូវកងទុក្ខនោះបានជាពិតប្រាកដ ។ ម្យ៉ាងទៀតខ្ញុំមានសង្ឃឹមយ៉ាងមាំថា បើពុទ្ធបរិស័ទដែលនឿយណាយធុញទ្រាន់នឹងកងទុក្ខមានជាតិទុក្ខជាដើមនោះ បានចាប់អារម្មណ៍ទៅរកសុខ ៤ ប្រការនោះហើយ, ពុទ្ធបរិស័ទនោះមុខតែនឹងខំស្វែងរកវត្តប្រតិបត្តិដែលអាចញុំាងសុខ ៤ ប្រការនោះឲ្យសម្រេចកើតឡើងបានមកសិក្សាឲ្យបេះចាំស្ទាត់ ដើម្បីនឹងបានតាំងចិត្តព្យាយាមបំពេញនូវវត្តប្រតិបត្តិទាំងឡាយនោះឲ្យសព្វគ្រប់ រៀងកបដកបលុះត្រាតែបានសម្រេចគោលបំណងជាទីបំផុតមិនខានឡើយ ។

នៅទីអវសានកថានេះ ខ្ញុំសូមថ្លែងបញ្ជាក់តាមអត្តនោម័តិថា វត្តប្រតិបត្តិទាំងឡាយណាដែលគ្មានគោលដៅឆ្ពោះទៅរកវិធីផុសខាត់ជំរះចិត្តឲ្យបរិសុទ្ធផូរផង់ ពោលគឺការលះកិលេសទេ, វត្តបដិបត្តិនោះទុកជាសីល-វត្តពុំគប្បីបដិបត្តិតាមឡើយ ពីព្រោះវត្តបដិបត្តិខុសទំនងពុំអាចផ្ដល់ឲ្យនូវសុខ ៤ ប្រការ មានបរមសុខជាកំពូលបានសោះឡើយ នេះគឺយោបល់ដែលខ្ញុំយល់ឃើញ, តែស្រេចនូវអស់លោកអ្នកជាពុទ្ធបរិស័ទត្រិះរិះពិនិត្យមើលថែមទៀតចុះ ។

សេចក្ដីអធិប្បាយអំពីលោកុត្តរចិត្តសន្ទគជាចប់ដោយសង្ខេបតែប៉ុណ្ណេះហោង ។

# ព្រះអភិធម្មបិដក

## គម្ពីរព្រះយមកៈ

លោក ប៊ុ - ប៊ុ ប្រែរៀបរៀង

( ភមព )

គោចរសម្បជញ្ញោ ឯវ ធាតុយោ សុញ្ញតោ
ធម្មវិសេសំ អធិគន្តុំ សមត្ថោ ហោតិ កាលវល្លិ-
មណ្ឌបវាសី មហានាគត្ថេរោ វិយ ច ។ សោ
កិរ បឋមំ ភគវតោ មហាបធានំ បូជេស្សាមីតិ ។

ម្យ៉ាងទៀត ព្រះយោគាវចរភិក្ខុប្រកបដោយគោចរសម្បជញ្ញៈ កាលបើបានពិចារណានូវធាតុទាំងឡាយឲ្យយល់ឃើញថា ជារបស់សាបសូន្យហើយ ក៏អាចបាននូវធម៌វិសេស ដូចជាព្រះមហានាគត្ថេរដែលគង់នៅក្នុងកាលវល្លិមណ្ឌបមហាវិហារ ។

សោ កិរ មានដំណាលថា ព្រះមហានាគត្ថេរនោះគិតថា អាត្មានឹងបូជានូវសេចក្ដីព្យាយាមចំពោះព្រះមានព្រះភាគជាដំបូង លោកគិតហើយ ក៏ធ្វើសេចក្ដីព្យាយាមចំរើនព្រះកម្មដ្ឋាន មិនបានលះបង់ចោលអស់ចំនួន ៧ ឆ្នាំ ។ ខាងក្រោយមក លោកតាំងព្យាយាមចំរើនព្រះកម្មដ្ឋាន ១៦ ឆ្នាំទៀត ទើបបានសម្រេចព្រះអរហត្ត ។

ន កេវលំ ច មិនមែនមានតែព្រះមហានាគត្ថេរ ១ រូបនេះទេ បញ្ញាស ភិក្ខូ វិយ ព្រះយោគាវចរប្រកបដោយគោចរសម្បជញ្ញៈ ហើយតាំងព្យាយាមចំរើនព្រះកម្មដ្ឋានមិនលះបង់ ទាល់តែបានសម្រេចមគ្គផល នៅមានជាច្រើនរូបទៀត ដូចជាភិក្ខុ ៥០ រូប ។

តេ កិរ មានដំណាលថា ភិក្ខុទាំង ៥០ រូបនោះ ធ្វើកតិកាវត្ត គឺនិយាយសន្យាគ្នាថា យើងរាល់គ្នាបើមិនបានសម្រេចមគ្គផលជាព្រះអរហន្តទេ យើងមិនត្រូវចរចាសន្ទនាគ្នាអំពីរឿងអ្វី ១ ឡើយ ទាល់តែយើងបានសម្រេចអរហត្តផលជាព្រះអរហន្តហើយ ទើបយើងនិយាយគ្នា ។ ភិក្ខុទាំង ៥០ រូបនោះ លុះសន្យាគ្នាយ៉ាងនេះហើយ កាលចូលទៅកាន់ស្រុកភូមិ ដើម្បីភិក្ខាចារគោចរបិណ្ឌបាតមិនចរចាសំណេះសំណាលគ្នាសោះ ។ ពួកអ្នកស្រុកឃើញភិក្ខុទាំងនោះស្ងៀមស្ងាត់ មិននិយាយគ្នាជារៀងរាល់ថ្ងៃខែដូច្នោះ ក៏និយាយប្រាប់គ្នាថា ន សល្លបន្តិ ហេតុអ្វីបានជាលោកម្ចាស់ទាំងនោះ មិននិយាយរកគ្នាផង មិននិយាយនឹងយើងរាល់គ្នាផង ប្រហែលជាលោកឈ្លោះប្រកែកទាស់ទែងទើងគំនិតគ្នាទេដឹង គួរតែយើងទៅឯវិហារញ៉ាំងលោកទាំងនោះឲ្យអត់ទោសដល់គ្នាទៅវិញទៅមក ។

សព្វេ វិហារំ គន្ត្វា មនុស្សទាំងពួងនាំគ្នាទៅកាន់ព្រះវិហារ មិនបានឃើញភិក្ខុទាំងនោះ គង់លើសេនាសនៈជាមួយគ្នា តាំងតែពីអង្គ

ទៀងទៅ ប៉ុន្តែ បានឃើញបរិវេណវិហារ ទីលានព្រះចេតិយ, លានព្រះស្រីមហាពោធិ, ឃើញទឹកប្រើ, ទឹកឆាន់ដំកល់ទុកនៅជាប្រក្រតី ៗ យោ ចក្ខុមា បណ្តាមនុស្សអ្នកបានទៅឃើញទីព្រះវិហារក្តី គ្រានោះ អ្នកដែលមានបញ្ញាចក្ខុ ចេះត្រិះរិះពិចារណារកហេតុផល ប្រាប់ជនទាំងនោះថា វសេ ោគោសោ លំនៅរបស់ភិក្ខុទាំងអស់ដែលមានសភាពយ៉ាងនេះ មិនមែនជាលំនៅរបស់អ្នកឈ្លោះប្រកែកគ្នាទេ ព្រោះទីបរិវេណ, លានព្រះចេតិយ ទីលានព្រះស្រីមហាពោធិ ស្អាតបាតល្អឥតសម្រាម ទាំងទឹកប្រើទឹកឆាន់ក៏មានពេញពាងពេញក្អម ឥតខ្វះ សុនិក្ខិត្តា អំបោសដែលបោសរួចហើយ ក៏ទុកដាក់រៀបរយតាមទីកន្លែង ៗ ហេតុនេះ ភិក្ខុទាំងអស់មិនឈ្លោះប្រកែកគ្នាទេ និយាយគ្នាហើយត្រឡប់ទៅផ្ទះរៀងខ្លួនវិញ ៗ

ចំណែកភិក្ខុទាំង ៨០ រូប ខំតាំងព្យាយាមបំពេញវត្តប្រតិបត្តិមិនលះបង់ចោល ទាល់តែបានសម្រេចព្រះអរហត្តផលព្រមទាំងបដិសម្ភិទាញាណ ទើបបានចរចាសន្ទនាគ្នាទៅវិញទៅមកតាមធម្មតា ៗ ភិក្ខុទាំង ៨០ រូបខំព្យាយាមចំរើនព្រះកម្មដ្ឋានមិនបានលះបង់យ៉ាងនេះ ឈ្មោះថាអ្នកមានគោចរសម្បជញ្ញៈ ៗ

## ៤– អធិប្បាយអំពីអសម្មោហសម្បជញ្ញៈ

អសម្មោហសម្បជញ្ញៈនោះ បានដល់កិរិយាដែលភិក្ខុចំរើនកម្មដ្ឋាន

មិនវង្វេងវិលវល់ មិនភាន់ច្រឡំ ពិចារណានូវខន្ធ, ធាតុ, អាយតនៈ នឹងបច្ច័យឲ្យយល់ច្បាស់ថា ចក្ខុនោះឯងឈ្មោះថា ចក្ខុធាតុ ៗ នោះគឺជាចក្ខុ ៗ ចក្ខុធាតុនេះជាអនិច្ចំមិនទៀងទាត់ ជាទុក្ខ មិនមែនជារបស់ខ្លួន ៗ ភិក្ខុគប្បីពិចារណានូវធាតុទាំង ១៨ ប្រការ មានចក្ខុធាតុជាដើម មានមនោធាតុជាបរិយោសានដោយប្រការដូច្នេះ ឈ្មោះថា អសម្មោហ-សម្បជញ្ញៈ ៗ

ម្យ៉ាងទៀត ភិក្ខុពិចារណានូវបច្ច័យទាំងបួន គឺចីវរបច្ច័យ, បិណ្ឌ-បាតបច្ច័យ, សេនាសនបច្ច័យ និងគិលានភេសជ្ជបច្ច័យ ក្នុងវេលាទទួល ឬវេលាស្វែងរក និងវេលាបរិភោគប្រើប្រាស់នូវបច្ច័យទាំងបួននោះ ណាមួយ មិនវង្វេងភ្លាំងភ្លេច មិនភាន់ច្រឡំ យ៉ាងនេះឈ្មោះថា អ្នកមាន អសម្មោហសម្បជញ្ញៈ ៗ

តត្ថ ចីវរធារណេ តាវ បណ្ដាបច្ច័យទាំងបួននោះ សូមអធិប្បាយអំពីការប្រើប្រាស់នូវចីវរបច្ច័យជាមុន ៗ ភិក្ខុស្លៀកដណ្ដប់នូវចីវរ គឺស្បង់, ចីពរ និងសង្ឃាដី បានពិចារណាដោយតង្ខណិកបច្ចវេក្ខណៈឲ្យឃើញថា ចីវរំ អចេតនំ ចីវរដែលអាត្មាស្លៀកដណ្ដប់នេះគ្មានចេត-នាទេ កាយក៏មិនដឹងនូវចីវរ ៗ ក៏មិនដឹងកាយ យថាបច្ចយំ បវត្ត-មានំ ចីវរនេះ ប្រព្រឹត្តទៅដោយសមគួរដល់បច្ច័យ គ្រាន់តែជាធាតុ ឯបុគ្គល គឺអាត្មាអ្នកស្លៀកដណ្ដប់នូវចីវរនេះក៏ជាធាតុដែរ ៗ ភិក្ខុពិចា-

រណាដោយធាតុដូច្នេះហើយស្លៀកដណ្ដប់នូវចីវរ ឈ្មោះថា អ្នកមានគោចរសម្បជញ្ញៈ ។ ភិក្ខុមិនវង្វេង មិនភ្លេចភ្លាំងស្មារតីក្នុងការពិចារណានូវចីវរបច្ច័យដោយធាតុនោះ ឈ្មោះថា អ្នកមានអសម្មោហសម្បជញ្ញៈ ។

ការដែលភិក្ខុពិចារណានូវបិណ្ឌបាត, សេនាសនៈ និងភេសជ្ជៈឲ្យឃើញថាជាធាតុនោះ មានន័យដូចការពិចារណានូវចីវរបច្ច័យដែរ ។

បណ្ដាសម្បជញ្ញៈទាំង ៤ ប្រការ ដូចបានរៀបរាប់មកហើយនោះ អសម្មោហសម្បជញ្ញៈជាធំជាចម្បងជាងសម្បជញ្ញៈ ៣ ប្រការ គឺសាត្ថកសម្បជញ្ញៈ ១ សប្បាយសម្បជញ្ញៈ ១ គោចរសម្បជញ្ញៈ ១ ព្រោះថា បុគ្គលធ្វើកិច្ចការអ្វីៗបើភ្លេចភ្លាំងស្មារតីវង្វេងភាន់ច្រឡំហើយកិច្ចការនោះៗ មុខជាមិនបានសម្រេចប្រយោជន៍ឡើយ នឹងនាំឲ្យកើតទុក្ខទោសដល់ខ្លួន សូម្បីចំរើនព្រះកម្មដ្ឋាន ក៏មិនបានសម្រេចផលតាមចិត្តប្រាថ្នា ។ ហេតុនោះ បានជាលោកពោលថា អសម្មោហសម្បជញ្ញៈជាធំជាងសម្បជញ្ញៈ ៣ ប្រការខាងដើម ។ បើគ្មានអសម្មោហសម្បជញ្ញៈទេ សម្បជញ្ញៈ ៣ ខាងដើមក៏មិនអាចកើតឡើងបាន បើទុកជាកើតមានហើយ ក៏ស្ថិតនៅមិនបាន នឹងសាបសូន្យទៅវិញជាមិនខាន ។

ព្រះយោគាវចរដែលពិចារណានូវធាតុ ១៨ ប្រការនោះ គប្បីតាំងនៅក្នុងសម្បជញ្ញៈទាំងបួន ដូចពោលមកហើយទើបអាចពិចារណាឲ្យឃើញជាក់ច្បាស់បាន ។ ធាតុ ១៨ ប្រការនោះ បើបុគ្គលគ្មានសម្ប-

ផ្ញាៈហើយ មិនអាចពិចារណាឲ្យឃើញថាជារបស់សាបសូន្យឡើយ ត្រឡប់ជាយល់ឃើញថា ចក្ខុធាតុជាដើមជារបស់ខ្លួន ជារបស់ស្ថិតថេរនៅវិញ ។

បុគ្គលដែលមានបារមីចាស់ក្លាបានពិចារណាធាតុ ១៨ ប្រការនោះហើយ អាចសម្រេចមគ្គផលក្នុងបច្ចុប្បន្នជាតិនេះបាន បើបារមីមិនទាន់ចាស់ក្លាទេ ក៏អាចបានសម្បត្តិសួគ៌ដែរ ។ ហេតុនេះ បានជាសម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ធាតុ ១៨ ប្រការចូលក្នុងគម្ពីរយមកៈនេះ ។

XXX

## សច្ចយមកៈ

ចត្តារិ អរិយសច្ចានិ ទុក្ខំ អរិយសច្ចំ ទុក្ខសមុទយោ អរិយសច្ចំ ទុក្ខនិរោធោ អរិយសច្ចំ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចន្តិ ទុក្ខំ ទុក្ខសច្ចំ ទុក្ខសច្ចំ ទុក្ខំ ទុក្ខំ ច ទុក្ខសច្ចំ ទុក្ខសច្ចំ ច ទុក្ខន្តិ អាទិកាំ បុច្ឆិ ។

លំដាប់នេះ សូមវិសជ្ជនាក្នុងសច្ចយមកៈតទៅ ដំណើរសេចក្តីថា សច្ចនសេដ្ឋ សម្តេចព្រះបរមសាស្តាទ្រង់ឃើញច្បាស់នូវអរិយសច្ចទាំងបួនប្រការ ឯកបុគ្គលោ ព្រះអង្គជាបុគ្គលលើសលែងតែមួយអង្គឯងក្នុងត្រៃភព ពុំមានអ្នកណាប្រៀបផ្ទឹមឲ្យស្មើបាន កាលព្រះអង្គសំដែងនូវធាតុយមកៈចប់ហើយ ក្នុងលំដាប់នោះ ព្រះអង្គទ្រង់សំដែង

នូវសច្ចយមកៈតទៅទៀត ។ ឯសច្ចយមកៈនោះ ព្រះពុទ្ធអង្គទ្រង់ទេសនា ដោយចតុករិយសច្ច ត្រាស់បុច្ឆាជាគូ ៗ ហើយត្រាស់វិសជ្ជនាជាគូ ៗ ។

ចត្តារិ អរិយសច្ចានិ អរិយសច្ចបួនប្រការនោះគឺៈ

១– ទុក្ខអរិយសច្ចំ,

២– ទុក្ខសមុទយអរិយសច្ចំ,

៣– ទុក្ខនិរោធអរិយសច្ចំ,

៤– ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចំ ។

កន្ទុក្ខអរិយសច្ច មានព្រះពុទ្ធដីកាត្រាស់ទេសនាបុច្ឆាថា ទុក្ខំ អរិយសច្ចំ ទុក្ខនោះឬឈ្មោះថាទុក្ខសច្ច, ទុក្ខសច្ចនោះឬឈ្មោះថាទុក្ខ ឬថាទុក្ខនោះមិនមែនទុក្ខសច្ច, ទុក្ខសច្ចមិនមែនទុក្ខ ? ។

ត្រាស់បុច្ឆាដូច្នេះហើយ ទើបត្រាស់វិសជ្ជនាដោយព្រះអង្គឯងថា ទុក្ខំ ទុក្ខសច្ចំ ទុក្ខនោះឯងឈ្មោះថាទុក្ខសច្ច, ទុក្ខសច្ចនោះឯងឈ្មោះថាទុក្ខ, ទុក្ខនោះនឹងមិនបានឈ្មោះថាទុក្ខសច្ចក៏មិនមែន, ទុក្ខសច្ចនោះនឹងមិនបានឈ្មោះថាទុក្ខក៏មិនមែន, ទុក្ខនោះឈ្មោះថា ទុក្ខសច្ចដោយពិត, ទុក្ខសច្ចនោះឈ្មោះថាទុក្ខពិត ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានចូលចិត្តថា ព្រះពុទ្ធអង្គត្រាស់ទេសនាបុច្ឆាជាគូ ៗ ត្រាស់វិសជ្ជនាជាគូ ៗ កន្ទុក្ខអរិយសច្ច ដូចម្តេច ព្រះពុទ្ធអង្គត្រាស់ទេសនាបុច្ឆាជាគូ ៗ ត្រាស់វិសជ្ជនាជាគូ ៗ កន្ទុក្ខសមុទយអរិយសច្ច និងទុក្ខនិរោធអរិយសច្ច និងទុក្ខនិរោធគាមិនីបដិ-

បជាអរិយសច្ច ដូច្នោះដែរ ។

ទីនិវេសដ្ឋានៃទុក្ខអរិយសច្ចជាមុន; ទុក្ខំ ពាក្យនេះចែកចេញជាពីរ អក្សរ គឺ ទុ ក ១ ខំ ១; ទុក ប្រែថាអាក្រក់, ខំ ប្រែថាទទេ, ជាគ្មាន, ជាជីក; រួមទាំងពីរសព្ទជា ទុក្ខំ ប្រែថាអាក្រក់ទទេ គឺជាអាក្រក់គ្មានរបស់អ្វីនឹង ការពារបាន ។

ន័យមួយទៀត ទុ ប្រែថា កម្រ, ទុក្ខំ ជាបុគ្គលនឹងជីកបាន ដោយកម្រ ។ ម្យ៉ាងទៀត ទុក្ខំ ប្រែថា កម្របុគ្គលនឹងជីក ចោលចេញឲ្យផុតពីចិត្តសន្តានបាន ។ អរិយសច្ចំ ប្រែថា ជារបស់ ពិតនៃព្រះអរិយ, ព្រោះហេតុព្រះអរិយទាំងឡាយ មានសម្តេចព្រះពុទ្ធ អង្គជាដើម ជាបុគ្គលតាំងនៅក្នុងទីឆ្ងាយចាកកិលេស រមែងត្រាស់ដឹង, ជារបស់ព្រះអរិយនោះ គឺនឹងមិនបានជាទុក្ខ មិនមែនជាទុក្ខពិតណាស់ បើពោលដោយសង្ខេប ទុក្ខនោះមានបួនប្រការ គឺ: ជាតិទុក្ខ ១ ជរាទុក្ខ ១ ព្យាធិទុក្ខ ១ មរណទុក្ខ ១ ។

បើពោលតាមព្រះពុទ្ធដីកាដែលទ្រង់ត្រាស់ទេសនាក្នុងធម្មចក្កប្បវត្ត-នសូត្រថាមានទុក្ខច្រើនប្រការទៀត គឺអប្បិយសម្បយោគទុក្ខ ១ បិយវិប្បយោគទុក្ខ ១ យម្បិច្ឆំនលភតិទុក្ខ ១ សង្ខិត្ត-បញ្ចុបាទានក្ខន្ធទុក្ខ ១ ផ្សំចូលគ្នានឹងទុក្ខទាំងបួនកងមានជាតិ ទុក្ខជាដើម ។ ឯជាតិទុក្ខ, ជរាទុក្ខ, ព្យាធិទុក្ខ នឹងមរណទុក្ខនោះលើក

ទុកចុះ នឹងសំដែងតែក្នុងអប្បិយសម្បយោគទុក្ខជាមុន ។

## អប្បិយសម្បយោគទុក្ខ

អប្បិយសម្បយោគទុក្ខនោះ បានទឹងការដែលប្រកបដោយទុក្ខ ព្រោះហេតុនៅក្នុងទីជាមួយគ្នានឹងសត្វនឹងសង្ខារមិនជាទីស្រឡាញ់ ។ ការនៅជាមួយនឹងសត្វនឹងសង្ខារមិនជាទីស្រឡាញ់នោះ រមែងនាំមកនូវទុក្ខ គឺជានាំឲ្យកើតទុក្ខដែលនឹងប្រែត្រឡប់ឲ្យបានសុខវិញនោះគ្មានទេ នឹងចង្អុលគួយាំងឲ្យឃើញជាក់ ។ ក្នុងបច្ចុប្បន្ន ចំពោះបុគ្គលដែលមានបុត្រព្រមទាំងមាតាបិតាមានបុត្រធីតាក៏ជាជាទីស្រឡាញ់ហើយ ប៉ុន្តែបើបុត្រធីតានោះស្តីថាប្រដៅមិនបាន ក៏នាំឲ្យកើតទុក្ខមិនបានសុខ ។ ឯបុគ្គលដែលនៅរួមជាមួយសត្វនឹងសង្ខារមិនជាទីស្រឡាញ់នោះ ជាពិតក្រៃលែងជាងបុត្រធីតាដែលស្តីថាប្រដៅមិនបានទៅទៀត រេះតែរងទុក្ខរហូតទៅដល់នូវសេចក្តីវិនាសស្លាប់បាត់បង់ជីវិតជាទីបំផុត មានរឿងអតីតនិទានដូចក្នុងចិញ្ចមនៃឃោសកសេដ្ឋី មានសេចក្តីដំណាលថា ៖

សេដ្ឋីនោះ ដើមដំបូងដើរទៅគាល់ព្រះមហាក្សត្រដល់ពាក់កណ្តាលផ្លូវបានជួបនឹងបុរោហិតសួរថា ភោ អាចរិយ បពិត្រលោកអាចារ្យដ៏ចំរើន ! ឥមស្មិំ សិវច្ឆរេ ក្នុងឆ្នាំនេះបុក្សយាមនឹងគិច័ល្អ ឬអាក្រក់ដូចម្តេច លោកអាចារ្យបានគិតារណាមើលដែរឬទេ ? ។

(នៅមានត)

មង្គលភាហាណី

# សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តមក)

---

អធិប្បាយថា សមុទ្រសាគរអាចទ្រទ្រង់នូវទឹកស្ទឹងតូចធំទាំងពួងក្នុងលោកដែលហូរចុះមកប្រជុំមានឧបមាយ៉ាងណា, ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គ អាចទ្រទ្រង់នូវគំនរគុណទាំងឡាយទាំងពួងមានឧបម័យយ៉ាងនោះឯង ។ ផែនដីដ៏ធំធេងនេះ អាចទ្រទ្រង់នូវសត្វថោកទាបនិងសត្វឧត្តមថ្លៃថ្លាទាំងអស់ពុំរើសមុខមានឧបមាយ៉ាងណា ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គអាចទ្រទ្រង់នូវសត្វមានគុណនិងសត្វឥតគុណទាំងឡាយពុំរើសមុខ មានឧបម័យយ៉ាងនោះឯង, ព្រះតថាគតជាម្ចាស់នៃខ្ញុំ ព្រះអង្គមានកាយវាចាចិត្តស្ងប់រម្ងាប់យ៉ាងនេះ ព្រះអង្គជាវីរបុរសឈ្លាសវាងវៃយ៉ាងនេះ ព្រះអង្គមានឥទ្ធានុភាពផ្សេងៗ ទ្រទ្រង់នូវករុណាគុណយ៉ាងនេះ, បុគ្គលឯណាទីមួយក្នុងលោកនេះ ពុំអាចនឹងពោលពណ៌នាគុណព្រះមានព្រះភាគអង្គនោះបានឡើយ ។

កាលបើជនទាំងពីរនាក់នោះ ពោលអួតគុណគ្រូរបស់ខ្លួនទទៃទៃពីគ្នាយ៉ាងនេះហើយ ក៏បណ្តាលកើតឡើងជាជម្លោះឈ្លោះទាស់ទែងយ៉ាងធំ គឺម្នាក់ពោលថា ទេវរូបរបស់យើងប្រសើរវិសេសជាងគ្រូរបស់អ្នក ។ ម្នាក់

ពោលថា ព្រះតថាគតជាម្ចាស់នៃយើង ប្រសើរវិសេសជាងទេវរូបរបស់អ្នក ម្ល៉ោះហើយជនទាំងពីរនាក់ពុំសុខចិត្តនឹងគ្នាទៅវិញទៅមក ហើយនាំគ្នាចូលទៅគាល់ព្រះបរមក្សត្រក្រាបបង្គំទូលតាមដំណើរនោះថា សូមព្រះអង្គទ្រង់វិនិច្ឆ័យតាមយុត្តិធម៌ឲ្យទាន ៗ ព្រះបរមក្សត្រលុះទ្រង់ព្រះសណ្ដាប់ពាក្យជនទាំងពីរនាក់នោះហើយ ទ្រង់ត្រាស់ថា បើដូច្នោះយើងទាំងឡាយ នឹងបានដឹងនូវអានុភាពនៃគុណរបស់ទេវតានឹងគុណព្រះសម្មាសម្ពុទ្ធរបស់អ្នកទាំងឡាយថា ប្រសើរនឹងមិនប្រសើរ ដោយឥទ្ធិបាដិហារ្យទាំងឡាយឥឡូវនេះឯង លុះព្រះអង្គមានព្រះរាជឱង្ការយ៉ាងនេះហើយ ក៏ត្រាស់បង្គាប់សេវកាមាត្យទាំងឡាយ ឲ្យវាយស្គរជ័យផ្សាយទៅក្នុងនគរទាំងអស់ថា: អនាគតកាលតទៅមុខ ៧ ថ្ងៃទៀត នឹងមានបាដិហារ្យទាំងឡាយរបស់ព្រះសាស្ដាទាំងពីរព្រះអង្គនេះ នឹងកើតប្រាកដដោយពិត ដូច្នេះមហាជនទាំងឡាយត្រូវបបួលគ្នាចូលមកប្រជុំចាំមើលចុះ ៗ រីឯមហាជនទាំងឡាយដែលនៅក្នុងទិសផ្សេង ៗ បានស្ដាប់ដំណឹងនោះហើយ ក៏កើតជាកោលាហលគឹកកងជ្រួលជ្រើម ច្រើនក្រៃពេក សឹងចូលមកប្រជុំគ្នាតាមកាលកំណត់នោះហោង ៗ

កាលនោះ ពួកមនុស្សអ្នកមិច្ឆាទិដ្ឋិបានគិតថា ថ្ងៃនេះពួកយើងនឹងបានឃើញនូវអានុភាពនៃទេវរូបរបស់យើងដោយពិត លុះគិតដូច្នេះហើយ ក៏ធ្វើសក្ការបូជាយ៉ាងធំដល់ឥស្សរទេវរូបនោះឯង ៗ

ចំណែកឯពួកមនុស្សអ្នកសម្មាទិដ្ឋិក៏បានគិតថា ថ្ងៃនេះយើងទាំងឡាយនឹងបានឃើញនូវអានុភាពព្រះមានព្រះភាគរបស់យើងដោយពិត លុះគិតយ៉ាងនេះហើយ ក៏នាំគ្នាចូលទៅកាន់ទីប្រតិស្ឋានពាលុកចេតិយ ដែលបញ្ចុះព្រះបាទចេតិយធាតុ (ទ្រនាប់ព្រះបាទ) ព្រះមានព្រះភាគ ហើយធ្វើសក្ការបូជាដោយគ្រឿងបូជាទាំងឡាយមានផ្កាកម្រងជាដើម ស្រេចហើយដើរប្រទក្សិណបីជុំ លើកដៃឡើងប្រណម្យថ្វាយបង្គំ ស្ថិតនៅកន្ទីនោះឯង ។

លំដាប់នោះ ព្រះនរិន្ទ្រាធិបតីបរមក្សត្រ ព្រមទាំងពលពាហនៈនឹងសេវកាមាត្យជាច្រើនហោមហែមជាបរិវារ ដង្ហែស្ដេចយាងទៅកាន់ទីប្រជុំនោះ ហើយទ្រង់ប្រថាប់នៅកន្ទីដ៏សមគួរមួយ ។

ចំណែកមនុស្សទាំងឡាយដែលប្រកាន់លទ្ធិផ្សេង ៗ បានគិតថាថ្ងៃនេះ យើងនឹងបានឃើញនូវបាដិហារ្យនៃបុគ្គលមានឫទ្ធិទាំងឡាយនោះដោយពិត លុះគិតយ៉ាងនេះហើយ ក៏បបួលគ្នាគឹកកងចូលទៅកាន់ទីប្រជុំនោះហើយតាក់តែងចងគ្រែតូចជំរួតលើគ្រែធំ អង្គុយប្រជុំចាំមើលកន្ទីនោះហោង ។

កាលបើមហាជនទាំងឡាយនោះបានប្រជុំគ្នាយ៉ាងនេះស្រេចហើយពួកមនុស្សដែលជាសម្មាទិដ្ឋិក៏ធ្វើកិរិយាបូជាយ៉ាងអធិកអធម នូវព្រះសថូបពាលុកចេតិយ ហើយលើកឡើងនូវក្រពុំម្រាមទាំង ១០ នមស្ការពោលថា៖ បពិត្រព្រះមានព្រះភាគជាម្ចាស់ សូមព្រះអង្គជាទីពឹងចំពោះខ្ញុំព្រះ

អង្គទាំងឡាយក្នុងកាលឥឡូវនេះ, លុះកាលយ៉ាងនេះហើយ ក៏ធ្វើសច្ច-
កិរិយាព្រមគ្នាសូត្រនូវបទព្រះគាថាដូច្នេះថា:

អាចាណា កោដិ ពុទ្ធស្ស សរណំ គោ គតំ យទិ
តេន សច្ចេន យំ ធាតុ ឧស្សេតុ ចាដិហារិយំ ជាដើម

អធិប្បាយថា ខ្ញុំព្រះអង្គទាំងឡាយជាសត្វមាននៅជាន់ក្រោយនេះ បាន
ដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកហើយ, ប្រសិនបើព្រះធាតុឯណាមាននៅ
មែន សូមព្រះធាតុនោះ សំដែងនូវព្រះបាដិហារ្យជាទីអស្ចារ្យដល់ខ្ញុំព្រះ
អង្គទាំងឡាយ ដោយពាក្យសច្ចនោះឯង ។ បពិត្រព្រះអង្គជាធំជាងអ្នក
ប្រាជ្ញ កាលព្រះអង្គបានកើតជាកូតកមរជកុមារជាបុត្រានៃព្រះបាទទសរថ
បានធ្វើនូវព្រះបាទុកៈ គឺស្បែកព្រះបាទស្មៅឲ្យប៉ះទង្គិចគ្នាហើយ សម្តែង
បាដិហារ្យអណ្តែតឡើងក្នុងអាកាសគួរជាទីអស្ចារ្យ ប្រសិនបើព្រះធាតុ
ណាមាននៅមែន សូមព្រះធាតុនោះសម្តែងនូវព្រះបាដិហារ្យជាទីអស្ចារ្យ
ដល់ខ្ញុំព្រះអង្គទាំងឡាយ ដោយពាក្យសច្ចនោះឯង ។ កាលដែលព្រះ
អង្គកើតជាដំរី ឈ្មោះឆទ្ទន្តៈ មានរស្មីទាំងប្រាំមួយពណ៌ផ្សាយចេញអំពី
ភ្លុកទាំងគូគួរជាទីអស្ចារ្យ ប្រសិនបើព្រះធាតុណាមាននៅមែន សូមព្រះ
ធាតុនោះ បញ្ចេញនូវរស្មីទាំង ៦ ពណ៌ ដល់ខ្ញុំព្រះអង្គទាំងឡាយដោយ
ពាក្យសច្ចនោះឯង ។ កាលដែលព្រះអង្គទើបនឹងប្រសូតចាកផ្ទៃ
នៃព្រះមាតានាបច្ឆិមជាតិនេះ មុនត្រាស់ដឹងពោធិញាណ ទ្រង់បាន

សម្ដែងបាដិហារ្យឈរលើផ្កាឈូកមាស បញ្ចេញនូវព្រះរំពាជាសប្បុរស ថា អគ្គោហមស្មិ លោកស្ស សេដ្ឋោហមស្មិ ប៉ុណ្ណោះជាដើម គួរជាទីអស្ចារ្យ ប្រសិនបើព្រះជាគុណាមានទៅ សូមព្រះជាគុនោះសម្ដែងនូវព្រះបាដិហារ្យជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គទាំងឡាយ ដោយពាក្យសច្ចនោះឯង ៗ កាលព្រះអង្គទ្រង់ទតឃើញនូវទេវទូតទាំងបួនដែលសុទ្ធាវាសព្រហ្មកនិមិត្តថ្វាយ លុះឃើញហើយក៏មានព្រះទ័យនឿយណាយចាកវត្ថុសង្សារចេញទៅទ្រង់ព្រះផ្នួសកសាងទុក្ករកិរិយាគួរជាទីអស្ចារ្យ ប្រសិនបើព្រះជាគុណាមានទៅមែន សូមព្រះជាគុនោះសម្ដែងនូវព្រះបាដិហារ្យជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គទាំងឡាយ ដោយពាក្យសច្ចនោះឯង ៗ កាលព្រះអង្គទ្រង់សម្ដែងព្រះបាដិហារ្យផ្ចាញ់នន្ទោបនន្ទពជក្ដី ផ្ចាញ់ដំរីនាឡាគិរីដ៏ប្រសើរក្ដី ផ្ចាញ់ពួកយក្សមានអាឡវយក្សជាដើមក្ដី ផ្ចាញ់ពួកព្រហ្មមានពកាមហាព្រហ្មជាដើមក្ដី ផ្ចាញ់ពួកនិគ្រន្ថមានសច្ចកនិគ្រន្ថជាដើមក្ដី ផ្ចាញ់ពួកព្រាហ្មណ៍មានកុដទន្តព្រាហ្មណ៍ជាដើមក្ដី ដោយឫទ្ធិគួរជាទីអស្ចារ្យ ប្រសិនបើព្រះជាគុណាមានទៅមែន សូមព្រះជាគុនោះសម្ដែងនូវព្រះបាដិហារ្យជាទីអស្ចារ្យដល់ខ្ញុំព្រះអង្គទាំងឡាយដោយពាក្យសច្ចនោះឯង ៗ

លុះមនុស្សទាំងឡាយជាសម្មាទិដ្ឋិ បានពោលពាក្យជាបទគាថាដ៏ច្រើនយ៉ាងនេះហើយក៏ពោលអាកធនាថា: បពិត្រព្រះជាគុជាម្ចាស់ សូមព្រះអង្គតាំងព្រះទ័យអនុគ្រោះដល់ខ្ញុំព្រះអង្គទាំងឡាយ សម្ដែងនូវព្រះបាដិហារ្យ

ជាទីអស្ចារ្យដល់មហាជន ដើម្បីបំបែកទំលាយជនមិច្ឆាទិដ្ឋិដែលមានទិដ្ឋិខុសឲ្យប្រែត្រឡប់បានឃើញត្រូវវិញក្នុងកាលនេះហោង ។ កាលនោះព្រះបាទបិដ្ឋធាតុបានអាស្រ័យនូវពុទ្ធានុភាពផង អាស្រ័យនូវសច្ចកិរិយានុភាពនៃពុទ្ធបរិស័ទទាំងឡាយផង ក៏បានទំលាយនូវព្រះពាលុកចេតិយឲ្យបែកធ្លាយជាពីរចំណែក ហើយចេញមកខាងក្រៅធ្វើបាដិហារ្យហោះអណ្តែតឡើងទៅស្ថិតនៅឰដ៏អាកាសបញ្ចេញនូវរស្មីទាំងប្រាំមួយពណ៌ភ្លឺប្រភាត់ផ្សាយទៅកាន់ទិសនានាជាទីអស្ចារ្យពន់ពេកក្នុងកាលនោះឯង ។ លំដាប់នោះឯង មហាជនទាំងឡាយក៏មានសេចក្តីសោមនស្សជ្រះថ្លាបានលើកឡើងនូវទង់សំពត់ប្រមាណមួយពាន់បូជា ទាំងកំសាន្តល្បែងសាធុការញុំាងសំឡេងឲ្យលាន់ឮខ្ទាំងឲ្យប្រព្រឹត្តទៅពុំដាច់ ធ្វើកិរិយាបូជាយ៉ាងធំក្រៃលែងក្នុងកាលនោះឯង ។

ចំណែកឯពួកជនជាមិច្ឆាទិដ្ឋិ លុះបានឃើញនូវព្រះបាដិហារ្យជាទីអស្ចារ្យយ៉ាងនេះ ក៏មានចិត្តស្ញើមលះបង់មិច្ឆាទិដ្ឋិដែលខ្លួនចូលចិត្តខុសប្រកាន់ខុសជាជ្រះស្រឡះ ហើយបានដល់នូវគុណព្រះរតនត្រ័យដ៏ឧត្តមជាទីពឹងទីរលឹកប្រព្រឹត្តទៅខាងមុខ មានសទ្ធាមិនករម្រើក លែងបូជារាប់អានឥស្សរទេវតាអ្នកតាអារក្សទេព្រក្សតទៅទៀតឡើយ ។

(នៅមានត)

មហោសថជាតក

លោក អ៊ឹម-កង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស គឹម-ទូរ ពិនិត្យ

(តមក)

សេកសុវបណ្ឌិតគិតហើយ ក៏ហើរទៅក្នុងឧទ្យាននោះ ទំពួនឰដមែកឈើសាលព្រឹក្ស ; រីឯព្រះបាទចុលនីថា ម្នាលអាចារ្យ ! ចូរអ្នកថ្លែងទៅមើល?! រាជគ្រូកេវដ្ដព្រាហ្មណ៍ថា បពិត្រមហារាជ, សូមព្រះអង្គផ្ទៀងព្រះសោត្រអម្ចាស់នោះមកឯនេះហោង, គំនិតនេះមានត្រចៀក៤, បពិត្រមហារាជ, ថាបើព្រះអង្គធ្វើតាមពាក្យអញខ្ញុំ អញខ្ញុំនឹងរណ្ដាប់តាក់តែងមហារាជឲ្យជាស្ដេចប្រសើរលើសក្រៃ ឰដ៏សកលជម្ពូទ្វីបនេះហោង ។ ព្រះបាទចុលនីស្ដាប់ពាក្យរាជគ្រូដូច្នោះហើយ ហេតុតែព្រះចំណង់ខ្លាំង ស្ដេចមានព្រះហឫទ័យត្រេកអរសោមនស្សត្រាស់ថា ម្នាលអាចារ្យអើយ! នាពាក្យអាចារ្យសំដែងថ្លែងនោះ អញនឹងធ្វើតាមពាក្យអាចារ្យហោង ។ រាជគ្រូថា បពិត្រមហារាជ, យើងខ្ញុំនឹងប្រជុំពលសេនាយោធាមកជុំហើយ យើងខ្ញុំទៅចោមរោមនគរតូចជាដើម ហើយអញខ្ញុំចូលទៅក្នុងនគរនោះតាមទ្វារតូច ហើយអញខ្ញុំស្រដីនឹងស្ដេចនគរនោះថា បពិត្រមហារាជ, អម្ចាស់ចុះចូលជាទ្រព្យសំរាប់យើងទាំងពួងហើយ រីឯមហារាជនឹងច្បាំងគតអគ្គិមានឡើយ, ហើយសម្រេចសម្បត្តិមហារាជក៏គង់នៅដូចដើម ៗ

មួយលោក បើមហារាជទ្រង់នឹងយើងដ៏មានកំឡាំងដ៏វិសេសៈរទេះច្រើន ដូច្នោះ ក៏មហារាជនឹងចាញ់ទៀតក្តាត់មិនទេឡើយ ថាបើស្តេចនោះ តាមដោយពាក្យអញខ្ញុំដូច្នោះហើយ ក៏អញខ្ញុំនឹងប្រមូលស្តេចនោះប្រពៃហោង, ពោះបើថេមិនតាមដោយពាក្យអញខ្ញុំហើយ ក៏យើងនឹងច្បាំងឲ្យស្តេចនោះក្ស័យជីវិត ហើយយើងយកអស់សេនាពលចេញទៅកាន់នគរទៀតបានហោង, ហើយទៅនគរឯទៀតធ្វើពិធីដដែលនេះ, ហើយយើងយករាជសម្បត្តិទាំងសកលជម្ពូទ្វីបនោះទៀត, យើងធ្វើឧបាយកលដូច្នេះស្រេចហើយ យើងផឹកស្រាជ័យបានហោង ។ កាលយើងនឹងផឹកស្រាជ័យបាននោះ យើងឲ្យយកស្តេចមួយរយនឹងមួយមកជុំគ្នានានគរយើងនេះ ហើយឲ្យផឹកស្រាជ័យដាក់នូវថ្នាំពិសពុលដ៏ឧឡារ, អ្នកទាំងពួងនោះលុះក្ស័យជីវិតហើយ យកខ្មោចនោះបោះក្នុងទឹកហោង យើងធ្វើរាជសម្បត្តិអស់រាជធានីមួយរយនឹងមួយនេះ ឲ្យលុះក្នុងកណ្តាប់ដៃនៃអម្ចាស់ជាស្តេចប្រសើរថ្ងៃត្រង់ជម្ពូទ្វីបនេះ នូវប្រការដូច្នេះហោង ។ ព្រះបាទចុលនីព្រហ្មទត្តរាជបន្ទូលថា គាប់ហោង អាចារ្យអើយ! អញធ្វើដូចពាក្យអាចារ្យហោង ។ រាជគ្រូថា បពិត្រមហារាជ, នាហៅតំរិះតែត្រចៀក ៤ នេះ អ្នកដទៃអង្គមានគំរិះនេះ មិនអាចដើម្បីនឹងឲ្យអ្នកដទៃដឹងឡើយ ហេតុនោះ ព្រះបាទអម្ចាស់ធ្វើកុំឲ្យយូរឡើយ ព្រះបាទអម្ចាស់ចេញទៅឆាប់ហោង ។ ព្រះបាទចុលនីព្រហ្មទត្តរាជ ស្តាប់ពាក្យរាជគ្រូ

នោះហើយមានព្រះហឫទ័យត្រេកអរទទួលថា តាប់ហោង ៗ ឯសេកសុរ-
បណ្ឌិតពិនិត្យស្ដាប់សព្ទសេចក្ដីអ្នកទាំង ២ នោះហើយ ក៏សំយុងកចុះដូច
ទីងញាក់អំពីមែកលផ្នែកសាលព្រឹក្ស ហើយលុះសម្រេចគំនិតនៃអ្នកទាំង ២
នោះហើយ សេកក៏ទម្លាក់អាចម៍១ដុំមកលើក្បាលអាចារ្យកេវដ្តព្រាហ្មណ៍,
អាចារ្យកេវដ្តព្រាហ្មណ៍ផាសចេញពីក្បាលហើយថា អេះ! សត្វអ្វីដូច្នេះ,
អេះ! ម៉្លេះហើយសេកទម្លាក់នូវអាចម៍ ១ ដុំវិញទៀត ក្នុងមាត់អាចារ្យ
កេវដ្តព្រាហ្មណ៍ដែលងើយមើលនោះ, វស្សព្ណោ សឹងស្រែក, គាំរ៉
គាំរ៉ ឥតិ ថា ក្រេក ៗ ដូច្នេះ ហើយហើរទៅអំពីមែកសាលព្រឹក្ស ហើយ
ព្រះបាទចុលនីស្រដីទីងអាចារ្យកេវដ្តព្រាហ្មណ៍ថា នែអាចារ្យអើយ!
រីគំនិតព្រះស្ដែងគិតថា នែអញទីងព្រះស្ដែងឯងជាត្រចៀក ៤, ឥឡូវនេះ
កើតជាត្រចៀក ៦ ហើយ, អដ្ឋក្កណ្ណោ កើតជាត្រចៀក ៨ វិញ,
អនេកសតក្កណ្ណោ ជាត្រចៀកច្រើនរយក្រៃលែងវិញហោង ៗ
លំដាប់នោះ; សេកហើរទៅដោយផ្លូវទៅកាន់មិថិលានគរ ហើយស្រែក
ថាដូច្នេះ គណ្ហថ ៗ ថា អ្នកទាំងឡាយអើយ! ចូរទៅកាន់លំនៅចៅ
មហោសថអ្នកប្រាជ្ញឲ្យឆាប់ ហើយនាំពត៌មានសេកសោមបណ្ឌិតនោះ
ថាបើមកអំពីឯណា ១ ក៏គប្បីប្រាប់ចៅមហោសថនោះឯងហោង; លំដាប់
នោះ, សេកចុះទំព្វង់ស្លាទៃពោធិសត្វនោះ ថាបើគួរបើប្រាប់នាងអមក
ដើម្បីនឹងឲ្យនាងស្ដាប់នូវពត៌មាននោះ ក៏មកចុះលើចង្កេះ ថាបើចង់ឲ្យ

មហាជនជន៍ស្តាប់ ក៏ចុះលើភូមិដ៏ហោង ៗ រីឯសេកសុវណ្ណិតក៏ចុះមក ពុំស្មាពៅមហោសថអ្នកប្រាជ្ញ ៗ ឯពួកមហាជនទាំងឡាយ ឲ្យថយ ចេញហើយថាដូច្នេះ គប្បីនឹងចង់ជំនិនូវអាថ៌សេចក្តីកំបាំងដោយសំគាល់ នោះហើយ ៗ ពៅមហោសថអ្នកប្រាជ្ញ យកនូវសេកសុវណ្ណិតឡើង. លើប្រាសាទ ហើយអ្នកជណ្ដឹងដូច្នេះថា តាត វៃហសេកអើយ ! តើ បាយល់.ឮអ្វី ? ៗ ក្នុងណានោះ, សេកនិយាយនឹងមហោសថអ្នកប្រាជ្ញ ដូច្នេះថា បពិត្រអម្ចាស់អើយ ! អញខ្ញុំមិនយល់នូវទុក្ខភ័យពុំសំណាក់ ស្តេចដៃទកនិកំឡុងសកលជម្ពូទីបនោះឡើយ; ប៉ុន្តែកាលនោះ, មានបុរោ-ហិតម្នាក់របស់ព្រះបាទចុលនីព្រហ្មទត្តកជ ជាព្រាហ្មណ៍ឈ្មោះកេវដ្ដ នៅ ពុំទុក្ខបញ្ចាលនគរមិញ នាំស្តេចទៅកាន់ឧទ្យាននោះ ហើយក៏កាន់យក នូវគំនិតគ្រឿង ៤ ពុំព្រៃ, អញខ្ញុំសោត ចុះទៅពុំលផ្ទៃមែកសាល-ព្រឹក្ស អញខ្ញុំបានទម្នាក់នូវអាថ៌ ១ ដុំមកក្នុងមាត់អាចារ្យកេវដ្ដព្រាហ្មណ៍ ហើយអញខ្ញុំហើរមកហោង ៗ សេកនិយាយប្រាប់អស់អាថ៌ សេចក្តីទាំងពួងដោយប្រការអម្បាលនោះហើយ ក៏យល់ឮទៅដល់ពៅ មហោសថអ្នកប្រាជ្ញនាពាក្យពៅមហោសថស្រដីថា រីពាក្យនោះតើស្តេច ញាំងទទួលយកឬទេ? សេកថា ទេ? បពិត្រអម្ចាស់អើយ ! ស្តេចទទួល យកហោង ៗ មហោសថធ្វើសក្ការដល់សេកនោះ ឲ្យដេកលើកំពល ជិទទន់ល្មុនក្នុងគ្រង់មាស, ពោធិសត្វរំពឹងគិតថា នគរនេះនោះ ដូចអញ

គិតនេះ វីអាចារ្យកេវដ្ឋព្រាហ្មណ៍នេះ មិនដឹងនូវសភាពនៃអញជាមហោ-សថអ្នកប្រាជ្ញ មានប្រាជ្ញាយល់សារពើឥតបើខ្វះ, ហើយពោធិសត្វអ្នករំពឹងគិតថា ឥឡូវនេះ គំនិតស្រដីទាំង ២ អញមិនឲ្យលុះបរិបូណ៌ឡើយ, វីត្រកូលខ្សត់នៅឆ្ងាយអំពីនគរព្រះមហាក្សត្រ ឲ្យលើកចូលមកនៅក្រៅព្រះនគរ, ត្រកូលមានទ្រព្យសម្បត្តិជាអ្នកមានយសស័ក្តិនៅនាស្រុកឋាននិគមជនបទនោះ ឲ្យនាំមកណ្តាប់នូវទ្រព្យស្រូវអង្ករផងច្រើន សំថែទុកឲ្យច្រើនក្នុងព្រះនគរនោះហោង ។

ចុលនីព្រហ្មទត្តោបិ ឯស្តេចចុលនីព្រហ្មទត្តរាជ យកនូវពាក្យអាចារ្យកេវដ្ឋព្រាហ្មណ៍នោះហើយ ស្តេចនោះទៅនឹងសេនាយោធាផងទាំងឡាយជាបរិវារក៏ទៅតាមភេមនគរតូច ១ ៗ ឯអាចារ្យកេវដ្ឋព្រាហ្មណ៍ក៏ចូលទៅកាន់នគរនោះ ដោយនូវន័យគំនិតដែលថានោះហោង, ហើយប្រាប់ឲ្យជាដំណឹងដល់ស្តេចនោះ ធ្វើឲ្យមកកាន់សំ-ណាក់អាត្មា ជាមួយនឹងសេនាពីរនឹងចាប់យកនូវស្តេចឯទៀតដូច្នោះក៏នឹងចាប់យកអស់ស្តេចទាំងពួង ដោយនូវលំដាប់រៀងទៅហោង ។

ឃរិ ចុលនីព្រហ្មទត្តោ វីព្រះបាទចុលនីព្រហ្មទត្តរាជ បិតដោយនូវពាក្យអាចារ្យកេវដ្ឋព្រាហ្មណ៍ នូវប្រការអម្បាលនោះហើយលើកទុកតែស្តេចវិទេហរាជជាសំណល់ ក៏ធ្វើអស់ស្តេចទាំងសកលជម្ពូ-ទ្វីប ឲ្យបានមកសំណាក់នៃអាត្មាហើយ វីបុរសនុបនិក្ខិត្តរបស់ពោធិ-

សត្វមិញ សឹងប្រើពតិមានមកកាន់ពោធិសត្វពុំដាច់ដូច្នេះថា ព្រះបាទចុលនីព្រហ្មទត្តរាជ គេចាប់បាននគរទាំងឡាយអម្បាលនោះហើយ កុំប៉ះម្ចាស់ប្រហែសឡើយ ។ បណ្ឌិតោបិ បពិត្រអើយ ! រីពោធិសត្វអ្នកប្រាជ្ញប្រើពតិមានទៅវិញ នាបុរសដែលមកព្រមាននោះដូច្នេះថា តុម្ហេ រីព្រះស្តែង វសថ ចូរទៅនៅនោះ កុំប៉ះក្រសាលប្រហែសភ្លេចស្មារតីឡើយ រីអញនៅនាឋាននេះមិនប្រហែសឡើយ ។ ឯព្រះបាទចុលនីព្រហ្មទត្តរាជ រៀនទុកដំកល់តែសម្បត្តិព្រះបាទវិទេហរាជចេញ ជាសំណល់បាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ក៏ខឹងចាប់យកអស់ស្តេចសកលជម្ពូទ្វីបនោះបានងាយក្តាត់ហោង, ស្តេចចុលនីព្រហ្មទត្តរាជបន្ទូលនឹងអាចារ្យកេវដ្តព្រាហ្មណ៍ដូច្នេះថា អាចារ្យ ហៃអាចារ្យអើយ ! យើងនឹងទៅចាប់យករាជសម្បត្តិព្រះបាទវិទេហរាជ នៅឰដ៏មិថិលានគរនោះហោង ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា មហារាជ បពិត្រមហារាជអើយ ! រីចៅមហោសថនៅនានគរនោះ យើងពុំអាចដើម្បីនឹងទៅយករាជសម្បត្តិគេនោះបានឡើយ. អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា ចៅមហោសថប្រកបនូវព្រះប្រាជ្ញាជាអ្នកឈ្លាសនូវកលឧបាយ នឹងពាយស្រាយនោះឥតឯខ្លះឡើយ ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលឃាត់ព្រះបាទចុលនីព្រហ្មទត្តរាជនូវប្រការអម្បាលនោះហើយ ក៏ថ្លែងសរសើរនូវគុណមហោសថនោះបរិបូណ៌ ដូចកលមណ្ឌលព្រះចន្ទប្រាសលែងមន្ទិល

ពពក នឹងគេបាត់ស្មើនោះគ្នានឡើយ ហើយចៅមហោសថអ្នកប្រាជ្ញនេះ
សូម្បីគាត់ចេះនូវឧបាយកលយល់ឆ្ងាយផងហើយនោះហោង, រីយើង
ទាំងមួយរយនេះ នាបើហៅរាជសម្បត្តិមិថិលានគរនោះយើងនឹងទៅយក
ពុំបានឡើយ ហើយស្ដេចទាំងសកលជម្ពូទ្វីបនោះ គេនឹងមើលងាយ
អម្ចាស់ នូវអញខ្ញុំហោង ។ អាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា នាបី
យើងនឹងសម្លាប់ស្ដេចទាំងនោះនូវប្រការម្ដេចអេះ! អាចារ្យកេវដ្ដព្រាហ្មណ៍
សំគាល់នូវឧបាយកលមួយថា នាយើងនឹងទៅយករាជសម្បត្តិឯមិថិលា
នគរ សូម្បីអស់ស្ដេចទាំងអម្បាលនោះ យើងនឹងបរើផឹកស្រាជ័យ
បានហើយ ក៏សូម្បីនឹងឃាត់ស្ដេចទាំងនោះថា ឱ បពិត្រមហារាជអើយ!
យើងនឹងយកសម្បត្តិស្ដេចវិទេហរាជនោះ យើងនឹងគាលធ្វើអ្វីឡើយ រី
រាជសម្បត្តិស្ដេចវិទេហរាជនោះ សឹងជាទ្រព្យសំរាប់យើង ហើយ
អញ្ជើញក្រឡាប់មកស្ទេះនៅនេះសិនហោង ។ អាចារ្យកេវដ្ដព្រាហ្មណ៍
គៀនអស់ស្ដេចទាំងអម្បាលនោះ ដោយនូវឧបាយកលយល់ហើយ,
ស្ដេចទាំងអម្បាលនោះស្ដាប់ពាក្យអាចារ្យនោះហើយ ក៏ក្រឡាប់វិលទៅ
ហោង ។ រីបុរសជាឧបនិក្ខិត្តរបស់ព្រះមហោសថវិញ ប្រើពត៌មាន
មកវិញទៀតថា រីស្ដេចចុលនីព្រហ្មទត្តរាជ ស្ដេចនឹងមកនាមិថិលានគរ នូវ
ស្ដេចមួយរយនឹងមួយជាបរិវារ តែបានអាចារ្យកេវដ្ដព្រាហ្មណ៍ឃាត់
ស្ដេច ក៏ស្ដេចវិលក្រឡាប់ទៅកាន់ព្រះនគរស្ដេចវិញហោង ។ មហា-

សត្តោបំ គេសំ គគោ បញ្ញាយ គស្ស ករិយំ ជា

ឆន្ទតិ បតិសាសរំ បេសេតិ ។ រីពោធិសត្វប្រើពតិមាន

គបរិញ ទៅដល់បុរសមកព្រមាននោះដូច្នេះថា ចាប់ដើមអំពីនេះទៅ

ចូរព្រះស្តេចប្រើមកឲ្យបានដឹងនូវអំពើស្តេចនោះហោង ។ រីស្តេច

ចុលនីព្រហ្មទត្តកជស្រដីមួយអន្ទើនឹងអាចារ្យកេវដ្តព្រាហ្មណ៍ថា ឥឡូវ

នេះ យើងនឹងធ្វើម្តេច ? ។ អាចារ្យកេវដ្តព្រាហ្មណ៍ទូលថា យើងបំ-

ផឹកស្រាជ័យបាន នាបុរសអាមាត្យផងទាំងឡាយ ឲ្យប្រដាប់សំកប់នូវ

ទព្វាននោះស្រេចហើយ ចូរអណ្តាប់ដំកល់ទុកនូវស្រាបានមួយរយឆ្នាក់

មួយពាន់ឆ្នាក់ ហើយចូរនាំមកនូវបាយដំណើប នូវត្រីសាច់ផងទាំង

ឡាយជាដើមនោះ មានដំពូកផ្សេង ៗ ស្រេចហើយ បង្គាប់ប្រើអា-

មាត្យ ។ ឮដំណាលនោះរីបុរសទបនិក្ខិត្តនៃពោធិសត្វ ប្រើនាំពតិមាន

នោះមកកាន់ទៅមហោសថផ្តាំដូច្នេះថា មួយទីសោត រីស្តេចចុលនី-

ព្រហ្មទត្តកជនោះ ផ្សំថ្នាំពិសនឹងស្រា មានចំណង់ចង់សម្លាប់ស្តេចទាំង

ឡាយមិនដឹងខ្លួនឡើយ ។ មួយទីសោត, ព្រះមហាសត្វនឹងដឹងពតិមានអំពី

សេកសុវបណ្ឌិតតែងទៅសំណាក់បុរសនោះ ហើយមហោសថនឹងចង់

ដឹងស្តេចនោះ ថ្ងៃណានឹងទៅផឹកស្រាជ័យ, ផ្តាំដូច្នោះហើយ ប្រើ

ឲ្យនាំពតិមានឲ្យទៅអាមាត្យប្រើមកព្រមាននោះ ។ តេ តថា ករឹ-

សុ រីអាមាត្យនោះ ធ្វើឮដំណាននោះហើយ, ក៏ពោធិសត្វអង្គពិនិត្យថា

ពួកប្រាជ្ញទាំងឡាយមិនគួរធ្វើនូវអញនេះឡើយ, មួយទៀតសោត ស្ដេច ទាំងគម្ពលនេះ ក៏នឹងឲ្យស្លាប់ដរតែស្ដេចទាំងឡាយនោះ ស្លាប់ ឥតសង្ស័យឡើយ, ព្រះមហាសត្វអ្នកឲ្យហៅយោធាមួយពាន់ដែលកើត ព្រមថ្ងៃមួយនឹងពោធិសត្វនោះមកផ្ដាំនូវពាក្យដូច្នេះថា ម្នាលគ្នាយើង អើយ! ព្រះបាទចុលនីព្រហ្មទត្តរាជនោះ ដូចយើងបានឮមក គាត់ថា នឹងចង់ទៅកាន់ព្រៃឧទ្យានឋានស្នាក់ ហើយគាត់នឹងប្រដាប់មានចំណាន់ បំផឹកស្រាជ័យ មានស្ដេចមួយរយនឹងមួយជាបរិវារ អ្នកចូលទៅ ឋាននោះ កុំឲ្យស្ដេចទាំងឡាយដឹងខ្លួន ចូរប្រដាប់កំពលអាសនាស្ដេច ទាំងឡាយនោះទីទៃ ៗ ហោង; តែអាសនាស្ដេចចុលនីព្រហ្មទត្តរាជនោះ នាលផ្ទៃឋានកណ្ដាល ហើយចូរអ្នកទាំងឡាយដណ្ដើមយកអាសនានោះ អ្នកទាំងឡាយត្រូវស្រដីថា នេះអាសនាស្ដេចយើង នេះអាសនា អម្ចាស់យើង ម្ល៉ោះហើយបុរសទាំងឡាយនោះគេថានឹងអ្នកទាំងឡាយ ដូច្នេះ នេះបុរសអាមាត្យស្ដេចឯណាហ្ន៎: គ្នាយើងទាំងឡាយ ចូរថា ដូច្នេះ យើងនេះជាអាមាត្យនៃព្រះបាទវិទេហរាជ អស់គេទាំងនោះ គេនឹងស្រដីមួយអន្ទើនឹងគ្នាយើងទាំងឡាយគេនឹងថាដូច្នេះ យើងចាប់ យករាជសម្បត្តិស្ដេចទាំងឡាយនោះ តែប្រាំពីរឆ្នាំ អធិកនូវ ៧ ខែ, ៧ ថ្ងៃទេ, យើងមើលមកប្រមាណឯស្ដេចវិទេហរាជនេះ សូម្បីយើងនឹង ចាប់តែមួយថ្ងៃហោង; ថាដូច្នោះហើយ ខ្ញាចខ្ញីនឹងព្រះបាទវិទេហរាជ

នោះហ៎ះ ! ចូរព្រះស្តែងទៅកំពៅអេះ យកអាសនាមួយអង្គុយទីនគ្នាទាំងឡាយហោង ហើយចូរអ្នកទាំងឡាយធ្វើដំណោះឈ្មោះប្រកែកជជែកពាក្យនឹងស្តេចយើងថា វៀរតែស្តេចចុលនីព្រហ្មទត្តកជឯងចេញនឹងមានស្តេចដទៃឯណាក្រៅលែងជាងនោះឥតអង្គីមានឡើយ ហើយសូម្បីមា-ត្រាអាសនានៃស្តេចយើង អ្នកទាំងឡាយមិនឲ្យបានផងហោង នាឥឡូវនេះ ស្រោណាទឹងផឹកក្តី ត្រីសាច់នឹងចំណីធីក្តី យើងកុំឲ្យធំបានឡើយ ហើយអ្នកទាំងឡាយសន្ទាប់គេនៅនាហ៍ខនោះ ចូរគ្នាយើងស្រែកហៅនូវសត្វកោលាហលរវល់រចល់នោះឲ្យច្រើន ហើយយើងកាន់យកនូវព្រ-នន់ដំបងផងទាំងឡាយឲ្យធំប្រដំវាយគ្នាតពន្ធនទាំងឡាយ ធ្វើឲ្យខ្ទាត់ខ្ទាយត្រីសាច់ទាំងឡាយ ចូរកុំឲ្យធំបានឡើយ ឲ្យរត់ឲ្យធាប់ចូលទៅកណ្តាលជំនុំសេនាយោធាទាំងឡាយ ហើយគ្នាងចូលទៅក្នុងនគរស្រែកនូវសត្វនោះឲ្យរវល់រចល់ឡើង ធ្វើហាក់ដូចកលសុរក៏នឹងចាប់អាត្មា ចូរគ្នាងស្រែកឃោសនាឡើងថា រះយើងនេះ ជាអាមាត្យទៅមហោសថអ្នកប្រាជ្ញ អាចបិតៈនាំមិថិលានគរនាយហោង ហើយគ្នាងថាដូច្នេះ ភោ ម្នាលអ្នកទាំងឡាយអើយ ! ពោះយោបទនឹងអាចមកចាប់ស្តេចយើងលង់លង់មើលហ៎ះ ។ ... តុម្ហាកំ អាគតការំ ជាជា-បេត្វា អាកឡូថាតិ វត្វា បេសេសិ ។ តេ សាធូតិ តស្ស វចនំ សម្បដិច្ឆិត្វា វត្វា ... ។

(នៅមានត)

ការរលាយនៃភពផែនដី

និង

កើតជាថ្មីសាឡើងវិញ

ពាក្យកាព្យ

លោក ញុង.សៀង និពន្ធ

(តចប់)

## ការកកើតឡើងវិញនៃពិភពលោក

តពីនេះទៅយូរអនេក ពេលមួយមហាមេឃស្រែកធ្ងន់ធ្ងើយ
ផ្គរលាន់ទទ្រើនកើនឥតស្បើយ គគ្រេងល្វេងល្វើយ ហាក់ស្រណោះៗ
ហាក់ដូចស្រណោកសោករលឹក អាសូរដីទឹកសព្វកៀនកោះ
ទីឋានប៉ុន្មានដែលឆេះនោះ ដោយក្តីអាឡោះស្មោះពេកក្រៃ ៗ
រួចតាំងបង្អុរភ្លៀងរលឹម ទូទឹមជានិច្ចអចិន្ត្រៃយ
ផ្សើមគ្រប់កន្លែងភ្លើងប្រល័យ ទូទៅទាំងផ្ទៃគួរអស្ចារ្យ ៗ
គ្រាប់ភ្លៀងធំប៉ុនដូចគេសាច សក្យសក្តិស្វាចតូចល្អិតឆ្មារ
ហើយកាន់តែច្រើនលើសប៉ុនខ្នារ យូរយារធារធំប៉ុនឈើទាល ៗ
ភ្លៀងក្នុងគ្រានេះមិនដូចមុន ភ្លៀងទៀងទ្វេគុណជំក្រកាល
ភ្លៀងទាំបង្កើតចក្រវាឡ ភ្លៀងទាំបណ្តាលស្រីសួស្តី ៗ
ភ្លៀងមិនដាច់គ្រាប់ជាប់ជានិច្ច ភ្លៀងទាល់តែលិចគ្មានសល់អ្វី

ភ្លៀងយូរអង្វែងក្នុងលោកិយ    ភ្លៀងពេញភពបីទំបាំងស្ងាត់ ៗ
កាលភ្លៀងបង្អុរពោរពេញហើយ    អ្នកអើយមានខ្យល់បក់បោកផាត់
គឺខ្យល់អស្ចារ្យខ្យារក្តាត់    បក់ពុះពារកាត់កណ្តាលទឹក ៗ
បក់បៀតជ្រៀតជ្រែកបែកពពុះ    បក់ប៉ុនគេព្យុះសូរគឹក
បក់ហើយបក់ទៀតឆ្មៀតពន្លឹក    បក់ទាល់តែទឹកឡើងកករឹង ៗ
បក់ខ្លាំងប្រជួនជួនយ៉ាំងញាប់    បក់ថែមសន្ធាប់រ៉ូរឹង ៗ
បក់មិនសម្រាកផ្អាកត្រឹមហ្នឹង    ខ្យល់នៅតែប្រឹងតឹងចម្លែក ៗ
ខ្យល់បក់ចំហៀងឆៀងទៅក្រោម    ព័ទ្ធឡោមជុំវិញគ្រប់ចំណែក
តាំងទ្រដុំទឹកមិនឲ្យបែក    ខ្ទង់ខាប់អនេកទៅលើខ្យល់ ៗ
ប្រៀបដូចទឹកដក់លើស្លឹកឈូក    ផ្ទើងផ្ទាំងឥតភ្លូកនៅសល់វ៉ល់
ការយាំខ្លាំងខ្ចប់គ្រប់មណ្ឌល    ដូចគេតំកល់ជាប់ដរាប ៗ
រួចហើយខ្យល់បក់ជាលំដាប់    រុញច្រានប្រញាប់កាន់ទីទាប
ដើម្បីបង្កើតផែនដីរាប    ទៅតាមសភាពដ៏បុរាណ ៗ
គ្រានោះព្រហ្មលោកកើតឡើងវិញ    តាំងឋានសួគ៌មិញក៏កើតបាន
តាមដោយទំនងទងដើមដាន    គ្រប់ជាន់ថ្នាក់ឋានដូចធម្មតា ៗ
ចំណែកផែកឋានមនុស្សលោកថ្មី    មិនទាន់មានដីព្រៃព្រឹក្សា
មានសុទ្ធតែទឹកសន្ទឹកថ្លា    ល្ហល្ហាចក្រណាលទ្វាមសាយ ៗ

ស្រាប់តែមានខ្យល់ខ្លល់គគ្រឹក(១) បក់បិទខ្ទប់ទឹកខ្ទាំងមាលព្យាយ
ធ្វើទឹកឲ្យទាប់ស្អិតអន្ទាយ ឲ្យកើតខ្ទិះក្លាយមានរសឆ្ងាញ់ ។
ខ្ទិះដីនោះឯងអណ្តែតត្រា លើទឹកជម្ពាហាក់ដូចខ្លាញ់
ឬដូចទឹកដោះព្រោះចំកញ់ ផ្អែមឆ្ងាញ់មិនទាញ់សេផាតិស្ករ ។
មានខ្ទិនក្រអូបយ៉ាងឈ្ងុយឈ្ងប់ ពណ៌ស្រស់លើសលុបដំបរ
ជាទឹកឥតមានលាយកករ គួរឲ្យត្រេកអរចាប់ចិត្តចង់ ។

ក្នុងគ្រានោះឯងថ្ងៃឯសត្វ ដែលកើតវិបត្តិខាត់ស្លាប់បង់
ទៅកើតព្រហ្មលោកតាំងដៅពង្ស អង្វែងយូរលង់មុននេះកប្ប ។
ខ្វះអស់អាយុខ្វះអស់បុណ្យ កសិជាបដុនគឺត្រូវស្លាប់
កំបេវិលវឹងចុះក្រឡាប់ កើតជាលំដាប់ក្នុងលោកិយ ។
ដោយឧបបាតិកកំណើត ស្រាប់តែកកើតធំដឹងក្តី
ហើយមានពន្លឺភ្លឺរស្មី សរីព្រោលផ្ទាំងតាំងខ្លួនឯង ។
ជាសត្វមានឫទ្ធិពិតឧត្តម រុងរឿងថ្កើងថ្កុំសមចំពោង
បិតលើអាកាសដាសដាក់ស្តែង ហោះហ្យានខ្វាត់ខ្វែងក្លីព្រាងព្រាយ ។
មានតែបីតិជាអាហារ មិនទាន់ត្រូវការបេះឃ្លានបាយ
នាំគ្នាផ្លុកផ្លោះហោះប្រញាយ កញ្ជ្រៀវក្អាកក្អាយបានតាមចិត្ត ។
ប៉ុន្តែចំណែកគ្រឿងប្រដាប់ ខោអាវសម្រាប់ស្លៀកបាំងបិទ

---
១- ខ្យល់ផ្សេងមួយលើកទៀត ។

គ្មានទេអ្នកអើយបើតាមពិត ថ្វីបើមានឫទ្ធិបិតលើមេឃ ។
តាំងកេទសង្កេតទៀងប្រាកដ គឺគោលកំណត់កត់ចំណែក
ជាប្រុសឬស្រីផ្សេងដោយឡែក ក៏ឥតមានថ្កុតថែកសញ្ញា ។
គ្រាន់តែមានរាងពិតជាមនុស្ស មិនដឹងស្រីប្រុសខុសត្រង់ណា
ស្អាតធេងគ្រងិលស្រិលគ្មានត្រា មិនអាចពាយថាឲ្យត្រូវម៉ែក ។
ត្រគាកត្រគះកន្ទីង · ធីង រលោងរលីងដូចគេបក
សាច់មដ្ឋជិតស្និទ្ធឥតស្រុតស្រក កុញកកប្រឡែងលេងកំសាន្ដ ។
វេលាគ្រានោះមានសត្វមួយ មិនស្ងូវបេះព្រួយក្លៀវក្លាហាន
ឡេះឡោះជាងគេតាំងប៉ុន្មាន ឃើញខ្ទិះដស្ងានថាស្អុំនេះ ។
អណ្ដែតដេរដាសក្រាស់លើទឹក ពាសពេញសន្ទឹកច្រើនអីម្ល៉េះ
ក៏តាំងលូកដៃលៃកកេះ កកាយឆ្កុះបេះញាត់មាត់ប៉ុប
រសជាតិនោះឯងសែនឆ្ងាញ់ក្រៃ សរសៃប៉ុន្មានជ្រួតជ្រាបសព្វ
ភ្ញក់មើលប៉ុណ្ណោះមិនទាន់ស្កប់ រឡិបរឡប់បេះតែថែម ។
រីសត្វឯទៀតធ្មៀតគ្រាប់តាម ជញ្ជក់មាត់ញ៉ាំមល់ទ្វើប៉ុមៗ
ពីព្រោះខ្ទិះដីមានរសផ្អែម ស្រាប់តែផ្អើលក្រុមគ្មានសល់ម្នាក់ ។
ធ្កុះស៊ីតិចៗ មិនអស់ចិត្ត ព្រោះដៀតក្ដីល្មោភលោភជំពាក់
មិនកាយខាងលើសើកក់ៗ លេងលូកដល់ថ្នាក់ប្រឡាក់ដៃ ។
ពូតជាពន្លូតស៊ីឃ្មុមៗ ស៊ីនោះមិនល្មមទេអ្នកប៉ៃ

ដូចមនុស្សអត់បាយឃ្លានយូរថ្ងៃ
ពិតឥតសំច័យចាល់តែខ្ទួត ។
ព្រោះតែបរិភោគយោកខ្ទិះដី
រស្មីដែលធ្លាប់ភ្លឺក្រឡែត

ក៏ស្រាប់តែបាត់ស្ងាត់មួយភ្លែត
បណ្ដាលកើតហេតុងងឹតឈឹង ។
តាំងផ្អើលរវល់ខ្វល់ជ្រួលជ្រើម
ពពឹមពពើមភ័យស្មោស្មឹង

ពពាក់ពពូនលូនប្រែប្រឹង
មិនដឹងជាទៅទិសខាងណា ។
ធ្លាប់មានពន្លឺភ្លឺខ្លួនឯង
ចិញ្ចាចចិញ្ចែងដូចតារា

ឥឡូវខ្វាត់បាត់ពីកាយា
ព្រោះតែតណ្ហាលោកលើសលន់ ។
សត្វទាំងប៉ុន្មានខានសប្បាយ
កើតក្ដៅក្រហាយស្ដាយពេកពន់

ជំនុំគ្នាព្រួយជួយគិតគន់
បែរបន់ទឹករកពន្លឺថ្មី ។
គ្រានោះមានភ័ព្វគាប់មង្គល
សុរិយមណ្ឌលរឿងរង្សី

បំបាត់ភ័យសត្វក្នុងលោកិយ
ទើបបើករស្មីភ្លឺច្បាស់ថែង ។
រីឯពួកសត្វកំពុងព្រួយ
ងើបក្បាលរង្គួយអរក្រៃលែង

បានឃើញពន្លឺភ្លឺចិញ្ចែង
ផ្អើលរត់ខ្វាត់ខ្វែងងើយមើលមេឃ ។
កញ្ចែងកញ្ចាត់បាត់ក្ដីទុក្ខ
រីកមុខប៉ប្រិមញញឹមត្រេក

លោកហៅកញ្ច្រៀវខ្ញៀវអនេក
សប្បាយចំឡែកស្រែកហោហា ។
ទើបតាំងសន្មតនាមពន្លឺ
មណ្ឌលដែលភ្លឺថា "សុរិយា(១)"

---

១– សន្មតនាមថា "សុរិយៈ" ព្រោះពន្លឺនោះក្នុងពេលដែលរះឡើងអាចបំបាត់នូវភ័យព្រួយរបស់សត្វ ហើយញ៉ាំងសួរភាពគឺសេចក្ដីត្រៀវក្លាឲ្យកើតឡើង ។

ព្រោះហេតុញាំងសត្វព្រួយចិត្ត ឲ្យបានក្លៀវក្លាបាត់ភិតភ័យ ។
ក្នុងកាលនោះឯងព្រះអាទិត្យ សំដែងរុងច្ចែងពេញមួយថ្ងៃ
ក៏អស្តង្គតរលត់ក្ស័យ ទៅតាមសម័យលោកនិយម ។
ពួកសត្វនិករពាំងនោះឯង តឹងទ្រូងចំបែងរែងបារម្ភ
ងងឹតចូលលុកមុខក្រៀមក្រំ នាំគ្នាខិតខំអធិដ្ឋាន ។
ទះទគុណបុណ្យព្រះអង្គអើយ ម្តេចឡើយមកនាំឲ្យព្រួយប្រាណ
ម្តងមានពន្លឺម្តងគាក់ខាន ក្សេមក្សាន្តមិនបានហូរហែសោះ ។
ប្រសិនបើមានពន្លឺទៀត យើងអស់ចង្អៀតព្រួយក្រៀមក្រោះ
មុខជាកែកាយសប្បាយស្មោះ រំដោះកង្វល់ខ្វល់គានគឹង ។
កាលនោះរីឯចន្ទមណ្ឌល កើតងាយនិមលហាក់យល់ដឹង
សេចក្តីប៉ុនប៉ងបំណងហ្នឹង ដែលសត្វរំពឹងទន្ទឹងខ្លាំង ។
បញ្ចេញរស្មីពិសីច្រើន រះលេចកើតឡើងពន្លឺចាំង
គ្រប៉ះគ្រប់ខ្ទង់សម្រាំង ភ្លឺផ្លាំងស្រទន់ពេកពណ្ណនាយ ។
ពពួកសព្វសត្វពាំងប៉ុន្មាន កំពុងតឹងតានប្រាណធុញណាយ
ស្រាប់តែត្រឡប់ជាប្រែក្លាយ ញញឹមក្អាកក្អាយសប្បាយក្រៃ ។
នាំគ្នាសន្មតកត់តាំងតែង ពន្លឺនោះឯងថាចន្ទ[1]ថ្ងៃ

១– កំណត់នាមថា "ចន្ទ" ព្រោះពន្លឺនោះហាក់ដូចជាដឹងនូវ "ឆន្ទៈ" (បំណងឬអធ្យាស្រ័យ) របស់សត្វទើបរះឡើង ។

ព្រោះរះបំពេញអធ្យាស្រ័យ    ពួកសត្វដែលភ័យឱ្យធូរស្រាល ។
ពីនេះតទៅជាលំដាប់    កើតផ្កាយ តាន់តាប់ដ៏ត្រកាល
ជារូបផ្សេង ៗ គួរត្រេកអាល    ព្រោងព្រាយជាសដាលពេញមេឃា ។
តាប់តាំងពីនោះជាដើមហេតុ    បរិច្ឆេទកត្រីទិនទក់
កើតមានប្រាកដកំណត់ឃ្មា    ទៀងពេលវេលាជាដកប ។
រីឯរដូវទីងខែឆ្នាំ    មានគ្រឿងចំណាំតាមសភាព
កំរិតល័ក្ខណ្ឌកាន់រៀងកប    ឥតសាបរលាបដល់សព្វថ្ងៃ ។
ចំណែកគតផែនដែនប្រថពី    បពិតគិរីធំស្កឹមស្កៃ
សិនេរុកជហិមាល័យ    កើតក្នុងសម័យជាន់នោះ[១] ឯង ។
តំណជាតិធាតុស្មៅដុះដេរដាស    លូតលាស់ពេញពាសសព្វកន្លែង
ទាំងព្រៃព្រឹក្សាលតាវែង    ប្រដែងដុះដេរជាលំដាប់ ។
ទីងថ្ងៃឯពួកសត្វទាំងឡាយ    លែងព្រួយខ្វល់ខ្វាយណាយយ៉ុនយ៉ាប់
បរិភោគខ្ទិះដីឆ្ងាញ់ចំណាប់    ដែលមានស្រេចស្រាប់សម្រាប់ខ្លួន ។
លុះកាលកន្លងយូរអង្វែង    កំឡាំងកំហែងក៏មាំមួន
ប៉ុន្តែសម្បុរលែងភ្លឺខ្លួន    ខ្វះទៅសមសួនខ្វះស្មៅហ្មង ។
អ្នកមានរូបល្អសពណ៌កាយ    មើលងាយអ្នកអន់ឯទៀតផង
ជៀមជាមតាក់ឡៀលជៀលឌីជង    ថាអាប់ពេកៈហោង សាច់គគ្រើម ។

---

១– កើតដំណាលគ្នាក្នុងថ្ងៃកំណើតនៃព្រះអាទិត្យនិងព្រះច័ន្ទ ។

មើលទៅត្រាតមិនស្អាតស្អំ　　សម្បុរមិនសមដូចពីដើម
ភាំងបែបកខ្វរគួរឲ្យខ្ពើម　　កុំមកទើមទើមនៅក្បែរអញ ។
ព្រោះមើលឆាយគ្នាជាបច្ច័យ　　នាំឲ្យចង្រៃកើតគ្នាន់ខ្នាញ់
ខ្ទិះដីដែលមានរសជាតិឆ្ងាញ់　　ស្រាប់តែតាលតាញវិនាសបាត់ ។
នាំគ្នាជំនុំជុំខ្វល់ខ្វាយ　　មិនសូវសប្បាយស្តាយពេកក្តាត់
ពុំគួរមានឥមកផ្តាច់កាត់　　កំតាត់ចំណីឆ្ងាញ់ពីសា ។
ពេលនោះស្រាប់តែក្រមរដី　　កើតឡើងថ្មោងថ្មីមានឧបមា
ដូចផ្សិតក្បាលពស់ស្រស់ថ្លៃថ្លា　　មានរសឱជាឆ្ងាញ់ពេកក្រៃ ។
បានជាចំណីសត្វទាំងឡាយ　　ចែកគ្នាប្រញាយគ្រាន់អាស្រ័យ
ចិញ្ចឹមជីវិតរៀងរាល់ថ្ងៃ　　គជាបច្ច័យយូរអង្វែង ។
កើតមានកំឡាំងខ្លាំងស្វាហាប់　　រឹងប៉ឹងចំណាប់យ៉ាងខែងរែង
រីឯសម្បុរក៏ផ្លាស់ផ្លែង　　តាំងដៀលគ្នាឯងដូចមុនទៀត ។
លុះក្រមរដីវិនាសទៅ　　ពពួកសត្វនៅព្រួយចង្អៀត
ចេះតែគិតគៃលៃ ឈ្លាសទៀត　　ពិគ្រោះរកស្បៀងលៀងជីវិត
វេលាគ្រានោះបពាលត:[១]　　ច្រើនក្រៃណាស់ណាំដុះជុំជិត ។
មានរសផ្អែមល្ហែមយ៉ាងប្រណីត　　ជាទីពេញចិត្តសត្វទាំងឡាយ ។
កាលយកវល្លិនោះជាអាហារ　　សឹងមានហេតុការណ៍ដូចបរិយាយ

---

១– ឈ្មោះវល្លិមួយយ៉ាងមានរសជាតិផ្អែម, មានសណ្ឋានដូចវល្លិត្រកួន ។

ខាងដើមមកហើយដោយទ្រូសត្រាយ　　គឺនាំប្រែក្លាយជាលំដាប់ ។
លុះកាលតមកក៏យូរលង់　　វល្លិ៍នោះមិនគង់អស់កាលកប្ប
សូម្បីសម្បូរដោសតាន់តាប់　　ក៏ប្រែក្រឡាប់ពាយសូន្យសោះ ។
សព្វសត្វកើតទុក្ខមុខក្រៀមក្រំ　　រងព្រួយបារម្ភស្តាយស្រណោះ
ស្មានបានវល្លិ៍ធ្លាញ់ជាកេរ្តិ៍កោះ　　តែមិនដូច្នោះខុសបំណង ។
គ្រានោះឯងកួរស្រូវសាលី　　ពណ៌ស្រស់ពិសីដុះឡើងស្គង
ផ្លែជាអង្ករសម៉ត់ម៉ង　　ស្អាតស្រេចតែម្តងមិនបាច់ស្រិត ។
មានខ្លិនក្រអូបយ៉ាងប្រសើរ　　ឈ្ងុយឈ្ងប់ប្រហើរក្រៃពេកពិត
គឺជាវត្ថុគួរជាប់ចិត្ត　　ដើមដុះដិតស្និទ្ធបិតពាសវាល ។
វីសត្វទាំងឡាយបានឃើញភ្លាម　　ប្រឹងស្ទុះរ៉មដោយស្រើបស្រាល
ប្រឡេះបេះស្រូវថ្មីត្រកាល　　ធ្វើជាអាហារយ៉ាងរីករាយ ។
តាមក្នុងគម្ពីរមានសំដែង　　ថាពេលនោះឯងកើតផ្ទាំងបាយ
សព្វសត្វទាំងអស់មុខស្រស់ស្រាយ　　ចែកចាយប្រើប្រាស់គ្រប់គ្នា ។
គេយកអង្ករដាក់ក្នុងឆ្នាំង　　រួចតាំងដាក់លើថ្ងា
មានភ្លើងឆេះឯងស្តែងណាស់ណា　　ក្តៅពីថ្ងាជានោះឆ្អិនស្រេច ។
គេគ្មានត្រូវការដោយសំឡ　　ដែលផ្សំគ្រឿងស្ពិតត្រីសាច់
ឬម្ហូបឯទៀតមិនចាំបាច់　　សម្រេចមានតែបាយនោះឯង ។

ចិត្តអ្នកបរិភោគចង់ដូរប្រែ(១) មិនចាំកែវទ្រព្យខ្នះខ្នែង
រសជាតិបាយនោះអាចផ្លាស់ផ្លែង ក្លាយក្លាមទៅឯងតាមចិត្តនឹក ។
ចំណែកផ្លែស្រូវមានធម្មតា បោចបេះត្រង់ណាក្នុងពេលព្រឹក
ពេលល្ងាចមានវិញពេញសន្ទឹក ទ្រុចទ្រុលណែនញឹកដូចប្រក្រតី ។
អស់លោកអ្នកអានបានពិនិត្យ ត្រិះរិះគន់គិតពីមនុស្សថ្មី
ប្រហែលសង្ស័យដែរឬអ្វី បរិភោគចំណីគ្មានផុះនោម ។
ស៊ីហើយស៊ីទៀតធ្មៀតចម្រុះ បេះតែបញ្ចុះប្រកចាំងតោម
បើគ្មានទ្វារចេញជេញទៅក្រោម របស់នោះទ្រោមទៅឯណា ។
វរៀងត្រង់ហ្នឹងសឹងជ្រាបស្រាប់ ដូចខ្ញុំសាស័ព្ទខាងដើមថា
សត្វមានកំណើតពីព្រហ្ម ជំបូងគឺគ្នាគ្មានទ្វារមគ្គ ។
ឥឡូវខ្ញុំសូមលៃជំរាប ឲ្យលោកអ្នកជ្រាបដោយជាក់លាក់
ទៅតាមហេតុកេចលំដាប់ថ្នាក់ កុំឲ្យរាំនរាក់ពាក់សេចក្តី ។
អាហារជាន់នោះខ្ពស់បំផុត ដូចទិព្វបរិសុទ្ធក្នុងលោកិយ
ជំបូងគឺរសជាតិខ្ទិះដី ដែលកើតឡើងថ្មីសម្រាប់សត្វ ។
រហូតមកដល់បពាលតា វិសេសថ្លៃថ្លាឆ្ងាញ់ពេកក្តាត់
កាលលេបចូលក្លាមរលាយបាត់ ជ្រួតជ្រាបស្ងួនស្ងាត់សព្វសរសៃ ។
គ្មានសេសសល់កាកជាលាមក ខ្ទិនស្អុយគគ្រក់អសោចិក្រៃ

---

១– មានៈសង្ឃូវប្រែជាដើម ។

លំបាកបត់ជើងវៀនកល់ថៃ　　ដូចក្នុងសម័យយើងនេះឡើយ ។
ប៉ុន្តែមកដល់ស្រីសាលី　　រីភេទប្រុសស្រីណាអ្នកអើយ
មុខជាកើតមានប្រាកដហើយ　　គម្ពីរបានឆ្លើយយ៉ាងជាក់ស្តែង ។
ព្រោះជាតិអាហារមិនមែនជ្រាយ　　មិនធាប់លាយគ្នាមឯង ។
កាលលេបចូលទៅនៅត្រាំត្រែង　　នាំកើតតឹងតែងរែងរឹករ ។
គ្រានោះសព្វសត្វព្រួយចិត្តខ្វល់　　ព្រោះណែនហួលហល់ឆ្អល់ខ្ទេរ
តឹងពោះក្តុង ៗ ហាក់ដូចស្គរ　　បញ្សរក្អែកស៊ីងប្រឹងភិតភ័យ ។
ប៉ុន្តែដោយមានភ័ព្វរក្សា　　កសិដគាថាជោគជ័យ
គឺធមិធម្មជាតិមកជួយលៃ　　រវៃសម្រួលពីរៀងហ៊ឹង ។
ពេលនោះអស្ចារ្យការចំឡែក　　ស្រាប់តែក្លាយបែកចែកជាលិង្គ[1]
មួយពួកលេចលូតស្អុយធ្កឹង　　ខ្វល់ទឹងតឹងហាក់ដូចប៉ោល ។
មួយទៀតស្រកូកក្រាបទៅតល់　　នរណាមិនយល់កុំជេញដោល
ប្រយ័ត្នខ្ញុំភ័យល្ងាំងរត់តោល　　គេចបាត់ស្រមោលខានគេរឿង ។
កើតទ្វារមួយទៀតផ្សេងដោយឡែក　　ទុកជាចំណែកបញ្ចេញគ្រឿង
លាមកអ្នកអាប់ខ្ទង់ខាប់លឿង　　កុំឲ្យកកគៀងទើបសុខស្រួល ។

---

១– ភេទ, លក្ខណៈ ឬ គ្រឿងសំគាល់ជាប្រុស-ស្រី ។ អ្នកដែលធ្លាប់មានភេទជាប្រុសពីដើម (ក្នុងកាលមុនភ្លើងចេះកំឡ្យ) ពេលនោះបានទទួលភេទជាប្រុសវិញ ឯអ្នកដែលធ្លាប់ជាស្រីពីដើម ក៏មានទំនងដូចគ្នាដែរ ។

កាលបានកើតគ្នាទាំងពីរក្រោម　　អ្នកដែលទឹមតាមតឹងណែនអួល
បក់ដើងតូចធំតាមសម្រួល　　អស់ក្តុកហួលស្រួលធម្មតា ៗ
កៃបំកប្រុស ៗ ធ្លល់មិនដឹង　　អ៊ក់ខ្ទួនហ្វឹងពិបាកថា
ស្រាប់តែកើតក្តាមមកពីណា　　ឮយ៉ាំរាំងបែបក្រង់កង់ ៗ
ទើបមើលនាយអាយដោយអឹមអៀម　　មិនស្ទាត់បាត់ស្មៀមលបសំឡក់-
សំឡឹងកិនស្រីក្អកមក់ ៗ　　ហាក់មានអ្វីធក់ប្រទាញចិត្ត ៗ
រីឯស្រី ៗ ជួរប្តោះដែរ　　កំតាំងផ្អាកបែរមើលបញ្ចឹត
បញ្ចៀងជៀងវិញដោយស្នេហ៍ស្និទ្ធ　　យូរ ៗ វិបរិតលែងឃ្លានបាយ ៗ
ខាងណោះផ្អាកទៅខនលគក　　ខាងណោះក្អួតមកត្រគាកសាយ
ភគៈកេលភលជាលក្នុងកាយ　　បបូរមាត់ស្វាយក្អកមមី ៗ

ពាក្យ ៩

មេឃខ្មួំមរលឹមលាយព្រះពាយផាត់
ព្យុះកំហាត់កាត់កំហោកបោកសព្វទី
ឈើតូចធំរលំខ្ទេចរេចរីករី
ខ្យល់យាយីចិប៉ុន្មានគ្មានកំបាំង ៗ
ផ្គរគ្រឹកក្អឹកកគ្រេងលេងខ្ញូរមេឃ
លាន់អនេកឆ្លុកបន្ទោរញ្ញាក្តាចផ្ទាំង
កាំរន្ទះរះរន្ទឹកទ្រុឌទាំង

បាញ់ម៉ាំងម៉ាំងតាំងក្ដីប្រាលដាលប្រាក់ ។
គួរឲ្យគឹតគិតឲ្យភ័យលៃខ្លាចផាប់
ផ្អើលដូចទ័ពញាប់រចល់ខ្វល់ទាំងសត្វ
សូរសម្រែកស្រែកទ្រហឹងប្រឹងប្រយ័ត្ន
ខ្លះបោលបាត់ខ្វាត់ទៅឆ្ងាយផាយបះជើង ។
ខ្លះកក្រើកកំរើកដល់ទល់កុដគ្គ
នាគរឿងរុងពន់ពារក្លារងើបឡើង
ទឹងធុរធេរក្រេវពិរេពធក្រោធដូចភ្លើង
ក្បាលទ្រមើងដំឡើងបុទ្ធិឥតស្ញប់ស្ញែង ។
ទើបស្ដេចនាគងាកងោកត្បុលសសុលចូល
ជ្រែកក្ដងស្បលបណ្ឌលកោះស្ពោះចំពោង
កន្ទុយញាច់ជាប់ប្រកិតរឹតទឹងខែង
ក្បាលប្រឡែងរែងប្រឡូកចូកព្រៃស្ពាប់ ។
សូរសន្ធឹកគគឹកញ័រខ្ទរចំឡែក
រឹងសព្ទួកបែកផ្កាគ្រែងដូចផ្សែងអ័ព្ទ
ពើខ្លាយសាយសព្រាតខ្វាតទន់ទាប់
នាគស្ពឹស្លាប់យ៉ាប់ដូចម្ដេចមិនគេចពា ។
ដល់បាតកោះស្ដោះព្រួសពិសទ្រឹស្ដទ្រទន់

ហាក់បង្អន់ចង់ស្រងល់ឆ្អល់អាត្មា
ញ័រចំប្រប់ចប់យ៉ាំកកាយណាយចិន្តា
ទើបនាគាកក្រឡាប់ចាប់វិង្ខី ។

ពាក្យ ៣

គ្រានោះអ្នកមានការស្រើបស្រាល កើតកើនត្រអាលប្រុសនិងស្រី
ឥតគិតប្រិតប្រៀនអៀនខ្មាសអ្វី យោលយោកជាសដីកណ្តាលក់លៗ
ចំណែកអ្នកមានក្តីអៀនខ្មាស ឃើញរឿងផ្តេសផ្តាសអំពើពាល
នៃពួកអ្នកត្រេកដេកត្រោបត្រាល ននលពាសវាលគួរឲ្យស្មេង ។
តាំងរើសដុំដីនិងដំបង គ្រវែងពោលខ្ទង់ពួកនោះឯង
ហើយដៀលដោយពាក្យជូរចត់ស្មែង សំដែងនូវការមិនពេញចិត្ត ។
ពួកអ្នកស្រើបស្រាលទាំងប៉ុន្មាន ស្តាប់ពាក្យនោះបានក៏រិះគិត
ឃើញថាពុំគួរតប្បពិត ទើបរៀបបាំងបិទធ្វើផ្ទះនៅ
ម្យ៉ាងទៀតឯរឿងគ្រឿងស្លៀកពាក់ ខ្លះក្រងប្រទាក់វល្លិ៍ក្រពៅ
ខ្លះខ្ចាស់ស្លឹកឈើឬក្រងស្មៅ ប៉ុនព័ទ្ធពីក្រៅការកេរ្តិ៍ខ្មាស ។
ពេលនោះផលស្រូវសាលី ដែលដុះពេញដីមុខដេរដាស
មិនទាន់ប្រែប្រួលឬវិនាស នៅតែពោរពាសដូចប្រក្រតី ។
ប៉ុន្តែលុះយូរតមកទៀត ពួកមនុស្សខំធ្មៀតទាំងប្រុសស្រី
នាំគ្នាបេះបូកប្រូតដាក់ល្អី ហើយក៏ឃ្មាតខ្មីយកទៅទុក ។

ដើម្បីបរិភោគឲ្យបានយូរ ជាការស្រួលជួរខ្លួនស្រណុក
គ្រាន់មានពេលខ្វះដេកស៊ុក កុំឲ្យគ្រុក ៗ កល់តែថ្ងៃ ។
ដោយហេតុពួកមនុស្សកើតគំនិត ទុកបាយរិះគិតចេះសំច័យ
ស្រូវទុំទិញមានតម្លៃ ក៏ពាយហើនហៃបន្តិចម្តង ។
មានផ្ទៃមិនញឹកសទឹកស្កះ កន្ទុងទីខ្វះដូចគេចង
ប្រមូលជាគុម្ពជាគុម្ពផង ហើយថែមមានល្អងកន្ទក់រំ ។
មានទាំងអង្កាមពណ៌ហង្សសៅ ក្តោបព័ទ្ធពីក្រៅជាសដិតជុំ
គឺស្រោបអង្ករដូចគេហុម ហើយមានខ្ទីទុំទៅតាមកាល ។
ពេលនោះផ្តើមមានអង្រែត្បាល់ បែនបុកដំដាល់មិនដូរស្រាល
យូរទៅកាន់តែទាំបណ្តាល ឲ្យកើតចិត្តពាលខូចអប្រិយ ។
ទើបតាំងលៃលកក់យចំណែក រាស់វែងតាយចែកស្រូវសាលី
ឲ្យស្មើភាគគ្នាទាំងប្រុសស្រី ចៀសរាំងកើតក្តីឈ្លោះតាស់ខែង ។
រួចហើយក៏បោះព្រំប្រទល់ កំរិតមណ្ឌលសព្វកន្លែង
បង្កើតជាស្រែក្រឡាខ្វង ស្រណុកហួងហែងផ្សេងដោយឡែក ។
ពួកអ្នកទាំងនោះក៏ប្រកាន់ នាទីកំណាន់វ័ណ្ឌចំណែក
ទៅតាមកំរិតស្រែគេចែក ឃើញថាស្រួលឯកប្លែកក្នុងចិត្ត ។
ប៉ុន្តែមិនយូរប៉ុន្មានសោះ មានខ្វះឡេះឡោះខូចទុច្ចរិត
បានលួចស្រូវគេ ៗ តាមគិត តាប់យកទៅប្រើតប្រៀនប្រដៅ ។

មួយលើកពីរលើកមិនកន់តាល    នាំឲ្យដាលរាលកើតមួរមៅ
អ្នកខ្លះចាប់បានវាគាត់ផ្ដៅ    ចិត្តនៅរឹងខ្លាំងតាំងកាយដ់ ។
អ្នកខ្លះដែលគ្មានកាន់វាគាត់    កំញើញជាកចាត់លាត់លោតច្រំ
តាល់តែអ្នកទោះឈើខ្លួនក្រំ    ធ្ងន់យាំងដំណាំស្មើរជិតស្លាប់ ។
មិនមែនតែរឿងលួចមួយទេ    អកុសលកើតទ្វេជាល់ដាប់
បន្ទិចនេះនោះឈ្មោះអ៊ឹងអាប់    គ្មានមេស្ដីប្រាប់ឲ្យស្ដាប់បាន ។
ទើបហៅប្រមូលគ្នាចួបជុំ    ជំនុំរើសរកអ្នកក្លាហាន
ដែលមានរូបល្អសមប្រាណ    ស័ក្តិខ្ពស់ថ្កើងថ្កានមានប្រាជ្ញា ។
ជាអ្នកទៀងត្រង់ផ្លូវផង់ពិត    មារយាទគំនិតវិសេសថ្លា
ប្រតិពលយល់ច្បាស់តាស់ក្បៀវក្លា    លើកជាមេបារបស់ខ្លួន ។
ដើម្បីទូន្មានប្រៀនប្រដៅ    អ្នកដែលល្ងង់ខ្លៅឲ្យមាំមួន
ដាក់ទោសទណ្ឌកម្មតាំងប្រដួន    ដល់អ្នករុកកួនឲ្យខ្លាចខ្លប ។
លុះបានពិគ្រោះអស់ពេលវែង    ឥតមានទាស់ខ្វែងក៏យល់ស្រប
ឃើញថារឿងនេះជារបប    សមសួនប្រកបតមបំណង ។
គ្រានោះក៏បានបបួលគ្នា    ស្រុកខ្មុំម្នាទៅអ៊ឹងកង
ពញាក់តពូនប្រុសស្រីផង    រកអ្នកចបងធ្វើជាមេ ។
ដល់ទីលំនៅបុរសម្នាក់    រូបកងសមស័ក្តិឆេតជាងគេ
ហាក់មានបុណ្យសានពីបុរេ    ក៏តាំងវិរៈប្រាប់ដំណឹង ។

តាមដោយដំណើរដែលខ្ញុំទប់ង    មានគោលបំណងរកទីពឹង
អង្វរសូមយកជាពំនឹង    បង្អែកមាំនឹងវែងឆ្ងាយ ។
បុរសបានស្ដាប់យល់ឃើញល្អម    ទទួលស្ម័គ្រព្រមដោយស្រស់ស្រាយ
រីមនុស្សទាំងអស់គីរកកាយ    ស្រែកហោសប្បាយលោតទះដៃ ។
រួចហើយទើបតាំងរៀបអភិសេក    សន្មតជាឯកអតិរេកក្រៃ
ឲ្យនៅស្រណុកសុខកល់ថ្ងៃ    គឺលើកតម្កើងទុកជាមកុដ ។
កាលនោះពាក្យថា "មហាសម្មតៈ"(១) ថ្លៃថ្លាអគ្គៈដ៏បរិសុទ្ធ
ក៏បានកើតឡើងមុនបំផុត    ពួកមនុស្សលំអុតតាំងដំកល់ ។
នាមនេះបុរសបានទទួល    ស្រុះស្រួលសម្រួលតាមយោបល់
ដែលគេព្រមព្រៀងប្រឹងថ្វាយខ្វល់    តែងតាំងប្រគល់ក្ដីជាធំនោះ ។
កាលបានទទួលងារស័ក្តិហើយ    មិននៅកន្តើយទទេសោះ
មហាសម្មតគាត់ហៅឈ្មោះ    អ្នកមានរឿងឈ្មោះកាត់សេចក្ដី ។
ផ្សះផ្សាឲ្យបានជានឹងគ្នា    ផុតទោសនិន្ទាពុំគប្បី
អ្នកណាខុសល្មមបន្ទោសស្ដី    ណាធ្ងន់អប្រិយបំបរបង់ ។
តាមដោយដំណើររឿងពិត ១    ត្រឹមត្រូវសុចរិតចិត្តផូរផង់
ឥតមានលំអៀងធៀងខ្វៀនខ្វង់    តម្រង់កែមនុស្សឲ្យសុខសាន្ត ។
ចំណែកខាងរឿងគ្រឿងបាយទឹក    ពេលល្ងាចនិងព្រឹកទាំងប៉ុន្មាន

១– មានន័យថា " អ្នកដែលមហាជនបានសន្មតតាំងឡើង " ។

ឥតមានលំបាកព្រួយវិនាន
បុរសនោះបានស្រួលជានិច្ច ។
ព្រោះគេតែងជូនស្រូវសាលី
ទាំងគៅទាំងល្អតាមច្រើនតិច
ជាសួយអាករបំពេញកិច្ច
គ្មានពុតកលល្បិចក្រឡិចវៃប្រែ ។
ដោយមានទំនងពាក់ទងហេតុ
ប្រមុខលើខេត្តស្រូវស្រែ
បុរសមានយសខ្ពស់ពូកែ
ស្រាប់តែបាននាមមួយទៀតថ្មី ។
ជា " ខត្តិយៈ[១] " វរៈវង្ស
ប្រសើរច្រើសទ្រង់ខ្ពង់ពិសី
ពិសេសឧត្តមសមល្បាញល្បី
មហាជនប្រុសស្រីស្រឡាញ់គ្រប់ៗ
តមកបាននាមក្រោយបង្អស់
ឧត្តុង្គឆើតស្រស់ដំលើសលប់
គឺនាម " រាជា[២] " កំពូលកត
សឹងបានជាមូលយ៉ាងសាខា ។
អស់លោកអ្នកអានបានជ្រាបទេ
អ្នក " មេធំ " នេះគឺនរណា
ដែលឡើងជាស្ដេចសាប់គឺថា
គ្រប់គ្រងរដ្ឋកប្បប្រថម ។

---

១– ជាអធិបតីនៃខេត្តស្រែចំការ ។ ២– អ្នកគ្រប់គ្រងបណ្ដាជនឲ្យបានសេចក្ដីរីករាយសប្បាយតាមធម៌ ។ នាមទាំង ៣ គឺ " មហាសម្មតៈ, ខត្តិយៈ, រាជា " តាមក្នុងអគ្គញ្ញសូត្រហៅថា " អក្ខរៈ " បានសេចក្ដីថា " ពាក្យសម្រាប់កំណត់ដាក់ឈ្មោះ ឬសម្រាប់បញ្ញត្តហៅ " ។ ពាក្យទាំងនេះ មិនមែនទើបនឹងកើតមានថ្មីក្នុងបឋមកប្បនេះទេ គឺជាពាក្យចាស់មានមកតាំងពីបុរាណកាល ( តាំងពីកប្បមុនៗ ) លុះដល់មកក្នុងកប្បថ្មីនេះ គឺជាកាលសម្បត្តិ ឬ កាលៈទេសៈ ទើបបណ្ដាលឲ្យពពួកសត្វនឹកឃើញអក្ខរៈដើមនោះយកមកសម្មតកំណត់ដាក់នាមដល់អ្នកដែលត្រូវបានឡើងជាស្ដេចជាដំបូង ។ សព្វថ្ងៃនេះនៅប្រទេសយើងនាមទី ១ គឺមហាសម្មតៈ មិនដែលឃើញប្រើទេ, មានប្រើតែនាមទី ២ គឺ ខត្តិយៈ ឬ ខត្តៈ (បា) ក្សត្រិយ៍ ឬ ក្សត្រ (សំ.) និងនាមទី ៣ គឺ រាជា តែប៉ុណ្ណោះ ។

មិនមែនមនុស្សផ្តាសសាសន៍វិបត្តិ  គឺពោធិសត្វគោត្ត–គោតម
ជាតិដែលព្រះអង្គផ្ចង់វិតក់  ស្វះស្វែងសន្សំសាងបារមី ។
ជាន់នោះទ្រង់យោនយកកំណើត  អន្ទោលកកើតក្នុងកប្បថ្មី
នៅក្នុងចំណោមជនប្រុសស្រី  ទ្រង់មានសរីរខ្ពស់បណ្តាច់ ។
គេមានសេចក្តីលំបាកចិត្ត  ព្រោះកើតវិបរិតមិនបេះស្រេច
ទើបលើកតាំងទ្រង់គង់ជាស្តេច  ដើម្បីសម្រេចការក្នុងស្រុក ។
តាប់តាំងពីនោះដូចថ្លែងហើយ  អ្នកអើយពួកជនដែលកើតទុក្ខ
ប្រកបការងារនៅជាសុខ  ផុតក្តីអុកឡុកមុខស្រស់ស្រាយ ។
លុះវណ្ណៈក្សត្រកើតមុនរួច  ទើបផ្តួចវណ្ណៈផ្សេងតាំងឡាយ
កើតឡើងបន្តពេញសុសសាយ  មានជាន់ថ្នាក់ក្លាយជាលំដាប់ ។
ព្រាហ្មណៈវេស្សៈសុទ្ទៈផង (១)  ជាពួកជាកងច្រើនតាន់តាប់
មានមុខរបរត្រូវកាន់កាប់  សម្រាប់ពួកក្រុមរៀង ៗ ខ្លួន ។
រីរឿងរលាយកតផែនដី  ហើយកើតជាថ្មីវិញមាំមួន
ដែលបានបរិយាយស្រាយតាមក្បួន  ប្រកបពាក្យជួនផ្ទួនហូរហែ ។
ព្រមតាំងបន្ថែមសែមពាក្យពេចន៍  ឲ្យលាស់លូតលេចមានផ្កាផ្លែ

---

១– ព្រាហ្មណៈ (ព្រាហ្មណ៍ គឺអ្នកបង្ហាត់បង្រៀនវេទមន្ត); វេស្សៈ ឬវៃស្សៈ (អ្នកប្រកបការងារផ្សេង ៗ មានពាណិជ្ជកម្មជាដើម); សុទ្ទៈ ឬ សូទ្រៈ អ្នកស៊ីឈ្នួលលីសែង គឺកម្មករ) ។

ជាគ្រឿងកំសាន្តបានល្ហើយល្ហៃ    សន្ទុតចប់តែប៉ុណ្ណេះហោង ៗ

បន្ទាប់ពីនេះសូមបញ្ជាក់    ដល់អស់លោកអ្នកទាំងពួងផង

អំពីរឿងនេះត្រូវទាក់ទង    តាមដោយចំនងដែលគួរយល់ ៗ

មនុស្សយើងកើតឡើងដំបូងផុត    ចិត្តថាបរិសុទ្ធស្អាតនិមល :

អាហារទិព្វឆើតកើតជួយផ្តល់    ស្រេចស្រាប់ឥតខ្វល់អំពល់អ្វី ៗ

ចុំខ្លួនលុះតល់ដាប់មក    តណ្ហាជ្រៀតជ្រែកក្នុងចិត្តថ្មី

ធ្វើចិត្តឲ្យល្អក់ខូចអប្រិយ    ខ្លួនទាំងប្រុសស្រីគ្មានសល់ម្នាក់ ៗ

នាំឲ្យរបស់ស្រស់នោះឯង    ទៅជាតឹងតែងក្នុងកាចកាក

ដភបសាបសូន្យអ្នូនចុះធ្លាក់    យូរៗដល់ថ្នាក់លំបាកខ្លាំង ៗ

រាគៈទោសៈមោហៈព្រួត    លោភៈប្រកួតអួតប្រណាំង

នាំឲ្យកេលកលដាលប្រឆាំង    ក្លាយជាចំបាំងកាប់តាក់គ្នា ៗ

សម្រុះសម្រួលលែងកើតសោះ    កញ្ជ្រោលបោលហោះគ្រប់ទិសា

ពុំដឹងជាស្តាប់អ្នកខាងណា    ស្រវាយកត្រូវតែរៀនខ្លួន ៗ

គ្មាននរណាមួយអាចសម្រេច    កាត់ក្តីឲ្យស្រេចល្មមសមសួន

អកុសលបេះតែកើតផ្ទួន ៗ    រឹតថែមប្រជួនជាដភប ៗ

លុះពេលវេលាកន្លងយូរ    ឥតមានស្រោលធូរកាន់តែជាប

ទាល់តែត្រូវភ្លើងឆួលឆេះឆាប    បង្ក្រាបកាត់ក្តីទើបបានចប់ ៗ

តំច្បាប់ធម្មជាតត្រូវលាងលោក    ឲ្យជ្រះស្អាតគ្រោកកខ្វក់សព្វ

រួចហើយទើបតាំងសាគ្រឡប់ បង្កើតពិភពវិញជាថ្មី ។
ថ្មីនេះយូរទៅ ៗ ជាចាស់ បាបកាន់តែគ្រាស់ពាសពេញដី
ដកបចុះយ៉ាប់អាប់សិរី វិនាសវិញខ្ទីទៀតជៀងជាក់ ។
វិលចុះវិលឡើងគ្មានចុងចប់ គ្រឡិនគ្រឡប់ឥតឈប់អាក់
នេះឯងហៅថាសំសារចក្រ វិលដូចប្រពាក់គ្រឿងយានយន្ត ។
ពីស្លាប់ទៅកើត ៗ ទៅស្លាប់ ច្របល់ផ្លាស់ផ្លាប់ច្រើនពេកពន់
សូម្បីពុទ្ធញាណមានលើសលន់ ស្ទើរតែគិតគណន៍កប់ពុំបាន ។
    ម្យ៉ាងទៀតរឿងនេះគួរយល់ថា សព្វសង្ខារអម្បាលម៉ាន
ដែលកកើតឡើងជារូបប្រាណ យើងពុំគួរស្មានថាថេរបិត ។
កុំថាតែសត្វក្នុងលោកិយ មនុស្សទាំងប្រុសស្រីមានជីវិត
សូម្បីផែនដីធំគ្រាស់ពិត បពិតរឿងបុទ្ធយ៉ាងស្កឹមស្កៃ ។
សមុទ្រជ្រាលជ្រៅជំទូឡារ ធំធេងអស្ចារ្យសម្បើមក្រៃ
គង់តែមានកាលត្រូវហិនហៃ ដោយភ្លើងប្រល័យក្សយឥតសល់ ។
យើងឃើញតែមនុស្សស្លាប់ញឹកញាប់ សត្វតិរច្ឆានងាប់កំប្លាប់យល់
លុះឮថាស្លាប់ស្រាប់តែឆ្ងល់ ហាក់ដូចអែកអល់ខ្វល់ចិន្តា ។
ព្រោះធ្លាប់សេះនៅតែលើដី តពូជប្រុសស្រីពីដូនតា
មិនដែលចាប់ភ្ញាក់នឹកស្មានថា ជីត្រូវមរណាស្លាប់ដែរសោះ ។

រឿងហ្នឹងមានតែព្រះជាម្ចាស់ ព្រះអង្គជ្រាបច្បាស់ប្រាកដស្មោះ
ជ្រាបទូទាំងភពគ្រប់កៀនកោះ ឥតមានចន្លោះសោះសល់អ្វី ។
ព្រះអង្គបានត្រាស់សំដែងហើយ អ្នកអើយសង្ខារក្នុងលោកិយ
ទោះឥតវិញ្ញាណឬមានក្តី ធំតូចវែងខ្លីសុទ្ធតែស្លាប់ ។
ខុសគ្នាតែត្រង់កំណត់កាល ខ្លះពាក់កណ្តាលខ្លះយូរឆាប់
ចំណែកផែនដីយូររាប់ក័ប្ប គង់ត្រូវខូចអាប់ស្លាប់ដូចគ្នា ។
ធម៌នេះតែងមានសម្រាប់លោក ដូចរោគជិតជាមតាមធម្មតា
តែមានជាតិហើយត្រូវចាំថា គង់មានមរណាចៀសពុំបាន ។
 យោបល់យ៉ាងខ្លីស្តីប៉ុណ្ណោះ បញ្ចប់ឈប់ស្ទះជាអវសាន
បើមានទៅខ្លះខ្លះសល់ខាន សូមលោកអ្នកអានគិតផងចុះ ។

---

**ផ្នែកអក្សរសាស្ត្រ**

# ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ

ឌ.. តាម

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ត

## ជំពូកទី ១

*យ៉ាងដូចម្តេចដែលគេហៅថាភាសាខ្មែរ ?*

តាមវចនានុក្រមខ្មែរ ដែលបោះផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យក្តី តាមអក្ខរានុក្រមខ្មែរក្តី អ្នកនិពន្ធមិនបានអធិប្បាយឲ្យក្បោះក្បាយនូវពាក្យ ថា ភាសា ទេ ។ អ្នកនិពន្ធគ្រាន់តែថា ភាសា គឺសំដី, ពាក្យ តែប៉ុណ្ណះ ។

ពាក្យថាភាសាមានន័យទូលាយសំខាន់ណាស់ ។ ភាសាទុកជាឯកសាររបស់មនុស្ស . ទុកជាការសំដែងនូវចិត្តគំនិតរបស់មនុស្សសត្វគ្រប់យ៉ាង ។ បើមនុស្សយើងមិនមានភាសាទេ ការទាក់ទងគ្នាដោយវាចា

ក៏មិនមានដែរ ។ កាលបើមិនមានការទាក់ទងគ្នាដោយវាចាទេ ការចំ-រើនតាមផ្លូវអក្សរសាស្ត្រ ក៏មិនមានដែរ ។ សូម្បីតែបុព្វសម័យរបស់ជនជាតិខ្មែរយើង សម័យក្រោយយុគថ្មមកហើយ ក៏នៅមិនទាន់មានការទាក់ទងគ្នាបានដាច់ហើសដែរ ។

ភាសាចាត់ទុកជាជាសម្ភារ សំរាប់ជួយក្នុងការគមនាគមន៍រកទីបំផុតគ្មាន ។ ភាសាមានសារប្រយោជន៍ធំបំផុតសំរាប់កត់ត្រាទុកនៅក្នុងសា-វតារ បើសិនជាយើងមិនមានភាសាទេ ប្រហែលជាសាវតារនគរមួយៗសាបសូន្យមិនខាន ។

ពេលនេះខ្ញុំសូមលើកយកបញ្ហាថា "តើភាសាមានដើមកំណើតមកពីណា ? នរណានាំបង្កើតឲ្យហៅឈ្មោះវត្ថុមួយៗមុនគេ ? (ដូចផ្លែស្វាយ នរណាបង្កើតឲ្យហៅឈ្មោះផ្លែឈើនេះថាផ្លែស្វាយ ) ហេតុអ្វីបានជាមនុស្សយើងមានភាសាច្រើនម្ល៉េះ ?

បញ្ហាទាំង ៣ នេះ ដូចជាពិបាកនឹងដោះស្រាយ ព្រោះថាមិនឃើញមានច្បាប់ក្បួនថាភាសាមានកំណើតពីត្រឹមណោះត្រឹមណោះតែតាមការពិចារណារបស់អ្នកប្រាជ្ញភាសាសាស្ត្រខ្លះយល់ឃើញថា ភាសាមានកំ-ណើតមកពីសង្គមមនុស្សមួយក្រុមៗ ព្រោះថាមនុស្សយើងតែមានសង្គមហើយ ត្រូវតែមានការទាក់ទងគ្នា តែមានការទាក់ទងគ្នាហើយ ត្រូវតែបង្កើតពាក្យសំដីដែលឲ្យស្ដាប់យល់ចំណាំបាន តែថាសម័យដែលសង្គមនីមួយៗ

បង្កើតបានជាភាសាហើយ មិនទាន់មានរូបអក្សរនៅឡើយទេ មាន

ត្រឹមតែសំដីពោលចេញមកពីមាត់ ៗ ដល់មកខាងក្រោយមកភាសាមាន

រូបអក្សរប្រាកដទុកជាគ្រឿងកត់ត្រាចំណាំឡើង ៗ

ចំពោះបញ្ហាទី ២ នេះ ខ្ញុំយល់ឃើញថា បើសង្គមមនុស្សមានភាសា

ការសន្មតហៅឈ្មោះអ្វីមួយ ៗ ក៏ចាប់មានទៅដែរ តែទីងឲ្យដឹងថា ឈ្មោះ

មនុស្សណាបង្កើតឲ្យហៅឈ្មោះរបស់នេះ របស់នោះមុនគេ ដូចជាពិបាក

ដែរ ៗ តែយើងគួរសន្និដ្ឋានថា ឈ្មោះវត្ថុមួយ ៗ ពិតជាហៅទៅតាមសង្គម

មនុស្ស ដែលបានឃើញហេតុកើតផលឡើង ៗ បើតាមមតិខ្ញុំយល់ថា

ប្រហែលជាគេសន្មតហៅឈ្មោះតាមកើត តាមហេតុ តាមផល ដូចយើង

ហៅ ទន្លេធំ ឬទី ក្រុងភ្នំពេញ ៗ នរណាជាមេនាំហៅពាក្យទាំងពីរនេះ

មុនគេ ? គឺមនុស្សសង្គមនេះ យល់ឃើញថាទន្លេនេះធំ ឲ្យឈ្មោះថាទន្លេ

ធំ ឯទីក្រុងភ្នំពេញ ដោយដូនពេញមកសង់វត្តនៅលើភ្នំ គេសន្មតឲ្យ

ឈ្មោះថាភ្នំដូនពេញ តែក្រោយមកឲ្យឈ្មោះថាភ្នំពេញ ចុះនរណានាំ

ហៅភ្នំពេញមុនគេ ? បែបពិបាកកេះឈ្មោះមនុស្សហៅមុនគេមិនបាន ៗ

បើយើងពិចារណាសម័យសង្គមក្រុងនិយមនេះ យើងអាចយល់

ច្បាស់ថា ពិតជាសង្គមមនុស្សនាំបង្កើតពាក្យឲ្យប្រើ ដូចជាទីក្រុងព្រះ

សីហនុ ជាដើម ៗ ដើម្បីយកព្រះនាមសម្តេចទៅដាក់ឲ្យឈ្មោះទីក្រុងនេះ

ត្រូវមានគណៈកម្មការធ្វើចុតហ្មាយថ្វាយទៅសម្តេច ជាសុំព្រះនាមយក

ទៅជាក់ឈ្មោះទីក្រុងនេះ ។ ឧទាហរណ៍នេះ ក៏អាចសន្និដ្ឋានបានថា គេហៅទៅតាមតែហេតុផល ។

ឯបញ្ហាទី ៣ យើងមិនបាច់មានសេចក្ដីសង្ស័យអ្វីទេ ព្រោះថាទៀត មានសង្គមមនុស្សច្រើន ភាសាក៏ច្រើនដែរ ។ នៅក្នុងសកលលោកនេះ មានប្រទេសជាច្រើន ដូច្នេះភាសាក៏ច្រើនដែរ សូម្បីតែជាតិដូចគ្នា ឧទាហរណ៍ដូចចិនមានភាសាច្រើន ដូចលោកអ្នកបានជ្រាបខ្លះហើយ ។

ចំពោះន័យរបស់ភាសានេះ តាមមតិលោក (Blancke ថា «Language is the instrument for the expression and communication for human thought . ភាសាជាសម្ភារសំរាប់បញ្ជាក់ឬទាក់ទងនាំគំនិតរបស់មនុស្សជាតិ » ។

តែតាមវចនានុក្រម New Webster Dictionary ថា «Any means, vocal or other, of expression or communicating feeling or thought. In the usual sense, language means system of conventionalized signs. ភាសា គឺជាសំឡេង ឬ សេចក្ដីបញ្ជាក់ ឬការគមនាគមន៍នូវសេចក្ដីសោយអារម្មណ៍ ឬ គំនិតគ្រប់វិះ តែតាមធម្មតាវិញ ភាសាគឺជាក្បួនរបស់សញ្ញាដែលគេសន្មតឲ្យប្រើ » ។

តាមសព្វវចនានុក្រមខ្លះទៀតថា « ភាសាគឺជាសំឡេងរបស់មនុស្សដែលអាចស្ដាប់បាន ដែលកើតឡើងដោយអណ្ដាតនិងសំឡេង

សោតប្បសាទ, ភាសាជារូបរាងរបស់ពាក្យ ហើយជារបៀបរៀបចំរក្សាពាក្យឲ្យគេស្ដាប់បានទៅតាមសម័យនីមួយៗ "

## ភាសាសាស្ត្រ និង អក្សរសាស្ត្រ

ពាក្យទាំងពីរនេះ កុំច្រឡំគ្នា មិនមែនមានន័យដូចគ្នាទេ តែជាពាក្យទាំងពីរនេះ ត្រូវទាក់ទងគ្នា ។

ភាសាសាស្ត្រ គឺជាក្បួនច្បាប់សំរាប់សិក្សានូវពាក្យសំដី ឫសគល់របស់ពាក្យ (Philologie) ។ ការសិក្សាស្រាវជ្រាវរកកំណើតដើមពាក្យ ថាតើពាក្យនេះមានន័យដូចម្ដេច យកមកពីភាសាជាតិណា ឬក៏គេប្រើនៅក្នុងសតវត្សរ៍ទីប៉ុន្មានជាដើម ។

អក្សរសាស្ត្រ ការសិក្សាខាងក្បួនច្បាប់អក្សរ (Litterature) ។ ពាក្យទាំងពីរនេះ មានន័យស្ទើរតែច្រឡំគ្នា ។ ខ្ញុំសូមយកឧទាហរណ៍មួយ ដូចការសិក្សានូវរឿងទុំទាវ ។ រឿងទុំទាវទាំងមូលនេះ ចាត់ទុកជាជា អក្សរសាស្ត្រខ្មែរ ។ ការស្រាវជ្រាវរឿងទុំទាវមកពន្យល់អធិប្បាយរកឫសគល់ជាដើមហៅថា ភាសាសាស្ត្រ ។

ភាសាសាស្ត្រ ដែលខ្ញុំរើយើងនិយាយនេះរៀនសព្វថ្ងៃមានពីរផ្នែក:

១- ភាសាមនុស្ស

២- ភាសាសត្វ

# ភាសាមនុស្ស

ភាសាមនុស្ស ចែកទៅមាន ៣ ផ្នែក :

១- ភាសាសង្ឃ ឬ សាសនាភាសា

២- ភាសាក្សត្រ ឬ រាជស័ព្ទ

៣- ភាសារាស្ត្រ ឬ ភាសាសាមញ្ញ

ខ្មែរយើងចេះភាសាមនុស្សហើយ ត្រូវចេះរៃលកប្រើពាក្យឲ្យត្រឹមត្រូវទៅតាមឋានៈមនុស្សទៅទៀត ។ បើសង្កេតឲ្យមែនទែនទៅឃើញថា ភាសាជាតិខ្មែរទាំង ៣ ថ្នាក់នេះ ទុកដូចជាថា ខ្មែរមានភាសាសំរាប់ ៣ ជាតិដែរ ។ ខ្មែរយើងសម្បូរពាក្យច្រើនតាល់តែរកពាក្យប្រើមិនគ្រប់គ្រាន់ ។ បានជាខ្ញុំថាដូច្នេះ ព្រោះថាដូចជាពាក្យ ស៊ី មានពាក្យ ២៤ ដែលជាវេវចនៈនឹងគ្នា នេះហើយដែលខ្ញុំថាសម្បូរ តែរកពាក្យប្រើមិនបាន ព្រោះថាឥឡូវពលភាសាបរទេសចូលមកច្រៀតជ្រែក យើងច្រើនតែយកភាសាគេមកនិយាយលាយឡំ ឬជួនកាលយើងមិនអាចប្រែមកជាភាសាខ្មែរបាន យើងក៏ទុកពាក្យបរទេសប្រើក្នុងភាសាខ្មែរ ។

១- ភាសាសង្ឃ ឬ សាសនាភាសា បុគ្គលពួកនេះ ក៏នៅមានចែកថ្នាក់ទៅទៀតដែរ ។ ឧបជ្ឈាយ៍ អាចមានពុទ្ធដីកាទៅកាន់ភិក្ខុសាមណេរ ដែលមានវស្សាតិចជាងថា "ឆាន់" ឬ "ក្តី" បាន តែសាមណេរ មិនអាចនិយាយថា "ឆាន់" ឬ "ក្តី" ទៅកាន់ភិក្ខុទេ ។

ពាក្យខ្លះដែលព្រះសង្ឃសន្ទនាក្នុងបព្វជិតនឹងបព្វជិត គឺ ករុណា, ខ្ញុំករុណា, ខ្ញុំព្រះករុណា ។ ជួនកាលនិយាយក្លាយទៅជា ក្រុណា ។

ពាក្យនៅក្នុងសាសនាទៀត មានពាក្យខ្លះប្រើបានតែចំពោះតែបុគ្គលម្នាក់ ដូចព្រះនាមព្រះពុទ្ធ "តថាគត" ពាក្យនេះប្រើបានតែចំពោះព្រះពុទ្ធទេ គេមិនយកមកប្រើចំពោះបុគ្គលទូទៅឡើយ ។

២- ភាសាក្សត្រ ឬ រាជស័ព្ទ យើងភ្ជាប់ហៅមកហើយថា (ពាក្យសំរាប់ប្រើនៅក្នុងរាជត្រកូល) រាជស័ព្ទ ។ រាជស័ព្ទ គឺជាពាក្យដោយឡែកដែលគេប្រើបានចំពោះតែត្រកូលក្សត្រ ។

១. សោយ - យាង - ផ្ទំ ជាដើម

បើចង់ជ្រាបឲ្យបានពិស្តារ សូមអានសៀវភៅរាជស័ព្ទដែលបោះពុម្ពផ្សាយពីពុទ្ធសាសនបណ្ឌិត្យ ។

បើពាក្យរាស្ត្រសាមញ្ញប្រើដែរនោះ តែគេយកទៅប្រើជារាជស័ព្ទ គេច្រើនតែយកពាក្យ "ព្រះ" ឬ "រាជ" មកធ្វើជាបុព្វបទ ។

១. រថ គេប្រើជាមួយពាក្យរាស្ត្រដែរ បើយកទៅប្រើជារាជស័ព្ទ ត្រូវដាក់ពាក្យថា "រាជរថ" ឬ "ព្រះរាជរថ" ឬក៏ "ព្រះទីនាំង" ។

៣- ភាសារាស្ត្រ ឬ ភាសាសាមញ្ញ ភាសាចំពូកនេះគឺ សំដៅយកភាសាមនុស្សទាំងពីរប្រភេទផ្នែកគ្រហស្ថ :

១- ភេទបុរស

២- ភេទស្រី

មនុស្សទាំងពីរប្រភេទនេះ មានចែកថ្នាក់ទៅទៀត តែពេលនេះខ្ញុំសុំបរិយាយយ៉ាងសង្ខេបនូវភាសាពួកនេះ

ក) ភេទប្រុស មានពាក្យផ្សេងៗ សំរាប់បុគ្គលពួកនេះនិយាយៗ ដូចពាក្យថា "ខ្ញុំបាទ" ជាដើម ពាក្យនេះសំរាប់តែបុរសទេ មិនអាចយកទៅប្រើជាមួយស្រី ឬ បព្វជិតឡើយ ។

ខ) ភេទស្រី មានពាក្យខ្លះសំរាប់តែមនុស្សពួកនេះប្រើ គេមិនយកទៅប្រើលាយឡំជាមួយភេទប្រុស ឬ បព្វជិតឡើយ ។ តែពាក្យថា "ខ្ញុំ" ពុំអាចយកមកនិយាយបានដែរ តែតាមការត្រឹមត្រូវ គួរតែថា "នាងខ្ញុំ"

ភាសាមនុស្សចែកទៅតាមឋានៈ មនុស្សមាន ៣ ថ្នាក់:

១- ថ្នាក់ខ្ពស់ ,

២- ថ្នាក់កណ្ដាល ,

៣- ថ្នាក់ទាប ។

ខ្ញុំសូមជូនភាសាដែលមនុស្សទាំង ៣ ក្រុមនិយាយទាក់ទងគ្នាយ៉ាងសង្ខេប :

ពាក្យថា "ខ្ញុំបាទ, ខ្ញុំព្រះបាទ, ខ្ញុំព្រះបាទម្ចាស់ ។

ខ្ញុំបាទ - មន្ត្រីសក្តិតូច ឬរាស្ត្រ និយាយទៅកាន់មន្ត្រីសក្តិធំ ឬក៏·

កស្ត្រនិយាយទៅកាន់កស្ត្រជាទីគោរពបាន ។

ខ្ញុំព្រះទាន – មន្ត្រីមានយសសក្តិធំ តែមិនមែនជារដ្ឋមន្ត្រី រដ្ឋលេខាធិការ ត្រូវនិយាយទៅកាន់រដ្ឋមន្ត្រី ។ ឯកស្ត្រសាមញ្ញក៏និយាយទៅកាន់មន្ត្រីសក្តិធំ ដែលមិនមែនជារដ្ឋមន្ត្រីថា ខ្ញុំព្រះបាទបាន ។

ខ្ញុំព្រះទានម្ចាស់ – សំរាប់មន្ត្រីសក្តិតូច ឬកស្ត្រនិយាយទៅកាន់រដ្ឋមន្ត្រី ។

ការសរសេរលិខិតអំពីការសក្តិនាម៉ឺនសព្វមុខមន្ត្រី ឬ ជនសាមញ្ញ សូមគានប្រជុំលិខិតដែល ឯ. ឧ. មហាមន្ត្រី ញិកា · ឆ្នាំ តែង ។

ឯកសាសក្ត ខ្ញុំនឹងអធិប្បាយទៅខាងក្រោយ ។

## ភាសាជាគមនាគមន៍

១– វិញ្ញាតិភាសា. ឧបមាថា មនុស្សបរទេសម្នាក់ជាទេសចរ មកប្រទេសកម្ពុជា មិនចេះភាសាខ្មែរសោះ ហើយថែមទាំងមិនចេះច្បាប់ចរាចរនៅប្រទេសកម្ពុជាទៀតផង ។ មនុស្សនេះដើរតុក ៗ តាមផ្លូវ ដោយមិនបានគិតថានឹងមានគ្រោះថ្នាក់ ដែលបណ្តាលមកពីរថយន្តស្រាប់តែក្នុងពេលជាមួយគ្នានោះ រថយន្តមួយបើកយ៉ាងលឿនសំដៅមកអ្នកថ្មើរជើង ហើយចាប់ហ្វ្រាំងឌឹត ហើយខ្មែរម្នាក់ស្រែក "វៃ៎" ជាមួយសំ-

ឡេងប្រហ៊ាំង អ្នកទេសចរអាចយល់បានថា "គ្រោះថ្នាក់" ។ សំរែកនេះក៏ចាត់ទុកថាជាភាសាសាស្ត្រដែរតែមិនមានព្យញ្ជនៈ ។

ម្យ៉ាងទៀត អ្នកធ្វើដំណើរតាមរថយន្ត អ្នកមុខតែឃើញមានសញ្ញាចរាចរប្រាប់អ្នកបើកបររថយន្ត ។ បើមិនមានសញ្ញាទាំងនេះទេ អ្នកបើកបររថយន្ត មុខតែចៀសមិនផុតពីគ្រោះថ្នាក់ឡើយ ។ សញ្ញាទាំងអស់នេះមិនមែនសុទ្ធតែជាអក្សរទេ គេច្រើនតែប្រើសញ្ញាជាគំនូស ដូចជាសញ្ញាក្មេងពីរនាក់កាន់ដៃគ្នាជាដើម ។ សញ្ញាក្មេងកាន់ដៃគ្នានេះប្រាប់ថា "ឲ្យបន្ថយល្បឿនរថយន្ត ព្រោះជិតសាលារៀន" ។

បើសង្កេតឲ្យឃើញវែងឆ្ងាយទៅទៀត នៅតាមមហាវិថីព្រះបាទនរោត្តម អ្នកបើករថយន្ត ត្រូវគោរពច្បាប់ចរាចរដែលរាជការប្រើភ្លើងជាសញ្ញា ភ្លើងក្រហម ត្រូវ "ឈប់!" ភ្លើងលឿងត្រូវ "ប្រុង!" ភ្លើងខៀវ ត្រូវ "ទៅ! ដើរ! បើកបរ!" បាន ។ ឯអ្នកចរាចរវិញ ត្រូវដើរឆ្លងកាត់ផ្លូវនៅក្នុងគំនូសដែលគូសកាត់ទទឹងថ្នល់ ។

ភ្លើងទាំងនេះ សញ្ញាទាំងនេះមានអក្សរឬទេ ? គ្មានទេ ចុះម៉េចបានជាមាន "ឈប់!" មាន "ប្រុង!" មាន "ទៅ!" ថាមកពីភ្លើង មកពីសញ្ញា ប្រាប់ឲ្យប្រតិបត្តិតាម ដូច្នេះឃើញថាជាភាសាមួយដែរ ។

សញ្ញាទីន៍ៗពានស័ព្ទ ដែលមិនមានពាក្យព្យញ្ជនៈបង្ហាញប្រាប់ តែជាសំឡេង-សញ្ញាអន្តរជាតិស្គាល់យល់បាន គេហៅថា "វិញ្ញាតភាសា"

២– កាយវិការភាសា (Gesture for Words) មនុស្សនៅក្នុងសាកលលោកនេះមានកាយវិការមិនសូវដូចគ្នាទេ ក្នុងការនិយាយពាក់ទងរវាងមនុស្សនឹងមនុស្ស ៗ មនុស្សដែលមិនចេះភាសា អាចដោះទាល់ម្តង ៗ ដែរ ក្នុងការសំដែងកាយវិការជំនួសភាសា ។ យើងពិនិត្យមើលមនុស្សគ តើគ្នាចេះនិយាយភាសាអ្វីឬទេ ? តែមនុស្សគអាចធ្វើកាយវិ-ការឲ្យគេយល់ថាខ្លួនត្រូវការនេះ ត្រូវការនោះ, តាមកាយវិការរបស់គាត់ ភាសានេះចាត់ថាជា ភាសាគ ។

(នៅមានត)

## ពាក្យខ្មែរប្រែពីបរទេស

# ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ " ក "

( តមក )

| | | |
|---|---|---|
| Exposé préliminaire | | សេចក្ដីថ្លែងប្រារព្ធ (ព-ប្ញ-) : សេចក្ដីថ្លែងគោលៗ ជាដំបូង ។ |
| Exproprier | (v.) | អស្សាមីក្រឹត : ដកកម្មសិទ្ធិ |
| Expropriation | (n.f.) | អស្សាមីករណ៍ : ការដកកម្មសិទ្ធិ |
| Etranger | (n.m.) | អ្នកបរទេស |
| Faire exécuter la peine | | ធ្វើទោស (ព-ប្ញ-) |
| Famille nombreuse | | គ្រួសារច្រើន : គ្រួសារដែលមានសមាជិកច្រើន |
| Interpréter | (v.) | សំដែង (ព-សិល្បៈ) |
| Interprétation | (n.f.) | ការសំដែង (ព-សិល្បៈ) |
| Livre | (n.m.) | សៀវភៅ |
| Livre | (n.m.) | គន្ថ (ព-ប្ញ-) : ចំណែកនៃសៀវភៅ,ចំណែកនៃក្រម ។ ៖ ក្រមព្រហ្មទណ្ឌមាន ៤ គន្ថ, ក្រមរដ្ឋប្បវេណីមាន ៣ គន្ថ ។ |
| De multiples familles | | គ្រួសារពហុគុណ: គ្រួសារច្រើនក្រុម ។ ពួកអ្នកទេសជាតិ ផ្គុំគ្នាជាគ្រួសារពហុគុណ ។ |
| National | (n.m.) | អ្នកទេសជាតិ: ពលរដ្ឋរបស់ប្រទេសណាមួយ។ ៖. កុងស៊ុលតែងការពារផលប្រយោជន៍នៃអ្នកទេសជាតិខ្លួន ។ |

(នៅមានតទៀត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង . ទាត់ រៀបរៀង*

( តមក )

---

អតិវិសារិន៑ គុ. ដែលផ្សាយ, ដែលទូលាយ ។

អតិវិស្ដរ បុ. ពិស្ដារក្រៃលែង ។

អតិវិស្ដីណ៌ គុ. ដែលលាតក្រៃលែង, ដែលទូលាយក្រៃលែង ។

អតិវិស្មយ គុ. ដែលគួរឆ្ងល់ក្រៃលែង, ដែលគួរសង្ស័យក្រៃលែង ។

អតិវិស្មិត គុ. ដែលឆ្ងល់ក្រៃលែង ។

អតិវិហ្វល គុ. ដែលជ្រួលច្របល់ក្រៃលែង ។

អតិវីរ គុ. វីរៈក្រៃលែង, ដែលក្លៀវក្លាក្រៃលែង ។

អតិវីយ៌ គុ. ដែលក្លៀវក្លាក្រៃលែង ។–វន្ត៑, គុ. ដែលមានសេចក្ដីក្លៀវក្លាក្រៃលែង ។

អតិវ្យូហិត គុ. មើលអតិព្យូហិត ។

អតិវ្ឫត៑ ធាគុ. ប្រព្រឹត្តកន្លងក្រៃលែង ។

អតិវ្ឫត្ត គុ. ដែលប្រព្រឹត្តកន្លងក្រៃលែង ។

អតិវ្ឫត្តិ ស្ត្រី. កិរិយាប្រព្រឹត្តកន្លងក្រៃលែង ។

(នៅមានទៀត)

# រឿងសាមកុក

## កំណាត់ទី ២៨

ឧកញ៉ាវិបុលរាជសេនា ញ៉ុក-ថែម ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះទហយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ-អ៊ុន

ជីវយ៉េឃើញសេចក្តីក្នុងសំបុត្រដូច្នោះ ក៏ដកដង្ហើមធំឈឺនឹកក្នុងចិត្តខ្លាំងណាស់ ពិសព្រួញក៏កំរើកឡើងជួលសន្ធប់ទៅ ៗ ពាហ៊ានដែលនៅជិតខាង ក៏កៃខ្សៀងស្មារតីឡើងវិញ ៗ ជីវយ៉េដឹងខ្លួនថា មុខជាមិនរស់រួចជីវិត ក៏តាំងសរសេរសំបុត្រទុកមួយច្បាប់ ហើយបង្គាប់នាយទ័ពនាយកងទាំងពួងទុកថា យើងខំធ្វើការទាំងម៉្លេះ ព្រោះតាំងចិត្តគិតនឹងទំនុកបំរុងស៊ុនគួនដោយស្មោះត្រង់ តែគិតទៅមិនចុះជាយ គ្រានេះជីវិតយើងវិនាសអន្តរាយហើយ អ្នកទាំងឡាយនៅឯក្រោយ ក៏ត្រូវជួយទំនុកបំរុងចៅហ្វាយយើង ឲ្យបានសម្រេចតាមការដែលគិតនោះផង ចុះអ្នកចូរយកសំបុត្រនេះទៅឲ្យស៊ុនគួនថា យើងសូមគំនាប់លាហើយ ៗ

ជីវយើផ្តាំតែប៉ុណ្ណេះ ពិសព្រញក៏រត់សព្វសាច់សទ្ទប់បាត់ស្មារតីម្តងទៀត, ទើបបានវិលដឹងស្មារតីឡើងវិញ, ជីវយើគ្នាន់ក្តាញ់ឈឺក្នុងចិត្តណាស់ ក៏ងើយមើលទៅលើអាកាសហើយស្រែកថា “ទេវតាអង្គណាហ្ន៎! ដែលឲ្យយើងកើតមកហើយម្តេចឡើយក៏ឲ្យខ្ញុំរងកើតមកជួបដូច្នេះ” , ជីវ· យើស្រែកប្រកាសដូច្នេះជាច្រើនមាត់ ដោយចិត្តខឹងខ្លាំង ពិសព្រញក៏តាំងតែជ្រួតជ្រាបសព្វសព៌ាង្គកាយ ក៏ដល់នូវសេចក្តីអន្តរាយជីវិតក្នុងខណៈនោះ ក្នុងអាយុគម្រប់៣៦ ឆ្នាំ ។

បណ្តាពួកនាយកងនាយទ័ព ក៏លើកត្រឡប់នាំសពជីវយើទៅទុកដាក់តាមបណ្តាសក្តិនាហ៊ឺនធំ ។ ឯបំរើក៏នាំសំបុត្រដែលជីវយើសរសេរនោះទៅឲ្យស៊ុនគួន ហើយសាស័ព្ទប្រាប់សេចក្តីឲ្យស៊ុនគួនគ្រប់ប្រការ ។ ឯស៊ុនគួន កាលបើដឹងថា ជីវយើស្លាប់ដូច្នោះ ក៏យំសោកសោកឡោះអាល័យឥតឧបមា ហើយយកសំបុត្រនោះមកមើលឃើញសេចក្តីថា “ខ្ញុំបាទជីវយើសូមគំនាប់មកដល់លោក ព្រោះលោកមេត្តាតាំងខ្លួនខ្ញុំឲ្យធ្វើមេទ័ពធំ និងប្រជុំប្រឹក្សាការរាជការទាំងពួង នោះព្រះតេជព្រះគុណធ្ងន់មិនមានទីបំផុត ខ្ញុំបាទក៏តាំងចិត្តធ្វើការដោយចិត្តស្មោះត្រង់ ប៉ងនឹងតបស្នងសងគុណលោកឲ្យបាន តែគ្រានេះ ការរបស់លោកទាំងប៉ុន្មានក៏នៅមិនទាន់ស្រេច ខ្ញុំមានអកុសលកម្មនាំមកផ្តាច់ឲ្យអស់ជីវិតទៅ ដោយសេចក្តីទុក្ខក្តៅក្នុងចិត្ត ទោះបើជីវិតខ្ញុំនឹងស្លាប់ក៏គ្មានគិតស្តាយប៉ុន្មាន តែគិតរំខានព្រោះ

មិនបាននៅជួយធ្វើការលោកតទៅ ព្រោះសព្វថ្ងៃនេះផែនដីក៏នៅមិនទាន់រាបទាបឯទិសខាងជើង ចូច្ចក៏បានជាធំនៅក្នុងស្រុកហ្វូគោមានចក្ករករាយណាស់ ឯឡាតីដែលនៅក្នុងស្រុកគេងជីវ ក៏ដោយសារស្រុកកាំងតាំងជួយជាកម្លាំងផងទើបបានសេចក្តីសុខ លោកនឹងបង្អង់ទុកក៏ដូចជាចិញ្ចឹមខ្លាសាហាវ អំណើះតទៅគង់នឹងមានកម្លាំងពីខាងក្រៅត្រឡប់ជាសត្រូវនឹងលោកវិញ ក្នុងស្រុកយើងក៏មិនបានសម្រេចការអ៊ីសោះ ព្រោះនាហ្មឺនក្នុងស្រុកកាំងតាំងសព្វថ្ងៃនេះ បើសំឡឹងមើលក៏ពុំឃើញនរណាអាចទទួលមុខងារជំនួសខ្ញុំបាន ឃើញមានតែឡោសុកមួយ មានតម្រេះប្រាជ្ញាមាំមួនសមសួនជាធំ ព្រោះជាមនុស្សរៀនគ្រង់សុចរិត សូមឲ្យលោកតាំងចិត្តរាប់អានឡោសុក ហើយតាំងជាមន្ត្រីធំជំនួសខ្ញុំចុះ បើលោកនឹងអនុគ្រោះ ក៏សូមឲ្យធ្វើតាមខ្ញុំគ្រប់ប្រការ ។

ស៊ុនគួនឃើញសេចក្តីក្នុងសំបុត្រដូច្នោះក៏ថា ជីវយីនេះមានតម្រេះប្រាជ្ញាណាស់ គួរទទួលតំណែងជាមហាឧបរាជបាន តែមកមានអាយុខ្លីគួរគប្បីឲ្យស្តាយពន់ពេកណាស់ វេលានេះយើងនឹងបាននរណាមកជួយរិះគិតធ្វើការតទៅទៀត ដែលជីវយីផ្តាំទុកនោះសោត យើងក៏យល់ស្របដែរ ។ ខណៈនោះ ស៊ុនគួនក៏តាំងឡោសុកជានាហ្មឺនធំជំនួសជីវយី ហើយក៏ឲ្យទាហានទៅទទួលសពជីវយីមកសែនព្រេនតាមទំនៀមក្នុងស្រុកផងសងគុនតាមបណ្តាសក្តិនាហ្មឺនធំ

ឯខុនបេងនោះ លុះដីវយើលើកទ័ពទៅហើយ ក៏នាំឡៅតីចុះពីលើភ្នំត្រឡប់ទៅស្រុកគេងដីវ លុះវេលាយប់ខុនបេងក៏ពិគ្រោះមើលឫក្សលើអាកាស ក្រឡេកឃើញផ្កាយធ្លាក់ចុះពីលើអាកាសមួយដួង, ខុនបេងអស់សំណើចហើយប្រាប់ឡៅតីថា ដីវយើស្លាប់ក្នុងថ្ងៃនេះហើយ ។ ទទួលទាហានដែលស៊ើបការចូលមកជំរាបថា ដីវយើស្លាប់ទៅហើយ ។ ឡៅតីក៏ប្រឹក្សានឹងខុនបេងថា យើងនឹងគិតធ្វើដូចម្តេច ? ។ ខុនបេងថា ដីវយើស្លាប់ទៅហើយ ឃើញតែឡោសុកមួយនឹងបានជាជំនួសដីវយើ, មួយទៀតខ្ញុំបានមើលឫក្សលើអាកាស ឃើញផ្កាយទៅប្រជុំគ្នានៅទិសខាងកើត ចាំខ្ញុំនឹងទៅសួរសពដីវយើឯស្រុកកាំងតាំង នឹងបានស៊ើបរកអ្នកមានតម្រេះប្រាជ្ញាបញ្ចុះបញ្ចូលមកជួយធ្វើការនឹងលោក ។

ឡៅតីឆ្លើយតបទៅខុនបេងវិញថា ដែលលោកនឹងទៅស្រុកកាំងតាំងនោះ ខ្លាចក្រែងនាហ្មឺនមុខមន្ត្រីនឹងទាហានធ្វើអន្តរាយដល់លោក ។ ខុនបេងឆ្លើយថា អំបាលដីវយើរស់នៅម្តេចខ្ញុំទៅបានមិនខ្លាច ឥឡូវដីវយើស្លាប់ទៅហើយនឹងត្រូវកោតខ្លាចនរណាទៀត ហើយខុនបេងក៏បង្គាប់ដូឡុងឲ្យលើកទាហាន ៥០០ នឹងរៀបចំរុំងគ្រឿងព្លីការទៅជាមួយផង, លុះចុះទូកទៅដល់កណ្តាលផ្លូវ បានឮដំណឹងអ្នកស្រុកតាមផ្លូវនិយាយថា ស៊ុនគួន តាំងឡោសុកជានាហ្មឺនធំ ជំនួសដីវយើ, ឯសពដីវយើ ស៊ុនគួនឲ្យនាំទៅទុកឯស្រុកឆសង់គុន ។ ខុនបេងឮដូច្នោះ ក៏ឲ្យបេវទូកជម្រង់

ទៅស្រុកឆសងគុន ។

ឡោសុកដឹងថា ខុនផែនទៅដល់ ក៏ចុះទៅអញ្ជើញឲ្យឡើងមកគំនាប់គ្នាតាមទំនៀម ។ ឯទាហានដីវ៉យក្រឡេកឃើញមុខខុនផែន ក៏ខឹងក្តៅខ្លាំងណាស់ គិតនឹងសម្លាប់ខុនផែន តែឃើញជួឡុងឈរកាន់ក្របីទៅជិតជិតជាប ក៏ញញើតខ្លាចនឹងធ្វើអន្តរាយមិនបាន ។ លុះខុនផែនទៅដល់សពដីវ៉យហើយ ក៏សែនព្រេនតាមទំនៀម ហើយធ្វើជាយំសោកអាឡោះអាល័យខ្លាំងណាស់ ។ ពួកទាហានដីវ៉យ ឃើញខុនផែនយំសោកដូច្នោះក៏និយាយគ្នាថា ខាងក្រៅឮល្បីគេនិយាយថា ខុនផែននឹងដីវ៉យជាសត្រូវនឹងគ្នា ឥឡូវខុនផែនមកសែនព្រេនឲ្យដីវ៉យ ហើយយំសោកអាឡោះអាល័យដូច្នេះ ក៏ឃើញថា ខុនផែននេះ មានចិត្តសុចរិតនឹងដីវ៉យ មិនសមនឹងពាក្យដែលឮល្បីថា សត្រូវនឹងគ្នានោះ ។ ឡោសុកឃើញខុនផែនធ្វើអាការសៅសោកខ្លួញយំដូច្នោះ ក៏យំសោកអាណិតជាមួយនឹងខុនផែន ហើយគិតថា ខុនផែននេះ ចិត្តល្អសុភាពល្អណាស់ គ្មានការអាឃាតព្យាបាទសោះ, ឯដីវ៉យជាមនុស្សមានចិត្តឫស្យាព្យាបាទ គេតាល់តែស្លាប់ខ្លួន, ឡោសុកលុះគិតដូច្នោះហើយ ក៏ឲ្យរៀបតុលៀងអាហារអញ្ជើញខុនផែនបរិភោគ, លុះរួចហើយ ខុនផែនក៏លាឡោសុកទៅវិញ ។

ឯចុំងចង ក្រឡេកឃើញខុនផែនក៏ដើរចូលមក ចាប់ជាយអាវខុន-

បេនះហើយអស់សំណើចថា អ្នកក្លែងធ្វើកលឧបាយឲ្យដីរយើឈឺចិត្តពាល់តែដាច់ខ្យល់ស្លាប់ ហើយថែមទាំងមកក្លែងធ្វើជាសែនព្រេន ទួញយំអាឡោះអាល័យដីរយើទៀត អ្នកធ្វើការចំអកឡកឡឺយមើលងាយគេដូច្នេះ ឃើញថាស្រុកកាំងតាំងនេះ គ្មានមនុស្សដឹងដល់កលឧបាយរបស់អ្នកទេឬ ? ។

ខុនបេនតក់ស្លុតក្នុងចិត្ត ក៏ក្រឡេកមើលទៅឃើញបាំងថងជាកឿនសម្លាញ់ ក៏សោយសេចក្ដីភ័យបារម្ភ ទើបអស់សំណើច ហើយដឹកដៃបាំងថងចុះទៅអង្គុយក្នុងទូក សន្ទនាគ្នាដោយសេចក្ដីរីករាយយ៉ាងក្រៃលែង ហើយខុនបេនក៏សរសេរសំបុត្របិទស្រោមបោះត្រាប្រគល់ទុកឲ្យបាំងថងមួយច្បាប់ ហើយផ្ដាំពាក្យក្រៅសំបុត្រនោះថាបើស៊ិនគួនមិនបានយកអ្នកទុកធ្វើការពេជការទេ ឬក៏អ្នកមិនពេញចិត្តដោយប្រការយ៉ាងណា ក៏ឲ្យអ្នកអញ្ជើញទៅស្រុកកេនដីវចុះ ដើម្បីនឹងជួយគ្នាធ្វើការពេជការទំនុកបំរុងផែនដីទៅពីតទៅមុខ ទៀតក៏នឹងបានជាជំ មិនបង់កម្លាំងដែលអ្នកបានរៀនចេះដឹងមកជាមួយគ្នា បើអ្នកទៅហើយមិនបានជួបនឹងខ្ញុំ ក៏ឲ្យយកសំបុត្រនេះទៅបង្ហាញទៀតចុះ ។ បាំងថងក៏ទទួលពាក្យថាព្រមទៅ ។ ខុនបេនក៏លាទៅស្រុកកេនដីវិញ ។

ឯឡោសុក ក៏ជូនដំណើរសេពដីរយើទៅដល់ដំបន់ប៊ូតាវ ។ ស៊ិនគួនក៏ឲ្យចាត់ចែងទ្រព្យរបស់ទៅសែនសេពដីរយើ ហើយក៏យំសោកចំពោះសេពដីរយើយ៉ាងខ្លាំង រួចបង្គាប់ពួកទាហានឲ្យកែងការសេពដីរយើតាម

បណ្ដាស័ក្ដិបញ្ចុះទុកនៅត្រង់ស្រុកកំណើត ហើយយកជីវស៊ុន ជីវអ៊ុន កូនជីវយ៉ីទាំងពីរមកចិញ្ចឹមព្យាបាល ។

ថ្ងៃមួយ ទ្បាស៊ុកបាននិយាយនឹងស៊ុនគួនថា ដែលលោកតាំងខ្លួនខ្ញុំជំនួសជីវយ៉ីនោះ ជាគុណធ្ងន់រកទីបំផុតគ្មាន តែតម្រិះប្រាជ្ញារបស់ខ្ញុំតិចណាស់ មិនដឹងដល់ផ្លូវរាជការ ខ្ញុំនឹងសុំទៅអញ្ជើញអ្នកមានតម្រិះប្រាជ្ញាម្នាក់ឈ្មោះបាំងថង មកឲ្យនៅជួយធ្វើការលោក ឈ្មោះនេះនឹងខ្ញុំក៏ជាគឿនសម្លាញ់នឹងគ្នាមកពីដើម ចេះដឹងមើលលក្ខណៈបុគ្គល ខាងលើអាកាសនឹងក្រោមផែនដី ដោយតម្រិះប្រាជ្ញាធ្លៀវធ្លាតណាស់ បានរៀនវិជ្ជាសិល្បសាស្ត្រនេះគ្រូជាមួយនឹងខុងបេង សូម្បីខុងបេងនឹងជីវយ៉ីក៏រមែងស្រឡាញ់រាប់អាន, ពីដើមបាំងថងនៅស្រុកសុងយ៉ុង ឥឡូវចូលមកនៅស្រុកយើង ។

ស៊ុនគួនឮទ្បាស៊ុកនិយាយដូច្នោះ ក៏ពេញចិត្តណាស់ថាៈ យើងបានឮឈ្មោះនេះមកយូរហើយ ចូរអ្នកឲ្យទៅអញ្ជើញចូលមកចុះ ។ ទ្បាស៊ុកក៏ទៅអញ្ជើញបាំងថងចូលទៅជួបនឹងស៊ុនគួន តំនាប់ហើយស៊ុនគួនក៏សំឡឹងមើលរូបភាពលក្ខណៈបាំងថង ឃើញចិញ្ចើមធំច្រមុះគោង មុខខ្មៅ ពុកចង្កាខ្លី រូបរាងវិកលណាស់ ចិត្តមិនសូវត្រេកអរ ស៊ុនគួនក៏សួរថា តម្រិះដែលអ្នកបានរៀនចេះដឹងមកនោះ យកអ្វីជាគោលចារិក ? ។ បាំងថងថា ដែលខ្ញុំយកជាគោលចារិកលើសជាង

តាំងអស់នោះ ក៏សុទ្ធតែជាការប្រមាណ លុះតែមានការមកដល់ ទើបគិតឃើញតទៅ ។

ស៊ិនគួនសួរថា វិជ្ជាសិល្បសាស្ត្រដែលអ្នកសិក្សារៀនមកនោះ ហើយនឹងតម្រេះដីវយើប្លែកគ្នាយ៉ាងណា ? ។ ប៉ាំងថងថា វិជ្ជាសិល្បសាស្ត្រដែលខ្ញុំរៀនមក ខុសគ្នានឹងតម្រេះដីវយើច្រើនណាស់ ។ ស៊ិនគួនឮដូច្នោះ ហេតុតែចិត្តទៅស្រឡាញ់អាល័យដីវយើច្រើន ក៏ស្តាប់មិនពេញចិត្ត ហើយប្រាប់ប៉ាំងថងថា អញ្ជើញអ្នកចេញទៅសិនចុះ បើមានការអាសន្នទៅខាងមុខ សឹមឲ្យអញ្ជើញអ្នកមកជួយរិះគិតការនោះៗ ។ ប៉ាំងថងឮដូច្នោះ ក៏ដកដង្ហើមធំ ហើយដើរចេញទៅវិញ ។

ឡោស៊ុកឃើញប៉ាំងថងដើរចេញទៅ ក៏សួរស៊ិនគួនថា ហេតុម្តេចលោកមិនយកប៉ាំងថងទុកធ្វើពជការផង ? ។ ស៊ិនគួនថា ខ្ញុំពិនិត្យមើលរូបកង មិនសមជាអ្នកមានតម្រេះប្រាជ្ញាសោះ ហើយនិយាយក្រអឹតក្រអោង បើនឹងយកទុកក៏មិនឃើញបានជាការអ្វី ។ ឡោស៊ុកថា គ្រាកាលចូចូលើកទ័ពទូកមកច្បាំងនឹងស្រុកយើងពីថ្ងៃមុន ប៉ាំងថងបានទៅជួយដីវយើ ប្រើឲ្យចាយទៅបញ្ឆោតចូចូ បានជាដីវយើផុតទ័ពចូចូស្លាប់ទាហានជាច្រើន ខ្ញុំឃើញថា ប៉ាំងថងមានគុណគាប់ប្រសើរណាស់ សូមឲ្យលោកត្រិះរិះគិតមើលសិន ។

ស៊ិនគួនថា ចូចូធ្វើការគ្រានោះ ព្រោះគំនិតចូចូខ្លួនឯង មិនមែនជា

គំនិតប៉ាំងចងទៅបញ្ឆោតទេ ។ ទេព្យសុកទៅជួបនឹងប៉ាំងចងហើយថា ខ្ញុំបានជួយទំនុកបំរុងអ្នកគឺអស់ប៉ុណ្ណឹងហើយ ស៊ិនគួនមិនព្រមយកអ្នកទុកជាគ្នា ចូរអ្នករង់ចាំស្តាប់ការបន្តិចទៅទៀតចុះ ។ ប៉ាំងចងឮទេព្យសុកនិយាយដូច្នោះ ក៏ឡេនជាក់មុខទឹកគួរចិត្ត មិនបាននិយាយតបប្រការម្តេច ចេះតែដកដង្ហើមធំ ។ ទេព្យសុកថា ខ្ញុំឃើញកិរិយាអាការក្នុងខ្លួនអ្នក មុខជាមិនចង់នៅក្នុងស្រុកកាំងកាំងហើយ អ្នកក៏មានវិជ្ជាសិល្បសាស្រ្ត ប្រកបដោយតម្រេះប្រាជ្ញាចូរពិគ្រោះពិចារណាមើលចុះ បើឃើញថានឹងទៅខាងទីណាដំបន់ណាស្រួល ក៏ចូរទៅនៅតាមអធ្យាស្រ័យអ្នកចុះ ។

ប៉ាំងចងឮដូច្នោះក៏ឆ្លើយថា ចិត្តរបស់ខ្ញុំចង់ទៅនៅទីងចូធូ ។ ទេព្យសុកថា អ្នកមានតម្រេះប្រាជ្ញាភ្លឺថ្លាដូចកែវដ៏ល្អពិសេស, បើអ្នកទៅនៅទីងចូធូនោះ បីដូចជាទៅនៅក្នុងទីងងឹត មិនគួរសមទេ សូមអ្នកទៅនៅឯស្រុកកេងជីវ នៅធ្វើការជាមួយទេព្យពីវិញ នឹងមានប្រយោជន៍ចំណេញដល់ខ្លួនអ្នក ។ ប៉ាំងចងថា សេចក្តីគិតក្នុងចិត្តខ្ញុំ ក៏គិតដូចអ្នកថា តែដែលខ្ញុំថាទៅនៅទីងចូធូនោះ ហាក់នឹងចង់ពិសោធចិត្តអ្នកមើលទេតើ ។ ទេព្យសុកថា បើដូច្នោះសឹមខ្ញុំធ្វើសំបុត្រមួយទៅដល់ទេព្យពី ផ្ញើអ្នកឲ្យទៅជួយទំនុកបំរុងទេព្យពី ដើម្បីមិនឲ្យទេព្យពីនឹងស៊ិនគួនទៅហ្វាយខ្ញុំជាហរិចិត្តទាំងសងខាង ជួយរំលាងបំផ្លាញចូធូចេញ ។ ប៉ាំងចងថា គំនិតរបស់អ្នកគិតនោះ ដូចជាគំនិតរបស់ខ្ញុំគិតដែរ សុំឲ្យអ្នកសរសេរសំបុត្រទៅចុះ

ឡោសុកក៏សរសេរសំបុត្រឲ្យប៉ាំងថង ។ ទទួលហើយក៏ទៅស្រុកកេងជ័រ ប៉ិងទីងចូលទៅជួយឡៅតី ។

វេលានោះ ជួនជា ខុនបេងមិនទៅ ចេញទៅជំរះសេចក្តីដោះទុក្ខ ក្រសួងខែត្រតាំង ៤ ។ នាយទ្វារ ក៏ចូលទៅជំរាបឡៅតីថា ប៉ាំងថង មកពីស្រុកកាំងតាំង មានការមករកលោក ។ ឡៅតីដឹងប៉ាំងថងមករក ក៏និយាយថា ខ្ញុំឮល្បីគេនិយាយមកយូរហើយ តែមិនដែលជួបមុខសោះ, ក៏ឲ្យនាយទ្វារអញ្ជើញប៉ាំងថងចូលមក ។ ខណៈនោះ ប៉ាំងថងក៏មិនបាន គួរសមគំនាប់តាមប្រក្រតីឡើយ ។ ឡៅតីបានពិនិត្យមើលលក្ខណៈសព្វគ្រប់ ក៏ឃើញអាការៈជាទុចរិតកាយ ក្នុងចិត្តពុំសូវត្រេកអររីករាយ ក៏ក្លែងនិយាយថា អ្នកមករកយើងពីស្រុកឆ្ងាយ យើងក៏មិនទាន់ទាន់មានធុរៈអ្វីនឹងត្រូវការ ។

ប៉ាំងថងឃើញឡៅតីមិនសូវរាក់ទាក់រាប់អាន ក៏ទោមនស្សក្តួចចិត្ត មិនយកសំបុត្ររបស់ខុនបេងនឹងឡោសុកបង្ហាញឲ្យឡៅតីឡើយ គ្រាន់តែនិយាយថា ខ្ញុំឮល្បីថា មារបស់ព្រះចៅហៀនគេនេះ រមែងបញ្ចុះបញ្ចូលមនុស្សដែលមានតម្រេះប្រាជ្ញ នឹងសេនាទាហានដែលមានថ្វីដៃខ្លាំងពូកែណាស់ ខ្ញុំក៏ឧស្សាហ៍ស្ទុះស្ទៀងមករក ។

(នៅមានត)

# រឿងព្រេងចិន

លោក ហ៊ុយ-ប៊ុគា ប្រែរៀបរៀង

(តមក)

តែដោយមានព្រឹត្តិការណ៍ដូច្នោះ, ព្រះអង្គមិនអាចនឹងធ្វើព្រះរាជសមរសព្រះនាង នឹងព្រះរាជបុត្រស្ដេចប្រទេសដទៃៗ បានឡើយ ។ ទ្រង់យល់ថា គួរតែធ្វើព្រះរាជសមរសព្រះនាង នឹងព្រះរាជឱរសព្រះមហាក្សត្រប្រទេសឆ្ងាយៗទើបបាន, ទ្រង់ចាត់អាមាត្យឲ្យធ្វើព្រះរាជសារតបទៅវិញថា: "បុត្រីយើងពេញក្រមុំហើយ, យើងអាចឲ្យបុត្រីយើងទៅជាទេពីព្រះរាជបុត្រព្រះអង្គបាន យើងនឹងត្រូវជាជទួងនឹងគ្នា, ប្រទេសយើងទាំងពីរ នឹងបានជាមិត្តជាមួយគ្នាយ៉ាងជិតស្និទ្ធ សូមស្ដេចយាងមកយកបុត្រីខ្ញុំចុះ" ។

រឿងព្រះមហាក្សត្រចង់ធ្វើព្រះរាជសមរសនោះ សូមស្ទុះតែប៉ុណ្ណេះសិន ។ លំដាប់តទៅ សូមពណ៌នាអំពីព្រះអង្គម្ចាស់ដែលទ្រង់រង់ចាំព្រះនាងតែមួយព្រះអង្គនៅទីនោះ មិនឃើញព្រះនាងនិវត្តមកសោះ, ទ្រង់បានពិនិត្យទីកន្លែងដែលទ្រង់ប្រថាប់ គឺជាវាលខ្សាច់រហោឋានធំធេងលន្លង់លន្លោច មានផ្នូរខ្សាច់ជាច្រើនពាសពេញ, ឯព្រះអាទិត្យបញ្ចេញនូវចំហាយខ្លាំងពន់ពេក, ហើយនៅទីនោះ គ្មានស្មៅ ឬ តិណជាតិ ដុះមួយសរសៃសោះឡើយ ។ ព្រះអង្គម្ចាស់ទ្រង់ស្រេកឃ្លានជាអនេក ទ្រង់

យានទៅរកទឹក ដើម្បីនឹងសោយ, តែទឹកនោះគ្មានសោះ ។ ទ្រង់បាន
ឡើងទៅលើភ្នំខ្សាច់មួយខ្ពស់ ហើយចុះទៅម្ខាងស្មានថា មានដង្គុំព្រៃល
ខ្សាច់ ដែលក្រឡេកមើលពីឆ្ងាយទៅមានពណ៌ស្រស់ខៀវខ្ចី . . . . ,
ប៉ុន្តែ លុះយានដល់កំពូលលើ ស្រាប់តែរអិលផ្លាតព្រះបាទដួលរសាត់
ចុះមកក្រោម ។ ខ្សាច់នោះហូរដូចជាទឹកកកហូរក្នុងទីឆ្ងាយដូច្នោះ ។
កាលបើព្រះអង្គងើបឡើង, ទ្រង់បានទតទៅឃើញឧទ្យានមួយ មាន
ផលានុផលបរិបូណ៌គ្រប់យ៉ាង ។ ផលានុផលនោះ មានពណ៌ក្រហម
ប្រាលឆ្អៅគួរឲ្យចង់សោយពន់ពេក, ទ្រង់បានបេះផ្លែប៉ែសមួយសោយ
ទ្រង់យានទៅផ្ទុំក្រោមដើមឈើនោះហើយលក់ទៅ ដល់ទ្រង់តើនពាក
សយនា យកព្រះហត្ថស្ទាបព្រះភក្ត្រ ទ្រង់យល់ថា ព្រះភក្ត្រសុទ្ធ
តែកេម ។ ព្រះអង្គឆ្ងល់ពន់ពេក ទ្រង់ព្រះតម្រិះថា: មុនអញដេក អញ
គ្មានកេមទេ, ម្តេចមកមានកេមដូច្នេះ? ហើយទ្រង់យល់ថា "ហេតុដែល
មានកេមនេះ ប្រហែលជាមកពីផ្លែប៉ែសនេះទេដឹង!" ។ ដល់បន្តិចទៅ
ទ្រង់ឃ្លានទៀត, ទ្រង់មិនហ៊ានសោយផ្លែប៉ែសទេ, ទ្រង់ខំព្យាយាមគ្រេច
ទៅកាន់ដើមពីរមួយ, ទ្រង់កំពាប់មែកនោះទាញបន្ទាបចុះបេះផ្លែពីរនោះ
សោយហើយទ្រង់ក៏ផ្ទុំលក់ទៅ ។ ដល់តើនពីក្រឡាព្រះបន្ទំស្រាប់តែមាន
ស្នែងដុះចំព្រះសិរទាំងកេមដុះជុំវិញផ្ទៃព្រះនស្ត, មានពុកចង្កាសវែង ។
ទ្រង់មានព្រះបន្ទូលក្នុងព្រះហឫទ័យថា: "នរូបអញអាក្រក់ណាស់ បើព្រះ

នានយានវិលត្រឡប់មកប្រាកដជាព្រះនាងលែងស្គាល់អញ ! ព្រះនាង, អស់សេចក្ដីស្នេហាមកលើខ្លួនអញ, អញអស់សង្ឃឹមហើយ ខុចជាសំណាងអាក្រក់ណាស់តើ ! ក៏ទ្រង់ព្រះកន្សែងហូរទឹកព្រះនេត្រស្រោចស្រប់ព្រះភ័ក្ត្រ ហើយទ្រង់ផ្ទួលក់ទៅ, ស្រាប់តែទ្រង់ព្រះសុបិននិមិត្តឃើញតាចាស់ម្នាក់យកដៃមកបបោសអង្អែលព្រះសិរ ហើយក្រាបបង្គំទូលថា: " ឱព្រះអង្គ, ម្ដេចក៏ទ្រង់ព្រួយព្រះហឫទ័យខ្លាំងម៉្លេះ ? ។

ព្រលឹងនៃព្រះអង្គម្ចាស់ ទ្រង់មានព្រះបន្ទូលទៅកាន់តាចាស់អំពីព្រឹត្តិការណ៍ដែលមានមកចំពោះព្រះរូបព្រះអង្គ ។ តាចាស់ក៏ក្រាបបង្គំទូលថា: "សូមព្រះអង្គកុំព្រួយព្រះហឫទ័យសោះឡើយ សូមទ្រង់រើសផ្លែពីរនឹងផ្លែប៉ែសដែលមានសភាពក្រៀម ដែលធ្លាក់ក្រោមគុម្ពជាតិទាំងនោះ, សូមទ្រង់សោយផ្លែឈើទាំងនោះ , ពុកចង្កានឹងស្នែងដែលដុះនោះនឹងរលក់រលាយជ្រុះបាត់ សូមទ្រង់កុំគង់ប្រថាប់នៅទីនេះ , សូមស្ដេចយាងឡែងបាត់, ពីព្រោះព្រះអង្គគង់នៅកន្ទេឡានៃអ្នកតាយក្សទាំងឡាយ

ពេលនេះព្រះអង្គទ្រង់ក៏ញុំផ្ទុំ, ដល់ទ្រង់តើនចាកព្រះសយនា, ហើយគង់នៅតទៅទៀត ខឹងសោយទំរង់តមិនខាន ! " ។

ព្រលឹងនៃព្រះអង្គម្ចាស់ លុះទ្រង់ព្រះសណ្ដាប់នូវរឿងនេះហើយ, មានព្រះហឫទ័យតក់ស្លុតជាខ្លាំង, ទ្រង់ភ្ញាក់ពីនិទ្រាឡើង, ទ្រង់គង់នៅតែមួយព្រះអង្គឯងក្នុងទីនោះ ។ ព្រះចន្ទពេលរសៀគ្គក្រចះក្រចង់

កណ្ដាលមហា, ព្រះកាយផាយផាត់បក់មកយ៉ាងត្រជាក់; កាលខ្យល់រហោឋានក៏គ្មានចំហាយក្ដៅនិងធូលីហុយសោះឡើយ ។ ក្នុងពេលនោះ, ព្រះអង្គម្ចាស់ ទ្រង់ប្រញាប់ប្រញាល់យាងចេញពីកន្ទ្វងអភាមណ្ឌលនោះ តាមពាក្យដំបូន្មាននៃតាចាស់ ។ ទ្រង់ទៅរើសផ្លែប៉ែសនិងផ្លែពីរដែលជ្រុះកក់កយក្រោមរុក្ខជាតិ ដែលមានសភាពក្រៀមស្ងួតហើយ ទ្រង់សោយនូវផ្លែឈើទាំងនោះ ។ ក្នុងមួយរំពេច ពុកចង្កានិងស្នែងក៏ជ្រុះធ្លាក់បាត់អស់គ្មានលល់ ។ ព្រះអង្គម្ចាស់ទ្រង់ព្រះតម្រិះមួយស្របក់ រួចទ្រង់កាច់មែកឈើស្ងួល ( ស្រល់ ) ក្រងជាល្អីមួយ ហើយទ្រង់ប្រមូលផ្លែប៉ែសនិងផ្លែពីរដែលមានសភាពក្រៀម និងផ្លែដែលកំពុងមានទឹកដមផ្អែមឆ្ងាញ់ដាក់ក្នុងល្អីនោះ ។ រួចទ្រង់ចាកចេញពីឧទ្យាននោះទៅដោយប្រញាប់ប្រញាល់ជាខ្លាំង ។ ទ្រង់មានបំណងចង់និវត្តទៅកាន់មាតុភូមិវិញ, តែទ្រង់មិនជ្រាបផ្លូវសោះ ទ្រង់ចេះតែយាងទៅជាលំដាប់ ។ ទ្រង់បានធ្វើព្រះដំណើរប្រាំពីរថ្ងៃប្រាំពីរយប់ នៅក្នុងកាលខ្យល់រហោឋាន, ទ្រង់មិនបានជួបប្រទះនឹងមនុស្សសត្វអ្វីសោះឡើយ ។ តមកទ្រង់មានសេចក្ដីស្រេកឃ្លានជាខ្លាំង បានសោយផ្លែពីរនិងផ្លែប៉ែសក្រៀមនោះទៅ ។ លុះនឿយព្រះកាយពល, ក៏ផ្ទំនៅលើថ្មកខ្យល់លក់ទៀត លុះតើនឡើងចាប់បន្តព្រះដំណើរតទៅទៀត បានយាងទៅដល់ថ្នល់ធំមួយ

ផុតពីគ្រោះថ្នាក់នោះ ហើយគង់នៅលើចំពោមថ្មល់ ដើម្បីសម្រាកព្រះកាយ ។

ក្រោយមកបន្តិច មានមនុស្សម្នាក់ដឹកលាមួយដើរមកដល់ទីនោះ ។ ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលសួរពត៌មានផ្សេង ៗ ពីអ្នកដឹកលា ។ ក៏ក្រាបបង្គំទូលថា បើព្រះអង្គចង់ធ្វើព្រះដំណើរទៅកាន់មាតុភូមិ សូមស្តេចយាងទៅកាន់ទិសខាងកើត ។ បើមានព្រះរាជបំណងចង់ជួបនឹងព្រះអង្គម្ចាស់ក្សត្រីសូមស្តេចយាងទៅទិសខាងលិច ។ គ្រានោះ ព្រះអង្គម្ចាស់ទ្រង់មានព្រះតម្រិះថា "អញចង់ឃើញព្រះអង្គម្ចាស់ក្សត្រីនឹងសេះឈើ អញមិនត្រូវត្រឡប់ទៅកាន់ព្រះនិវេសន៍វិញទេ គួរតែធ្វើដំណើរទៅកាន់ទិសខាងលិច ដើម្បីឲ្យបានជួបនឹងព្រះអង្គម្ចាស់ក្សត្រីនឹងសេះឈើ" ។

លុះទ្រង់យាងទៅបន្តិច ទ្រង់បានឮសូរសព្ទដូចជាជើងសេះរណ្តំលើថ្មល់ពីក្រោយព្រះអង្គ លុះទ្រង់ងាកព្រះនេត្រទៅ, បានយល់ពួកយោធាមួយក្រុមជិះសេះពាក់គ្រឿងដែក ហើយស្រែកយ៉ាងខ្លាំងព្រមទាំងមានបុកពាដំខែងរ៉ែងផង ។

(នៅមានត)

# ប្រកាសប្រឡងប្រជែងពាក្យទំនៀមទម្លាប់ខ្មែរ
## ក្នុងឆមាសទី ២ ឆ្នាំ ១៩៦២

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ មុខ គឺ :

១– អំពីទឹក

២– អំពីពពិល

វិញ្ញាសាប្រឡងនេះ សម្រេចយកនៅឆមាសទី ២
គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦២

ដូច្នេះ អស់លោកអ្នកចេះដឹងទាំងឡាយ ជាស្ត្រី ឬបុរស ឬជាបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងវិញ្ញាសា ស្ដីអំពីទឹក និង អំពីពពិល តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែធ្នូ ឆ្នាំ ១៩៦២ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ ៤ ថ្នាក់

| | |
|---|---|
| –រង្វាន់លេខ ១ ... ៧០០រ៛០០ | –រង្វាន់លេខ ៣ ... ៤០០រ៛០០ |
| –រង្វាន់លេខ ២ ... ៥០០រ៛០០ | –រង្វាន់លេខ ៤ ... ២០០រ៛០០ |

បណ្ដាវិញ្ញាសាតាំង ២ មុខនេះ បើបេក្ខជនមួយរូបស៊ូត្រចិត្តធ្វើដាក់ប្រឡងតាំង ២ មុខហើយបានល្អតាំង ២ មុខ អាចបានរង្វាន់តាំង ២ មុខ តែបើត្រូវការដាក់ប្រឡងតាំង ២ មុខ សូមធ្វើ ១ មុខ ១ ដោយឡែកពីគ្នា គឺសូមសរសេរលើសៀវភៅសរសេរធុនស្ដើងតាមសេចក្ដីខ្ញុំ ឬធុនក្រាស់តាមសេចក្ដីវែង ហើយសូមសរសេរនាម និងទីលំនៅរបស់ខ្លួន ឲ្យច្បាស់លាស់លើក្រដាស ១ សន្ធឹកផ្សេងដាក់ក្នុងស្រោមសំបុត្រជាមួយនឹងវិញ្ញាសានោះ១ រួចយកទៅឲ្យផ្ទាល់ខ្លួនក៏បាន ផ្ញើតាមប៉ុស្ដិ៍ទៅក៏បាន យកទៅជូនសាលាឃុំ សាលាស្រុក ឬខេត្ត សុំឲ្យផ្ញើឲ្យក៏បាន ដោយការខ្ទង់សំបុត្រថា:

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

(ផ្នែកក្រុមជំនុំទំនៀមទម្លាប់ខ្មែរ)

## គោលបញ្ហានៃការប្រឡងប្រជែង

### ១- អំពីទឹក

ទឹកជាវត្ថុចាំបាច់មួយ ដល់វត្ថុជាតុតាំងមានជីវិត តាំងឥតជីវិត ។

ខ្មែរយើងមានជំនឿ និងទំនៀមផ្សេងៗច្រើនណាស់ ដែលទាក់ទងដោយទឹក ។ នៅខាងក្រោមនេះ ក្រុមជំនុំសូមជូនឧទាហរណ៍ខ្លះដល់បេក្ខជនដែលចូលចិត្តសរសេរតែងទៅដាក់ប្រឡងប្រជែង ប៉ុន្តែបេក្ខជនអាចសរសេរការដែលទាក់ទងដោយទឹក ក្រៅអំពីឧទាហរណ៍ទាំងនេះបានតាមការដែលអស់លោកចេះដឹង ។

ទឹកសន្សើមនិងទឹកភ្លៀង.— តាមទំនៀមខ្មែរយើង ទឹកទាំងពីរយ៉ាងនេះ កើតឡើងរបៀបដូចម្ដេច? ភ្លៀងមានប៉ុន្មានយ៉ាង? អាទិទេពរបស់ភ្លៀងឈ្មោះអ្វីខ្លះ? ការប្រើប្រាស់ទឹកសន្សើម, ទំនៀម និងពាក្យស្លោកផ្សេងៗ ទាក់ទងដោយទឹកសន្សើមនិងទឹកភ្លៀង?

ទឹកនិងព្រះចន្ទ .— នៅពេលសំពះព្រះខែ ខ្មែរយើងនៅជនបទក្រៅ ច្រើនតែធ្វើពិធីសម្រក់ទៀនតាមទឹកភ្លៀងក្នុងឆ្នាំនីមួយៗ ។ កិច្ចនេះបង្ហាញឲ្យឃើញថា ជនជាតិខ្មែររៀបចំឲ្យមានការទាក់ទងរវាងព្រះចន្ទនិងទឹកដែរ ។ តើលោកអ្នកជ្រាបរឿងរ៉ាវអ្វី, ពាក្យសុភាសិត ឬពាក្យស្លោកអ្វី ឬក៏ទំនៀមបុរាណអ្វីដែលនិយាយពីព្រះចន្ទនិងទឹក មានការទាក់ទងគ្នាតាំងពីព្រេងនាយមកទេ?

ទឹកក្នុងទំនៀមផ្សេង ៗ.– របៀបធ្វើនិងប្រើទឹកប្រសិទ្ធិពរ ? ការស្រោចឬប្រស់ព្រំទឹកនេះនៅពេលធ្វើពិធីផ្សេង ៗ ដូចជាការស្រោចទឹក ? ការប្រើទឹកក្នុងមន្តអាគម ?

ទឹកជ្រោះ – ជំនឿ ទំនៀម និងការប្រើប្រាស់ទឹកនេះ ៗ

អូរ- ព្រែក- ស្ទឹង, ទន្លេ, សមុទ្រ, បឹង, ស្រះ .– សូមលោកអ្នកប្រឡងគេធិប្បាយអំពីអត្ថន័យនៃវារិបថ (ផ្លូវទឹក) ទាំងនេះ ព្រមទាំងសភាពដែលមានផ្ទុកគ្នា ។បបមាថា ម្ដេចហៅអូរ ? ម្ដេចហៅព្រែក ? ម្ដេចហៅស្ទឹង ? ម្ដេចហៅទន្លេ ? វារិបថអំបាលនេះ មានសភាពខុសគ្នាម្ដេចខ្លះ ទើបគេអាចស្គាល់ថានេះជាអូរ នេះជាព្រែក នេះជាស្ទឹង នេះជាទន្លេ . . . បាន ? លោកអ្នកជ្រាបរឿងរ៉ាវអ្វីទាក់ទងដោយវារិបថដែលលោកអ្នកស្គាល់នោះទេ ? លោកអ្នកស្គាល់បឹង ទន្លេ បារាយណ៍ ស្រះកន្លែងទឹកធ្លាក់ រូងថ្ម ជ្រោះ ទឹកប្រាល់ ៗ ល ៗ ដែលមនុស្សចូលចិត្តទៅធ្វើជាបូជនីយសក៍ឬទេ ? បើស្គាល់សូមអធិប្បាយ ៗ នៅបច្ចុប្បន្នកាលនេះ តើគេនៅគោរពទំនៀមផ្សេង ៗ ឬទេ ក្នុងការសង់ផ្ទះកសាងភូមិថ្មី ដែលនៅជិតកន្លែងមានទឹកល្អល្អាច ឬទឹកទន្លេ ស្ទឹង បឹង ៗ ល ៗ នៅពេលដែលគេនឹងជីកស្រះ ឬអណ្ដូង តើគេធ្វើពិធីនិងមើលភាពដីដូចម្ដេចខ្លះ ? ចុះបើគេត្រូវលើករបាំង ឬទំនប់ទឹក តើមានទំនៀមធ្វើដូចម្ដេចខ្លះ ?

គ្រោះថ្នាក់ដោយផ្លូវទឹក.– បើគេត្រូវការធ្វើដំណើរតាមផ្លូវទឹក តើមានជំនឿអ្វីខ្លះ ? ការប្រតិបត្តិយ៉ាងណាខ្លះដែលទាក់ទងដោយការជៀស-គ្រោះតាមផ្លូវទឹកនោះ ? បើប្រសិនជាមានមនុស្សលង់ទឹក តើគេត្រូវធ្វើដូចម្តេចដើម្បីជួយឲ្យគេរួចពីទុក្ខ ? បើយើងទៅក្នុងព្រៃហើយទឹកធ្វើឲ្យមានគ្រោះថ្នាក់ តើមានពិធីដូចម្តេចខ្លះ ? (ដូចទឹកដែលមានជាតិពុលដោយមានស្លឹកឬផ្លែឈើពុលជ្រុះត្រាំនៅ បរិភោគមិនបាន) តើមានរបៀបអ្វីដើម្បីបន្សាបជាតិពុលឲ្យទឹកនោះទៅជាទឹកបរិភោគបានឬទេ ?

កន្លែងធ្វើអំបិល ឬស្រែអំបិល.– ក្រុមជំនុំគ្នានឯកសារមួយនិ-យាយអំពីរឿងស្រែអំបិលសោះ ការធ្វើអំបិលមានរបៀបយ៉ាងណាខ្លះ ? តើមានទំនៀម ឬគ្រណមអ្វីខ្លះទាក់ទងដោយការធ្វើអំបិលនេះ ?

ប្រដាប់ប្រើប្រាស់បុរាណដែលប្រើដោយទឹក.– ដូចជារហាត់ទឹក ស្នាប...។ល។ សូមអធិប្បាយអំពីរបៀបធ្វើ របៀបប្រើ និងជំនឿផ្សេងៗ ទាក់ទងដោយរបស់ទាំងនោះ ។ ក្នុងរឿងនេះលោកអ្នកប្រឡងចង់សរសេរតែងអំពីអ្វីក៏បាន ឲ្យតែជារបស់ប្រើដោយទឹក ទោះជាប្រដាប់ដាក់ទឹក តម្រង់ទឹក ។ល។ ក៏បានទាំងអស់ ។

អាទិទេព និងសត្វអស្ចារ្យទាក់ទងដោយទឹក.– សូមអធិ-ប្បាយអំពីរឿងនាគ ឬសត្វអ្វីដែលខ្មែរយើងតែងនិយាយថាជាអ្នកបណ្តាល

ឲ្យមានភ្លៀង ឬឲ្យមានទឹកជន់ ។ សូមអធិប្បាយអំពីពិធី អំពីរឿងព្រេងនិទានអំពីទំនៀមផ្សេង? ដែលគេតែងធ្វើនៅពេលមានភ្លៀង ឬមានទឹកជំនន់ ៗ ចំណែករឿងរាំងភ្លៀងវិញ ខ្មែរយើងក៏មានជំនឿដែរ តើហេតុភេទអ្វីដែលបណ្ដាលឲ្យរាំងភ្លៀង ?

សត្វដែលរស់នៅក្នុងទឹក.- ការរាប់ឈ្មោះសត្វទឹកទទេ គ្មានសេចក្ដីអធិប្បាយ មិនមែនត្រូវចំណង់របស់ក្រុមជំនុំទេ ។ ហេតុនេះក្រុមជំនុំត្រូវការឲ្យលោកអ្នកប្រឡងអធិប្បាយអំពីទំនៀមទម្លាប់ ជំនឿ ចំណាំផ្សេងៗ ទាក់ទងដោយសត្វទឹក ៗ

លោកអ្នកជ្រាបទេពីរឿងបុរាណដែលមានដំណាលថាសត្វនេះ រស់បានតែក្នុងទឹក សត្វនោះរស់បានតែលើគោក សត្វនោះទៀតរស់បានទាំងក្នុងទឹកទាំងលើគោក មានសត្វខ្លះចេះហែលហើយមុជទឹកពូកែផង? តើអស់លោកអ្នកជ្រាបរឿងព្រេង ទំនៀម ជំនឿ ពាក្យស្លោកផ្សេងៗ និងគ្រណាមទាក់ទងដោយសត្វទឹកដែរឬទេ ?

ទឹកនៅក្នុងខ្លួនមនុស្ស និងខ្លួនសត្វ.- ទឹកភ្លោះ, ទឹកដោះ, ឈាម, ញើស, ទឹកភ្នែក ... និងទឹកដទៃទៀត ដូចជាទឹកឃ្មុំ ៗ ល ៗ ប្រពៃណី ស្ដីអំពីការបង្កបង្កើតទឹកនោះនៅក្នុងខ្លួនមនុស្សយើង និងអំពីការប្រើទឹកនៅក្នុងការជាឱសថ, ក្នុងការធម្មតា ព្រមទាំងក្នុងមន្តអាគម ?

ទឹកនៅក្នុងដើមឈើ.– សូមអធិប្បាយអំពីទំនៀម អំពីពាក្យស្លោកអំពីជំនឿផ្សេង ៗ និងអំពីការប្រើប្រាស់ទឹកនេះក្នុងឱសថ, ក្នុងមន្តអាគមនោះជាដើរក្តី ជាអ៊ីក្តី ៗ

២–អំពីពពិល

ក្នុងទំនៀមខ្មែរយើង ពិធីបង្វិលពពិល ជាមង្គលមួយធំណាស់ បានជាក្រុមជំនុំចង់បានសេចក្តីអធិប្បាយឲ្យបានសព្វគ្រប់ ៗ ការណ៍ដែលក្រុមជំនុំត្រូវការនោះដូចមានជូនជាលំនាំខ្លះតទៅនេះ៖

១– ដើមកំណើតពពិល និងការតំណាងរបស់ពពិល.–

២– រូបរាង និងក្បាច់របនាលើតួពពិល.–

បើគ្មានពពិល តើគេអាចយកអ្វីជាជំនួសបានឬទេ បើគេត្រូវតែធ្វើទានមិនបាន ? ពពិលមានក្បាច់ផ្សេង ៗ តើមានទំនៀមទម្លាប់ថាពពិលរូបនេះត្រូវប្រើក្នុងពិធីនេះ ក្បាច់នោះត្រូវប្រើក្នុងពិធីនោះឬទេ ? តើពពិលមានក្បាច់ដូចម្តេចនៅក្នុងស្រុករបស់លោកអ្នក ? លោកជ្រាបទេ នៅស្រុកនៅឃុំឯទៀតមានខុសគ្នាដូចម្តេចខ្លះ ? បើនៅក្នុងគ្រួសារណាមានពពិលតើគេមានទំនៀម ឬគ្រណាមអ្វី ចំពោះរបស់នោះឬទេ ?

ទៀនសម្រាប់ប្រើជាមួយពពិល .– ទៀននោះដូចម្តេច ? ប៉ុណ្ណា ? មានអំបោះប៉ុន្មានសរសៃជាប្រទេះ ? ត្រូវមានទម្ងន់ប៉ុន្មានដំឡឹង

សម្រាប់ពិធីអ្វី? ប៉ុន្មានទៀតសម្រាប់ពិធីដទៃ ?

**គេធ្វើពិធីបង្វិលពពិលនៅពេលណា?** ពិធីអ្វីខ្លះដែលគេត្រូវបង្វិលពពិល ? គេធ្វើពិធីនេះនៅពេលណា ? (ដូចក្នុងអាពាហ៍ពិពាហមង្គលគេធ្វើនៅពេលផ្ទឹមព្រឹកបង្ហើយពិធី ) សូមអស់លោកអ្នកប្រឡងអធិប្បាយឲ្យច្បាស់ បើជាធ្វើជាមួយនឹងពិធីហៅព្រលឹង តើគេធ្វើក្រោយ ឬធ្វើមុន ? បើនៅពេលចងដៃ តើធ្វើមុនឬក្រោយចងដៃ ? ។ល។

**ពិធីបង្វិលពពិលធ្វើដូចម្តេច?** ចំនួនមនុស្សប៉ុន្មាននាក់ដែលត្រូវធ្វើ និងគុណសម្បត្តិមនុស្សដូចម្តេចដែលត្រូវរើសឲ្យធ្វើពិធីនេះ ? ចំនួនពពិលប៉ុន្មានដែលត្រូវប្រើ ? គេហុចពពិលពីម្នាក់ទៅម្នាក់ដូចម្តេច? ទទួលដៃណា កាន់ដៃណា បក់ផ្សែងដៃណា ផាត់ផ្សែងទៅខាងណា ? គេបង្វិលប៉ុន្មានជុំ ? ពន្លត់ភ្លើងពពិលដូចម្តេច ? គេសូត្រធម៌អ្វីខ្លះនៅពេលនោះ? ពពិលត្រូវបង្វិលពីខាងណាទៅខាងណា? មនុស្សរស់គេបង្វិលពីខាងណាទៅខាងណា ? មនុស្សស្លាប់ពីខាងណាទៅណា ?

មនុស្សដែលគេត្រូវធ្វើពិធីបង្វិលពពិលឲ្យនោះ ត្រូវអង្គុយដូចម្តេច ? អ្នកបង្វិលត្រូវអង្គុយដូចម្តេច ? មានសំណែនអ្វីទេ? សំណែនទាំងនោះមានរបៀបដូចម្តេចខ្លះ ? នៅឱកាសដែលគេមិនធ្វើពិធីនេះនៅជុំវិញមនុស្សទេ គឺដូចជានៅពេលបញ្ចុះសីមាជាដើម តើពិធីនេះគេធ្វើដូចជាធ្វើចំពោះមនុស្សដែរឬដូចម្តេច ?

ដើម្បីឲ្យវិញ្ញាសាមានភស្តុតាង ក្រុមជំនុំសូមឲ្យអស់លោកអ្នកតែងបញ្ជាក់ដើមកំណើតនៃការណ៍ដែលលោកសរសេរតែងនោះ ថាបានដឹងពីអ្នកណា ? ឈ្មោះអ្វី ? ធ្វើការរកស៊ីអ្វី ? នៅស្រុកភូមិណា? ក្នុងសម័យបច្ចុប្បន្ននេះបានដឹងដោយបានឃើញគេ ឬធ្លាប់បានធ្វើផ្ទាល់ខ្លួន ? បើមានពិធីណាដែលគេលែងធ្វើទៅហើយក៏សូមប្រាប់ផង កុំភ្លេច ។

ជាធម្មតាក្រុមជំនុំ បានសង្កេតឃើញអស់លោកអ្នកប្រឡង ច្រើនសរសេរតែងសង្ខេបពេក លេបបាត់ការសំខាន់ ដែលក្រុមជំនុំត្រូវការអស់ សូមលោកអ្នកកុំខ្លាចវែងឲ្យសោះ សូមធ្វើឲ្យអស់សេចក្ដី ព្រោះបើការដែលលោកតែងនោះជាការចាំបាច់ ការរៀបរប់ចោល ។ ធ្វើឲ្យក្រុមជំនុំរិះរកការប្រាកដពុំឃើញ ។ ហេតុនេះ សូមអធិប្បាយខមួយៗ ឲ្យសព្វគ្រប់តាមដែលលោកចេះចាំ ។

ជាពិសេស ក្រុមជំនុំសូមជំរាបលោកអ្នកស្ម័គ្រចិត្តប្រឡងថា មុននឹងតែង សូមពិនិត្យមើលពាក្យសួររបស់យើងឲ្យមែនទែន ដើម្បីកុំឲ្យឃ្លាតសេចក្ដីគ្នា បើមានការអ្វីដែលអស់លោកនៅឆ្ងល់ សូមសរសេរទៅសួរក្រុមជំនុំៗ នឹងឆ្លើយបំភ្លឺសេចក្ដីជូនតាមបំណង ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

ផ្នែកកំណត់និងប្រវត្តិការណ៍

# ពិធីបុណ្យវិសាខបូជា នៅមុខព្រះសក្យមុនីចេតិយ

លោក ជង · វង រៀបរៀង

ប្រទេសកម្ពុជា ក្រោមការដឹកនាំនៃសម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គ-ពុទ្ធសាសនូបត្ថម្ភ និងក្រោមព្រះរាជូបត្ថម្ភនៃព្រះរាជបល្ល័ង្ក អស់កាលជាច្រើនសតវត្សមកហើយ ដែលក្នុងរជ្ជកាលនេះ មានសម្តេចព្រះមហា-ក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងជានិមិត្តរូប ទ្រង់បានកាន់ព្រះពុទ្ធសា-សនាយ៉ាងខ្ជាប់ខ្ជួន ដើម្បីប្រយោជន៍ដល់ការទ្រទ្រង់ជាតិ ឲ្យបានឋិតនៅក្នុងសភាពក្សេមក្សាន្តខាងផ្លូវកាយនិងផ្លូវចិត្ត ។

ព្រះសមណៈគោតមបរមគ្រូ ទ្រង់បរិនិព្វានទៅបាន ២៥០៩ ឆ្នាំហើយ ប៉ុន្តែសាសនធម៌របស់ព្រះអង្គបានឋិតនៅរហូតសព្វថ្ងៃ ។ ព្រោះហេតុដូច្នោះ បានជាជាតិខ្មែរ ៩៩ ភាគរយ ក្នុងប្រទេសកម្ពុជាតាំងមូលលុះដល់ថ្ងៃ ១៥ កើតខែវិសាខនៃឆ្នាំនីមួយៗ រមែងតុបតែងគ្រឿងសក្ការ-បូជាអុជប្រទីបផ្កាលា គ្រប់ផ្ទះ គ្រប់វត្តអារាម ធ្វើបុណ្យរំលឹកដល់ថ្ងៃដែលព្រះបរមគ្រូទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង និងទ្រង់បរិនិព្វាន ។

ជាពិសេស នៅរាជធានីភ្នំពេញ ក្រោមព្រះបរមរាជូបត្ថម្ភដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ និងសម្តេចព្រះប្រមុខរដ្ឋ

ព្រះបិតាជាតិ, កងរង្វាត្តិបាលបានរៀបចំយ៉ាងមហោឡារិកនូវពិធីបុណ្យវិសាខបូជា នៅព្រះសក្យមុនីចេតិយត្រង់មុខស្ថានីយរថភ្លើង ស្ថានីយដែលតែងតែធ្វើជារៀងរាល់ឆ្នាំមក ដោយកិច្ចចាត់ចែងនៃពុទ្ធិកសមាគមទាំង ៣ កងការិយាល័យរបស់ក្រសួងធម្មការ ។

នៅវេលាម៉ោង ៥ និង ៣០ នាទីល្ងាច នៃថ្ងៃ ១៥ កើត ខែវិសាខ ព.ស. ២៥០៥ ( ១៨.៥ ៦២ ) មានការជួបជុំព្រះសង្ឃចំនួន ៨០ អង្គ ដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ព្រះរាជវង្សានុវង្ស ប្រធាននៃសភាទាំងពីរ សមាជិកកងរង្វាត្តិបាល សមាជិកនៃសភាទាំងពីរ ប្រធាននៃពុទ្ធិកសមាគមទាំង ៣ មន្ត្រីគ្រប់ជាន់ថ្នាក់ទាំងទាហានទាំងស៊ីវិល លោកស្រី-យុវជនរាជសង្គមនិយមខ្មែរ - សិស្សានុសិស្សប្រុសស្រី ព្រមទាំងពុទ្ធបរិស័ទជាច្រើន បាននិមន្ត និងអញ្ជើញមកដើម្បីប្រជុំមកក្នុងពិធីបុណ្យវិសាខបូជានេះ ។

នៅវេលាម៉ោង ៦ គត់ សម្ដេចព្រះប្រមុខរដ្ឋព្រះបិតាជាតិ ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះមហាក្សត្រិយានីជាទីគោរព ទីងជាទីស្នេហាស្មើជីវិត ដោយមានសមាជិកកងរង្វាត្តិបាល និងព្រះរាជបរិពារផ្ទាល់ជាច្រើនអមផង បានស្ដេចយាងដល់មុខព្រះសក្យមុនីចេតិយ ដោយបានទទួលគារវកិច្ចយ៉ាងខ្ពង់ខ្ពស់អំពីក្រុមទាហានរក្សាព្រះអង្គ កងយោធ-

ពលខេមរភូមិន្ទទាំង ៣ ផ្នែក នឹងក្រុមតន្ត្រីព្រះរាជទ្រព្យ បានបន្លឺនូវបទភ្លេងចរលីលា នឹងភ្លេងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ ។ បន្ទាប់មក ព្រះអង្គបានស្តេចយាងចូលកាន់ព្រះពន្លាពិសេសថ្វាយបង្គំព្រះសង្ឃ ដែលមានសម្តេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន ហើយព្រះអង្គទ្រង់បានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនទាំងឡាយ ដែលរង់ចាំក្រាបថ្វាយបង្គំគាល់នៅទីនោះ ។

តមក មានធ្វើពិធីគោរពទង់ជាតិនឹងទង់ពុទ្ធសាសនា ដោយក្រុមតន្ត្រីព្រះរាជទ្រព្យ បានបន្លឺនូវបទភ្លេងនគររាជនឹងបទសរភញ្ញ ព្រមទាំងមានក្រុមសិស្សប្រុសស្រី បានច្រៀងនូវបទនគររាជ នឹងថ្វាយបទសរភញ្ញកំដរការគោរពនេះផង ។ បន្ទាប់មក សហជីវិន ចន្ទ-សុន នាយកការិយាល័យក្រសួងធម្មការ ជាតំណាងព្រះរាជរដ្ឋាភិបាល នឹងពុទ្ធបរិស័ទទាំងអស់ បានថ្វាយសុន្ទរកថាមួយ សំដែងសេចក្តីគោរពចំពោះព្រះបរមសារីរិកធាតុ ក្នុងព្រះសក្យមុនីចេតិយ ដែលមានអត្ថន័យគោរពដ៏ជ្រាលជ្រៅជាអនេកប្បការ ។ ក្រោយពេលចប់សុន្ទរកថា មានធ្វើពិធីនមស្ការជាឧឡារិក រំលឹកចំពោះព្រះគុណព្រះបរមគ្រូជាអម្ចាស់ ដែលទ្រង់បរិនិព្វានកន្លងទៅហើយ ដោយលោក ឈឹម-ស៊ិមង់ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ជាអាចារ្យសូត្រនាំមុខ ។

បន្ទាប់មក សម្ដេចព្រះប្រមុខរដ្ឋព្រះបិតាជាតិ ព្រះរាជវង្សានុវង្ស និងឥស្សរជន ព្រមទាំងពុទ្ធបរិស័ទទាំងឡាយ បានស្ដេចយាង និងអញ្ជើញហែប្រទក្សិណព្រះសក្យមុនីចេតិយ ៣ ជុំ ដោយមានលោកឈីម-ស៊ុមឆំដដែល ជាអ្នកនាំព្រះរាជដំណើរ ហើយស្ដេចយាងចូលចំពោះមុខព្រះចេតិយបូជាទៀនធូបភ្ញី ចំពោះព្រះបរមសារីរិកធាតុក្នុងព្រះសក្យមុនីចេតិយ ដែលក្នុងពេលនោះ ព្រះរាជបរិពារទាំងឡាយ ក៏បានបូជាទៀនធូបភ្ញីជាបន្តបន្ទាប់គ្នាមកដែរ រួចហើយ សម្ដេចព្រះប្រមុខរដ្ឋស្ដេចយាងត្រឡប់ចូលកាន់ព្រះពន្លាពិសេសវិញ ។

គ្រានោះ ព្រះសង្ឃ ៨០ អង្គ ដែលមានសម្ដេចព្រះសង្ឃនាយកទាំងពីរគណៈជាប្រធាន បានស្វាធ្យាយព្រះពុទ្ធជ័យមង្គលគាថា ចំរើនសិរីសួស្ដីក្នុងពិធីបុណ្យ ។ បន្ទាប់មក មន្ត្រីគ្រប់តំណែង ទាហានស៊ីវិល ព្រមទាំងពុទ្ធបរិស័ទទាំងឡាយ បាននាំគ្នាចូលទៅបូជាទៀនធូបភ្ញី ចំពោះព្រះសក្យមុនីចេតិយ ដើម្បីសាងកុសលតាមសេចក្ដីប្រាថ្នារៀងខ្លួន ។

វេលាម៉ោង ៦ និង ៤៥ នាទី សម្ដេចព្រះប្រមុខរដ្ឋ ដោយមានសមាជិកករាជវង្សានុពាលនិងព្រះរាជបរិពារផ្សេងៗជាច្រើនអមផង បានស្ដេចយាងនិវត្តវិញ ។

ក្នុងរាត្រីនោះ នៅកន្លែងប្រារព្ធពិធី ពុទ្ធិកសមាគមទាំង ៣ ដែលឋិតនៅក្នុងការឧបត្ថម្ភរបស់ក្រសួងធម្មការ បានធ្វើពិសាខបូជា ដោយបាននិមន្តព្រះសង្ឃសំដែងធម៌ទេសនា ជាទីសណ្ដាប់នឹងជាឱវាទដ៏ប្រពៃ ព្រមទាំងនិមន្តព្រះសង្ឃសូត្រព្រះពុទ្ធគាថា រហូតដល់ពេលអធ្រាត្រ ។

លុះព្រឹកឡើង ថ្ងៃសៅរ៍ ១ រោចខែពិសាខ ព.ស. ២៥០៥ ត្រូវនឹងថ្ងៃ ១៩ ឧសភា ១៩៦២ នៅត្រង់កន្លែងប្រារព្ធពិធី នាព្រះពន្លាពិសេសមុខព្រះសក្យមុនីចេតិយដែល ចាប់តាំងពីម៉ោង ៨ និង ៣០ នាទីទៅ មានការជួបជុំព្រះសង្ឃ ៨០ អង្គ ព្រះរាជវង្សានុវង្ស ប្រធានសភាទាំងពីរ សមាជិកព្រះរាជរដ្ឋាភិបាល សមាជិកសភាទាំងពីរ ប្រធានពុទ្ធិក-សមាគមទាំង ៣ រដ្ឋមន្ត្រីក្រសួងធម្មការ មន្ត្រីអ្នករាជការគ្រប់តំណែងទាំងទាហាន ទាំងស៊ីវិល លោកស្រី និងពុទ្ធបរិស័ទជាច្រើនពាន់នាក់ បាននិមន្ត ស្ដេចយាង អញ្ជើញមក ដើម្បីរួបរួមជាកិត្តិយស និងជួយឧបត្ថម្ភក្នុងពិធីបុណ្យនេះដូចកាលពីល្ងាច ។

នៅវេលាម៉ោង ៨ និង ៤៥ នាទី សម្ដេចព្រះប្រមុខរដ្ឋ ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះមាតាជាតិ ដោយមានព្រះរាជបរិពារជាន់ខ្ពស់ផ្ទាល់ព្រះអង្គជាច្រើនហែអមព្រះរាជដំណើរផង បានស្ដេចយាងមកដល់កន្លែងប្រារព្ធពិធី ដោយទ្រង់បានទទួលគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត

អំពីក្រុមទាហានរក្សាព្រះអង្គ ក្រុមខេមរកុមារទាំង ៣ កង ក្រុមក្មេងកងវរសេនាតូចរក្សាព្រះអង្គ និងក្រុមតន្ត្រីព្រះរាជទ្រព្យ ដែលបានលើកអាវុធធ្វើវន្ទនកិច្ច និងបន្លឺនូវបទភ្លេងជាតិថ្វាយជាព្រះរាជកិត្តិយសចំពោះព្រះអង្គ ។ រួចហើយ ស្តេចយាងចូលកាន់ព្រះពន្លាពិសេសថ្វាយបង្គំព្រះសង្ឃ ដែលនៅទីនោះព្រះអង្គបានទទួលការក្រាបថ្វាយបង្គំអំពីឥស្សរជនទាំងឡាយ ដែលរង់ចាំក្រាបថ្វាយបង្គំគាល់ ។

តមក មានធ្វើពិធីសមាទានសីលតាមទំនៀមទម្លាប់ពិធីបុណ្យ ក្នុងព្រះពុទ្ធសាសនា ហើយនៅពេលបន្ទាប់ពីនេះ សម្តេចព្រះប្រមុខរដ្ឋព្រមទាំងឥស្សរជន ក៏បានស្តេចយាង អញ្ជើញដាក់បាត្រព្រះសង្ឃដែលជាកិច្ចក្នុងពិធីបុណ្យ ។ ព្រះសង្ឃក៏បានធ្វើគាថានុមោទនាថ្វាយព្រះរាជ-កុសលនិងជូនកុសល ចំពោះពុទ្ធបរិស័ទទាំងឡាយ ដែលមានសទ្ធាជ្រះថ្លាបានស្តេចយាងនិងអញ្ជើញមកក្នុងពិធីបុណ្យដ៏ឧឡារិកនេះ ។

លុះចប់កិច្ចនោះហើយ មានធ្វើពិធីដាក់ទង់ជាតិនិងទង់សាសនា ដោយក្រុមតន្ត្រីព្រះរាជទ្រព្យ បានបន្លឺនូវបទភ្លេងជាតិនិងបទសរភញ្ញ ដែលក្នុងពេលនោះ ក្រុមសិស្សានុសិស្សប្រុសស្រី បានច្រៀងបទទាំងពីរនេះ កំដរបទភ្លេងក្នុងការដាក់ទង់នេះផង ។

ពិធីបុណ្យវិសាខបូជានៅមុខព្រះសក្យមុនីចេតិយនេះ បានចប់សព្វគ្រប់នៅវេលាម៉ោង ១០ គត់ ហើយសម្តេចព្រះប្រមុខរដ្ឋដោយមានព្រះរាជបរិពារដែលតាមដង្ហែផង បានស្តេចយាងនិវត្តវិញ ដោយមានការធ្វើការវិកិច្ចថ្វាយជាព្រះរាជកិត្តិយសដូចកាលស្តេចយាងមក ។

សូមជំរាបថា នៅជុំវិញព្រះសក្យមុនីចេតិយនិងនៅខាងកើតព្រះពន្លាពិសេសក្នុងបរិវេណនៃសួនច្បារ មានពុទ្ធបរិស័ទប្រុសស្រីក្មេងចាស់ជាច្រើនពាន់នាក់ បាននាំយកខាទនីយៈនិងភោជនីយាហារដ៏ប្រសើរមកដាក់បាត្រព្រះសង្ឃ ដែលគណៈកម្មការបុណ្យបាននិមន្តមកជាច្រើនរយអង្គ ដើម្បីទទួលនូវចង្ហាន់បិណ្ឌបាតក្នុងពិធីបុណ្យនេះ ដែលបានប្រព្រឹត្តទៅយ៉ាងសប្បាយ នៃពុទ្ធសាសនិកជនទូទៅ ៕

---